# ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨

## ពលករខ្មែរពីរនាក់ប្តីប្រពន្ធធ្វើការធ្វើនៅថៃត្រូវរថយន្តបុកស្លាប់ទាំង២នាក់

http://nokorwatnews.com/ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៨

ពលករខ្មែរ២នាក់ប្តីប្រពន្ធ ដែលបានចូលទៅធ្វើការ និងរស់នៅឯប្រទេសថៃយូរឆ្នាំដែរហើយនោះ បានជួបគ្រោះថ្នាក់ចរាចរណ៍ បណ្តាលឲ្យស្លាប់ទាំងប្តីទាំងប្រពន្ធថ្លុកឈាម យ៉ាងអាណោចអាធ័មក្នុង ខណៈពួកគេទាំង២នាក់ កំពុងជិះម៉ូតូសុខៗ ស្រាប់តែរថយន្តបង្ករេចង្កូតមកបុកយ៉ាងពេញទំហឹង។ គ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់នេះបានកើតឡើងកាលពីវេលាម៉ោង៦និង៣០នាទី ល្ងាច ថ្ងៃ អង្គារ ៤ រោច ខែ ទុតិយាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៨ លើកំណាត់ផ្លូវឡើសាក់ ចន្លោះបង្គោលគីឡូម៉ែត្រលេខ៨-៩ ត្រង់ផ្លូវចូលទៅក្រុមហ៊ុន ណាំហេង ស្ថិតក្នុងឃុំកុខាំចាន ស្រុកប្រាក់យុទ្ធបាទ ខេត្តសារៈបុរី ប្រទេសថៃ។

ប្រភពព័ត៌មានពីកន្លែងកើតហេតុនោះបានឲ្យដឹងថា មុនពេលកើតហេតុ មានរថយន្តមួយគ្រឿងម៉ាកអុីស៊ុយហ្សុយ ឌីមេក ពណ៌ខ្មៅ ពាក់ស្លាកលេខ ឈៀងរ៉ាយ ២៦១០ បានរេទៅបុកនឹងម៉ូតូមួយគ្រឿងម៉ាក ហុងដាវេវ ធុនសេ១០០ ពាក់ស្លាកលេខ បុរីរ៉ាំ ១៩៤០ បណ្តាលឲ្យអ្នកបើកបរម៉ូតូ និងអ្នករួមដំណើរជាជនជាតិខ្មែរស្លាប់ទាំង២នាក់ ភ្លាមៗនៅនឹងកន្លែងតែម្តង។ បើតាមប្រភពពីអាជ្ញាធរថៃប្រាប់ថា ជនរងគ្រោះទាំង២ ជាពលករខ្មែរ ដែលឆ្លងដែនចូលទៅធ្វើការនៅក្នុងប្រទេសថៃ ដោយស្របច្បាប់ និងត្រូវជាប្តីប្រពន្ធនឹងគ្នាថែមទៀត ប៉ុន្តែពុំមានប្រភពណាមួយអះអាងថា ជាអ្នករស់នៅក្នុងខេត្តណា នៅក្នុងប្រទេសកម្ពុជាឡើយ។ ជនរងគ្រោះទាំងពីរ មានឈ្មោះ ឈៀបម៉ៅ អាយុ៣៧ឆ្នាំ (ជាប្តី) រីឯប្រពន្ធឈ្មោះ ជឿន ចាន់ណែត អាយុ២២ឆ្នាំ។ បច្ចុប្បន្នសមត្ថកិច្ចថៃ បានយកសាកសពទៅតម្កល់ទុក ដើម្បីស្រាវជ្រាវរកក្រុមគ្រួសារសាច់ញាតិ និងបញ្ជូនសពមកកាន់ប្រទេសកម្ពុជាឲ្យក្រុមគ្រួសារយកទៅធ្វើបុណ្យតាមប្រពៃណី ៕ សហការី

## ការបង្រ្កាបអំពើជួញដូរមនុស្សសកម្មជាងមុន

https://wmc.org.kh/ ថ្ងៃពុធ ទី១ ខែសីហា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ មន្ត្រីជាន់ខ្ពស់រាជរដ្ឋាភិបាល និងមន្ត្រីអង្គការក្រៅរដ្ឋាភិបាលអះអាងថា ការបង្ក្រាបអំពើជួញដូរមនុស្សមានសកម្មភាពខ្លាំងខ្លាជាងមុនបានជួយសង្គ្រោះជនរងគ្រោះច្រើនជាងឆ្នាំៗ ដោយសារមានការសហការណ៍ល្អជាមួយរវាងរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល រួមទាំងអ្នកពាក់ព័ន្ធផ្សេងទៀត។

កម្ពុជាជាប់ចំណាត់ថ្នាក់លេខ ២ ឬ Tier 2 បីឆ្នាំ ជាប់ៗគ្នា ក្នុងការទប់ស្កាត់អំពើជួញដូរមនុស្ស ដែលមានន័យថា ការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជាមានស្ថានភាពល្អប្រសើរ។នេះបើតាម របាយការណ៍ក្រសួងការបរទេសអាមេរិកស្តីពី«ការជួញដូរមនុស្សឆ្នាំ ២០១៨»។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ប្រាប់វិទ្យុថា ការទប់ស្កាត់អំពើជួញដូរមនុស្សនៅកម្ពុជាមានស្ថានភាពមិនល្អពេក ហើយក៏មិនអាក្រក់ពេក ប៉ុន្តែរាជរដ្ឋាភិបាលកំពុងនឹងខិតខំប្រឹងប្រែងទប់ស្កាត់អំពើជួញដូរមនុស្សយ៉ាងសកម្ម។ លោកស្រី ជូ ប៊ុនអេង អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស មានប្រសាសន៍ថា ថ្មីនេះអាជ្ញាធរបានបង្ក្រាប់ចាប់ជនជាតិចិនផ្តល់សេវាពពោះជំនួស ដែលជាទំរង់ថ្មីមួយនៃអំពើជួញដូរមនុស្ស។ក្នុងការបង្ក្រាប់នេះ អាជ្ញាធររកឃើញស្ត្រីមានផ្ទៃពោះ ៣៣ នាក់។ បច្ចុប្បន្នជនសង្ស័យទាំងអស់កំពុងឃុំខ្លួននៅក្នុងពន្ធនាគារ។ លោកស្រី ជូ ប៊ុនអេង បញ្ជាក់ថា ក្នុងរយៈពេលឆមាសទី ១ ដើមឆ្នាំ ២០១៨នេះ អាជ្ញាធរបង្ក្រាបអំពើជួញដូរមនុស្សមានការកើនឡើងតិចតួច ប៉ុន្តែការជួញដូរផ្លូវភេទមានការថយចុះ បើធៀននឹងរយៈពេលដូចគ្នានៅឆ្នាំមុន។ លោកស្រី ជូ ប៊ុនអេង អះអាងថា អាជ្ញាធរបង្ក្រាបអំពើជួញដូរមនុស្សមានចំនួន ១៨ ករណី ខណៈដែលឆ្នាំមុន មាន ១៦ករណី បើធៀបទៅនឹងរយៈពេលដូចគ្នា។ ចំពោះការជួញដូរមនុស្សផ្លូវភេទថយចុះពាក់កណ្តាលឆ្នាំនេះ មាន ៤៤ ករណី ខណៈដែលឆ្នាំមុនមាន ៥០ ករណី បើគិតត្រឹមរយៈពេល ៦ ខែដូចគ្នា។

ប្រទេសកម្ពុជាប្រារព្ធទិវា«ពិភពប្រឆាំងអំពើជួញដូរមនុស្សអន្តរជាតិ»នៅថ្ងៃទី ១២ ខែ ធ្នូ ជារាងរាល់ឆ្នាំ។ ប៉ុន្តែប្រទេសមួយចំនួននៅលើពិភពលោកប្រារព្ធមុនកម្ពុជានៅថ្ងៃទី ៣០ ខែ កក្កដា។ អង្គការសង្គមស៊ីវិលធ្វើការងារពាក់ព័ន្ធនឹងការទប់ស្កាត់ការជួញដូរមនុស្សអះអាងថា ការទប់ស្កាត់អំពើជួញដូរមនុស្សនៅពាក់កណ្ដាល់ឆ្នាំនេះ មានភាពសកម្មជាងបណ្ដាឆ្នាំកន្លងមក។ ទោះបីយ៉ាងបញ្ហាជួញដូរមនុស្សនៅកម្ពុជានៅតែមានបញ្ហាប្រឈមនៅឡើយ។

លោក ស្រ៊ន់ ឡង់ដា ប្រធានគម្រោងក្នុងគម្រោងគាំទ្រការទប់ស្កាត់អំពើជួញដូរមនុស្សរបស់អង្គការសម្ព័ន្ធចាប់ដៃ ឲ្យដឹងថា ក្នុងឆមាសទី១ ដើមឆ្នាំ២០១៨នេះ អង្គការសម្ព័ន្ធចាប់ដៃបានសហការណ៍ជាមួយអាជ្ញាធរនិងអ្នកពាក់ព័ន្ធជួយសង្គ្រោះស្ត្រីត្រូវបានមេខ្យល់បោកបញ្ឆោទយកទៅលក់ ដើម្បីរៀបការជាមួយជនជាតិចិនដោយបង្ខំ។ ជនរងគ្រោះជាស្ត្រីច្រើនទៀតត្រូវបានគេជួញដូរទៅបម្រើការងារជាជំនួយការតាមផ្ទះនៅប្រទេសម៉ាឡេស៊ីជាដើម។ លោក ស្រ៊ន់ ឡង់ដា បញ្ជាក់ថា ក្នុងរយៈពេល ៦ ខែ ដើមឆ្នាំនេះ អង្គការលោកជួយស្ត្រីរងគ្រោះនៃការជួញដូរត្រឡប់មកស្រុកកំណើតមាន ៧២ ករណី។ក្នុងនោះស្ត្រីរងគ្រោះ ៦០ នាក់ ត្រូវបានរៀបការដោយបង្ខំជាមួយបុរសជនជាតិចិន ហើយជនរងគ្រោះ ៦នាក់ជួយសង្គ្រោះពីម៉ាឡេស៊ី និងអារ៉ាប់ប៊ីសាអូឌីត ម្នាក់។ លោកថាអំពើជួញដូរក្នុងស្រុកអង្គការសម្ព័ន្ធចាប់ដៃជួយក្មេងស្រីអាយុក្រោម១៨ឆ្នាំ ៤នាក់ ត្រូវបានគេបម្រុងនឹងលក់នៅតាមហាងការ៉ាអូខេ និងក្លឹមសម្បាន្ត។

បើតាមកម្មវិធីប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៅកម្ពុជានៃអង្គការ USAID ដែលធ្វើការជាមួយអ្នករស់រានមានជីវិតនៃអំពើជួញដូរមនុស្ស បាននឹងកំពុងជួយកសាងជីវិតជាថ្មីដល់ពួកគេចំនួន ២៨៩៧ នាក់ ចាប់តាំងពីឆ្នាំ ២០១៥ រហូតមកដល់បច្ចុប្បន្ននេះ។

បើតាមលោកស្រី ជូ ប៊ុនអេង ឲ្យដឹងថា នៅឆ្នាំ ២០១៧ អាជ្ញាធរបង្ក្រាប់អំពើជួញដូរមនុស្ស ៤៨ ករណី បើធៀបនឹងឆ្នាំ ២០១៦ មាន ២៧ករណី ហើយការបង្ក្រាប់អំពើជួញដូរផ្លូវភេទមានចំនួន ១១១ ករណីនៅឆ្នាំ ២០១៧ ខណៈដែលឆ្នាំ ២០១៦ មាន ៦៥ ករណី៕

## ករណីរំលោភផ្លូវភេទលើស្ត្រី រយៈពេល ៦ខែ ឆ្នាំ២០១៨ មានការកើនឡើង

https://wmc.org.kh/ ថ្ងៃសុក្រ ទី២៧ ខែកក្កដា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ ករណីរំលោភផ្លូវភេទលើស្ត្រី បានកើនឡើងក្នុងរយៈពេល ៦ខែ ឆ្នាំ២០១៨។ មន្ត្រី សមាគមអាដហុក ទទួលបន្ទុកផ្នែកស្ត្រី និងកុមារ មើលឃើញថា មូលហេតុដែលនាំឲ្យអំពើរំលោភលើស្ត្រី នៅតែបន្តកើតមាន កត្តាចម្បងគឺបណ្ដាលមកពីភាពសម្បូរបែបនៃប្រព័ន្ធបច្ចេកវិទ្យា។

លោកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រី និងកុមារ របស់សមាគមការពារសិទ្ធិមនុស្ស អាដហុក មានប្រសាសន៍ថា រយៈពេល ៦ខែ ក្នុងឆ្នាំ២០១៨នេះ បើយោតាមរបាយការណ៍ ករណីរំលោភសេពសន្ថវៈ របស់ក្រសួងមហាផ្ទៃ បង្ហាញថា មានករណីរំលោភរហូតដល់ជិត ៥០០ករណី បានកើតឡើង ៖«ចំពោះករណីរំលោភយើងឃើញថា តាមរបាយការណ៍ក្រសួងមហាផ្ទៃមានការកើនឡើង នៅក្នុង ៦ខែ ដើមឆ្នាំនេះ មានរហូតដល់ជិត ៥០០ ករណី ហើយខ្ញុំមើលឃើញថា ករណីរំលោភមានការកើនឡើងច្រើនបើប្រៀបធៀប ជាមួយឆ្នាំ២០១៧កន្លងមក»។ លោកស្រី បន្តថា តាមអ្វីដែលលោកស្រី ដែលជាអ្នកធ្វើកិច្ចការដោយផ្ទាល់លើការទប់ស្កាត់ករណីហិង្សាលើស្ត្រី និងកុមារ លោកស្រីមើលថា ការហូរចូល ភាពសម្បូរបែប នៃប្រព័ន្ធបច្ចេកវិទ្យា និងប្រភេទទូរស័ព្ទទំនើប បានធ្វើឲ្យក្រុមបុរស និងកុមារដែលមិនទាន់គ្រប់អាយុ មួយចំនួន ងាយស្រួលដើម្បីស្វែងរក រឿងអាសអាភាស មកមើល នាំឲ្យមានចំណង់ផ្លូវភេទ ៖«នេះគឺជាបញ្ហាចម្បងដែលបណ្ដាលឲ្យមានបញ្ហាការរំលោភហ្នឹងកើតឡើង រហូតដល់យើងឃើញហើយ ថ្មីៗនេះនៅខេត្តបាត់ដំបង រហូតដល់ឪពុកខ្លួនឯងនៅពេលគាត់មើលវិដេអូនេះហើយ គាត់ចាប់រំលោភកូនខ្លួនឯងរហូតដល់ ២នាក់»។ លោកស្រី សុគន្ធា បន្តទៀតថា បញ្ហា នៃការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារីនេះ គឺជារឿងដែលរាជរដ្ឋាភិបាលត្រូវតែយកចិត្តទុកដាក់ និងស្វែករកវិធីសាស្ត្រយ៉ាង ទប់ស្កាត់អ្វី ដែលជាដើមហេតុនាំឲ្យករណីរំលោភនៅតែកើតមាន។ ជាងនេះលោកស្រី បារម្ភថា ស្ត្រី និងកុមារី ត្រូវបានបាត់បង់ឱកាសដើម្បីបន្តការ

សិក្សា និងការចេញទៅខាងក្រៅដើម្បីប្រកបរបរចិញ្ចឹមជីវិតផ្សេងៗ ព្រោះតែភូមិ ឃុំ របស់ពួកគេ គ្មានសុវត្ថិភាព ៖« បញ្ហាដែលវាកើតឡើងភាគច្រើននៅតំបន់ដាច់ស្រយាល អញ្ចឹងធ្វើឲ្យអ្នកនៅជនបទដាច់ស្រយាល ពិបាកឲ្យកូនទៅរៀន ពិបាកឲ្យកូនទៅប្រកបមុខរបរ ដូចជាឃ្វាលគោ ឬក៏ទៅច្រូតកាត់អីជាដើម»។ ករណីរំលោភនេះ មិនមែនជារឿងថ្មីនោះទេ ពោលគឺវាបានកើតឡើងស្ទើរជារៀងរាល់ថ្ងៃ ប្រសិនបើយើងងាកទៅមើលលើបណ្ដាញសង្គម និងការសែតដែលបានបោះពុម្ពផ្សាយប្រចាំថ្ងៃ។ បញ្ហា នៃការរំលោភនេះ គឺជាក្ដីកង្វល់របស់រាជរដ្ឋាភិបាល ក៏ដូចជា សង្គមស៊ីវិល និងពិសេសក្រុមគ្រួសារ និងស្ត្រីខ្លួនឯងផ្ទាល់។

រាជរដ្ឋាភិបាល នាពេលកន្លងមកបានដាក់បញ្ជាឲ្យមន្ត្រីក្រោមឱវាទ នៅមូលដ្ឋានទាំងអស់ចុះអប់រំពីករណីរំលោភផ្លូវភេទនេះ ដើម្បីធ្វើយ៉ាងណាទប់ស្កាត់ និងលុបបំបាត់ឲ្យបាន បំណងធានាឲ្យបានភាពសុខសាន្ត និងសុវត្ថិភាពស្ត្រីនៅតាមភូមិ ឃុំ។ ក៏ប៉ុន្តែករណីរំលោភនៅតែកើតមាន ពីមួយថ្ងៃ ទៅមួយថ្ងៃ ជាអន្លើ។

កាលពីដើមខែកក្កដា ឆ្នាំ២០១៨ កន្លងទៅនេះ របាយការណ៍បឋមមួយ ស្ដីអំពី *"ហិង្សាផ្លូវភេទលើស្ត្រី និងកុមារី"* របស់សម្ព័ន្ធបងប្អូនស្រី ដែលជាបណ្ដុំអង្គការសង្គមស៊ីវិលចំនួន៤ ធ្វើការងារលើកស្ទួយសិទ្ធិស្ត្រី បានបង្ហាញថា ក្នុងមួយថ្ងៃមានករណីហិង្សាផ្លូវភេទកើតឡើងយ៉ាងតិច ១ករណី ហើយវាបានកើតឡើងទៅលើអនិតិជនភាគច្រើន ក្រោមអាយុ ១៥ឆ្នាំ។ បន្ថែមពីនេះជនល្មើស សុទ្ធតែធ្លាប់មានទំនាក់ទំនងជាមួយជនរងគ្រោះ ដែលពួកគេ ជាសាច់ញាតិ មិត្តភក្តិ ឬក៏ជាគូសង្សាជាដើម។ ស្ត្រី និងកុមារី ត្រូវបានរងហិង្សាផ្លូវភេទរហូតដល់ ១៩៩ករណី ក្នុងរយៈពេល ៦ខែ ចាប់ពីខែតុលា ឆ្នាំ២០១៧ រហូតដល់ខែមីនា ឆ្នាំ២០១៨ ។ សម្ព័ន្ធបងប្អូនស្រី បង្ហាញក្ដីព្រួយបារម្ភថា ករណីរំលោភផ្លូវភេទនេះ នឹងក្លាយជារឿងមិនល្អ ហើយក៏នឹងជះឥទ្ធិពលអាក្រក់ដល់អនាគត នឹងការចងចាំរបស់ក្មេងស្រីផងដែរ។

ទាក់ទិនរឿងនេះ លោកស្រី ធីតា ឃឹះ នាយិកាអង្គការសីលការ ផ្ដល់ជាអនុសាសន៍ថា ដើម្បីលុបបំបាត់ និងទប់ស្កាត់ ករណីរំលោភសេពសន្ថវៈនេះ រដ្ឋាភិបាលគួរតែអប់រំសង្គម ឲ្យផ្ដល់ការគោរពសិទ្ធិស្ត្រី និងដឹងថា អំពើរំលោភនេះ គឺខុសនឹងច្បាប់ ហើយជនប្រព្រឹត្តត្រូវតែមានទោស ៖«*ត្រូវអប់រំទៅដល់សង្គម ដើម្បីឲ្យមានការគោរពទៅដល់ស្ត្រី ហើយដឹងថា នៅពេលដែលមានការរំលោភ វាមានការប៉ះពាល់ខ្លាំងទៅដល់ស្ថិតអារម្មណ៍របស់ក្មេងស្រី ហើយវាប៉ះពាល់សតិអារម្មណ៍នេះពេញមួយជីវិតរបស់ស្ត្រី*»។ ក្រៅតែពីការចង់ឃើញយន្តការអប់រំសង្គម ពីការលើកកម្ពស់សិទ្ធិស្ត្រី លោកស្រី នៅចង់ឃើញការរឹតបន្តឹងការអនុវត្តច្បាប់ ក្នុងការផ្ដន្ទាទោសជនល្មើស ឲ្យបានធ្ងន់ធ្ងរថែមទៀត។ ជាងនេះលោកស្រី សំណូមពរ ដល់ជនរងគ្រោះ ឬក៏ក្រុមគ្រួសារ ត្រូវតែផ្ដល់ព័ត៌មានដល់អាជ្ញាធរ បើមានករណីរំលោភផ្លូវភេទកើតឡើង គឺមិនត្រូវលាក់បាំងព័ត៌មាននោះទេ។

សូមជម្រាបថា អំពើរំលោភផ្លូវភេទ គឺជាអំពើដែលខុសនឹងច្បាប់។ យោងតាមច្បាប់ស្ដីពីការរំលោភបំពានផ្លូវភេទ ត្រង់មាត្រា ៣៩ បានចែងថា ជនដែលប្រព្រឹត្តការចាប់ ឬ បង្ខំរំលោភផ្លូវភេទ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ពី ៥ឆ្នាំ ទៅដល់ ១០ឆ្នាំ។ លើសពីនេះ ជនប្រព្រឹត្ត ការចាប់រំលោភ ហើយសម្លាប់ ដោយគ្មានចេតនា នៅក្នុងច្បាប់ត្រង់មាត្រា ២៤៤ បានចែងថា ត្រូវផន្ទាទោសជននោះដាក់ពន្ធនាគារ ពី ១៥ ទៅ ៣០ឆ្នាំ តែចំពោះករណីរំលោភសម្លាប់ដោយចេតនា ជនប្រព្រឹត្តត្រូវផ្ដន្ទាទោស ដាក់គុកអស់មួយជីវិត ស្របទៅតាមមាត្រា ២០៥ ។ ដោយឡែកចំពោះករណីបៀតបៀនកេរ្តិ៍ភេទ ច្បាប់បានចែងថា ត្រូវផ្ដន្ទាទោសពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២ ទៅ ៦ លានរៀល ដែលមានចែងក្នុងមាត្រា ២៤៦៕

# ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៨

## ពលរដ្ឋខ្មែរ៩នាក់ ត្រូវអគ្គកុងស៊ុលខ្មែរ នៅថៃអន្តរាគមន៍ ឲ្យត្រឡប់មក កម្ពុជាវិញ

https://www.dap-news.com/kh/ ព្រហស្បតិ៍, 02 សីហា ២០១៨ 18:48 ដោយ: ដើមអម្ពិល ID:121

ភ្នំពេញ៖ ស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំខេត្តសាកែវ បានសហប្រតិបត្តិការ និងសហការជាមួយអាជ្ញាធរពាក់ពន្ធ ទាំងភាគីថៃ និងកម្ពុជា នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១៨ បានអន្តរាគមន៍ឲ្យពលរដ្ឋខ្មែរចំនួន៩នាក់ ដែលត្រូវបានអាជ្ញាធរ ថៃចាប់ខ្លួន កាលពីថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០១៨ ពីបទឆ្លងដែនខុសច្បាប់ និងដឹកជញ្ជូនទំនិញរំលោភ កម្មសិទ្ធិបញ្ញាចូលដឹកដីថៃ ដោយខុសច្បាប់ បានវិលត្រឡប់ ទៅជួបជុំគ្រួសារនៅកម្ពុជា វិញ តាមច្រកទ្វារព្រំដែន អន្តរជាតិប៉ោយប៉ែត-ខ្លងលឹក។ នេះបើតាមការផ្សព្វផ្សាយ នៅលើគេហទំព័រ របស់ស្ថានអគ្គកុងស៊ុល កម្ពុជាប្រចាំខេត្តសាកែវ នៅល្ងាចថ្ងៃ២ សីហា៕

## ម្ដាយនិងទារកឆ្លងផុតឧបសគ្គដ៏គ្រោះថ្នាក់កណ្ដាលជលសារលើទឹកដីថៃ

https://www.facebook.com/matemohachunnews/ សារព័ត៌មាន មតិមហាជន ថ្ងៃទី02 សីហា ២០១៨

បន្ទាយមានជ័យ៖ ការសម្រាលកូនមុនពេលកំណត់(មិនទាន់គ្រប់ខែ)បានធ្វើឲ្យស្ត្រីជាពលករខ្មែរម្នាក់ជួបការលំបាក ព្រោះនាងឈឺពោះខ្លាំងត្រូវជិះតាមទូកម៉ាស៊ីនឆ្លងកាត់ផ្ទៃសមុទ្រដាច់កន្ទុយភ្នែកពីកោះមួយនៅខេត្តរ៉ាក់យ៉ង ដើម្បីឡើងគោករកពេទ្យជួយសង្គ្រោះ។ហេតុការណ៍ដ៏កម្រនេះបានកើតឡើងកាលពីវេលាទាបភ្លឺព្រឹកថ្ងៃទី01 សីហា 2018 លើស្ត្រីជាពលករខ្មែរម្នាក់ធ្វើការនៅរីសតមួយលើកោះស្មាច់នៃខេត្តរ៉ាក់យ៉ងប្រទេសថៃ។សាច់ញាតិប្រាប់ថាស្ត្រីឈឺពោះសម្រាលកូននេះទើបតែមានផ្ទៃ៩ខែតែប៉ុណ្ណោះទើបមិនបានប្រុងប្រយ័ត្នជាមុន។ថ្វីត្បិតតែករណីនេះប្រៀបបាននិងការឆ្លងសមុទ្រមិនមែនឆ្លងទន្លេព្រោះតែបានឆ្លងកាត់មហាសាគរដ៏ធំល្វឹងល្វើយហើយទារកក៏អើតចេញមើលពន្លឺថ្ងៃពីផ្ទៃម្ដាយផុតក្បាលទៅហើយនោះប៉ុន្តែបានសម្រាលយ៉ាងមានសុវត្ថិភាពខណៈមកដល់មាត់កំពង់ផែប៉ះចំសមត្ថកិច្ចនិងក្រុមសង្គ្រោះរបស់ថៃជួយទាន់ពេល៕ដោយជីតា

## ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករ បានចុះទៅមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង ដើម្បីសួរសុខទុក្ខពលការិនីឈ្មោះ សេម សម្បត្តិ

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ ថ្ងៃទី02 សីហា ២០១៨

នៅថ្ងៃព្រហស្បតិ៍ ៦រោច ខែទុ.សាឍ ឆ្នាំច សំរិទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ០២ ខែសីហា ឆ្នាំ ២០១៨ ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករ បានចុះទៅមន្ទីរពេទ្យខេត្តរ៉ាក់យ៉ង ដើម្បីសួរសុខទុក្ខពលករឈ្មោះ សេម សម្បត្តិ ។ពលកររូបនេះបានធ្វើដំណើរពីកន្លែងធ្វើការរបស់ខ្លួននៅលើកោះសាម៉េត ខេត្តរ៉ាក់យ៉ង តាមរយៈនាវាលឿន ក្នុងគោលបំណងមកមន្ទីរពេទ្យក្នុងទីរួមខេត្តរ៉ាក់យ៉ង ដើម្បីសម្រាលកូន ប៉ុន្តែមិនទាន់មកដល់មន្ទីរពេទ្យផង ពលករបានសម្រាលកូននៅតាមផ្លូវតែម្តង ទើបតែកុងទូកបានទាក់ទងក្រុមមូលនិធិ ដើម្បីរងចាំជួយសម្រួលបញ្ជូនទៅមន្ទីរពេទ្យ។ បច្ចុប្បន្នទាំងម្តាយ និងទារក(ភេទប្រុស)មានសុខភាពល្អប្រក្រតី និងអាចចេញពីមន្ទីរពេទ្យបានក្នុងរយៈពេល០១-០២ថ្ងៃខាងមុខនេះ។ ជាមួយគ្នានេះដែរ ក្រុមការងារក៏បានជួយឧបត្ថម្ភនូវថវិកាមួយចំនួនផងដែរ។

## ក្មេងអូសរទេះនៅតែជាបញ្ហាចោទមិនអាចកែប្រែបានបើទោះជាច្រកទ្វារតំបន់ក្លាយទៅជាច្រកអន្តរជាតិ

https://www.facebook.com/matemohachunnews/ សារព័ត៌មាន មតិមហាជន ថ្ងៃទី02 សីហា ២០១៨

បាត់ដំបង៖ ត្បិតតែច្រកទ្វារតំបន់គីឡូ13(ភ្នំដី)ក្នុងស្រុកសំពៅលូនខេត្តបាត់ដំបងត្រូវបានរាជរដ្ឋាភិបាលនៃប្រទេសទាំង2កម្ពុជាថៃសម្រេចទៅជាច្រកទ្វារអន្តរជាតិទៅហើយក្តីប៉ុន្តែក្មេងៗអូសរទេះនៅតែជាបញ្ហាចោទព្រោះបន្តកើតមានព្រោងព្រៀតនៅឡើយ។ គេមិនដឹងថាបណ្តាលមកពីមូលហេតុអ្វីនោះទេប៉ុន្តែប្រភពជាច្រើនបានលើកឡើងថាករណីក្មេងអូសរទេះនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតត្រូវបានលុបបំបាត់ទាំងស្រុង ដោយគណៈកម្មការមួយនៃរដ្ឋសភានាពេលកន្លងមកបានចុះត្រួតពិនិត្យ និងណែនាំដល់ស្ថាប័នជំនាញពាក់ព័ន្ធឲ្យទប់ស្កាត់។ សង្ឃឹមថាក្រសួងជំនាញ និងមានវិធានការលើបញ្ហានេះដើម្បីឈានទៅលុបបំបាត់ការប្រើកំលាំងពលកម្មលើកុមារជៀសវៀងវងការរិៈគន់បន្តទៀត៕ដោយធីតា

# ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៨

## ក្រសួងការងារបញ្ចេញឈ្មោះក្រុមហ៊ុនដែលបញ្ជូនពលករខ្មែរទៅបរទេស ស្របច្បាប់

http://kleykley.sabay.com.kh/ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៨ ម៉ោង ១០:៥៧

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កាលពីថ្ងៃទី២ សីហាកន្លងទៅ បានបញ្ចេញឈ្មោះក្រុមហ៊ុនឯកជន ដែលទទួលបានការអនុញ្ញាតឱ្យធ្វើការជ្រើសរើស បណ្ដុះបណ្ដាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរ ទៅធ្វើការនៅតាមបណ្ដាប្រទេសមួយចំនួនដោយស្របច្បាប់ ដូចជា គូវ៉ែត ម៉ាឡេស៊ី ថៃ សិង្ហបុរី កាតា ជប៉ុន តំបន់រដ្ឋបាលពិសេសហុងកុង និងអារ៉ាប៊ីសាអូឌីត ក្រសួងបញ្ជាក់ថា រាល់ក្រុមហ៊ុនណា ដែលពុំមានឈ្មោះក្នុងបញ្ជីខាងក្រោមនេះទេ គឺចាត់ទុកថាជាក្រុមហ៊ុនខុសច្បាប់ ដោយក្រសួងបានអំពាវនាវឲ្យសាធារណជន រាយការណ៍ជាបន្ទាន់ទៅទូរសព្ទលេខ ០២៣ ៨៨០ ៤៧៤ និងទំនាក់ទំនងមន្ទីរការងារទាំង២៥ រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ។

## នាំនាងៗទៅធ្វើការនៅម៉ាឡេស៊ី តាមពិតទៅបំរើតណ្ហាខ្លួន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៨ ម៉ោង ១៧:០៦ យ៉ាន់ ចាន់ថេត

ខេត្តត្បូងឃ្មុំ ៖ បុរសពោះម៉ាយប្រពន្ធ២ម្នាក់ត្រូវសមត្ថកិច្ចនាំខ្លួនបញ្ជូនទៅតំណាងអយ្យការអមសាលាដំបូងខេត្តនាព្រឹកថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨ ដោយចោទប្រកាន់នាំពលករចេញទៅធ្វើការនៅប្រទេសម៉ាឡេស៊ីមិនស្របច្បាប់ជាមួយនោះបានកុហកថា យកកូនស្រីគេទៅធ្វើការតាមពិតយកទៅដើម្បីបំពេញចំណង់តណ្ហារបស់ខ្លួនទៅវិញ ។

លោកវរសេនីយ៍ត្រី សេង មុិ អធិការរងនគរបាលស្រុកត្បូងឃ្មុំប្រាប់ថា ជនសង្ស័យខាងលើឈ្មោះ ជូ ចំរើន ហៅវណ្ណា អាយុ៥៥ឆ្នាំ ជាបុរសពោះម៉ាយមានប្រពន្ធ២ មានទីលំនៅភូមិព្រៃកពាម ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ។ លោកអធិការបន្តថា កាលពីម៉ោង៨ព្រឹក ថ្ងៃទី៣ សីហា កម្លាំងជំនាញបានទទួលពាក្យបណ្ដឹងរបស់ប្រជាពលរដ្ឋខ្មែរអ៊ិស្លាមនៅភូមិឈើទាលទី២ ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ បានប្ដឹងពីបុរសពោះម៉ាយខាងលើដោយចោទប្រកាន់នាំពលករចេញមិនស្របច្បាប់មានគោលដៅ។ ក្រោយមកលោកបានបញ្ជាពីលោកអធិការនគរបាលស្រុក និងលោកស្នងការនគរបាលខេត្តឲ្យចាត់វិធានការស្រាវជ្រាវបន្ទាន់ ។

លោកអធិការរំលឹកថា នៅអំឡុងខែកក្កដា ២០១៧កន្លងទៅ ម៉ោង៧ព្រឹកបុរសសង្ស័យខាងលើបានមកជួបឪពុកម្ដាយជនរងគ្រោះនិយាយបញ្ចុះបញ្ចូលឲ្យកូនស្រីច្បងអាយុ២៨ឆ្នាំទៅធ្វើការនៅម៉ាឡេស៊ី ។ ហេតុតែទុកចិត្តនោះក៏ព្រមឲ្យកូនស្រីចេញទៅតាមរយៈមេខ្យល់រូបនេះ ដោយរំពឹងថានឹងបានលុយផ្ញើឲ្យមកគ្រួសារដោះស្រាយ

ជីវភាព។ លុះខែកុម្ភៈ ២០១៨ បុរសនេះត្រឡប់មកផ្ទះប្រាប់ឪពុកម្ដាយជនរងគ្រោះថា កូនស្រីដែលចេញទៅធ្វើការនៅម៉ាឡេស៊ីនោះសុខសប្បាយទេកុំឲ្យព្រួយបារម្ភអី ។ ហើយក៏និយាយសុំយកកូនស្រីទី២អាយុ១៨ឆ្នាំនោះចេញទៅបន្តទៀត និងបានយល់ព្រមឲ្យទៅធ្វើការ ។

លោកអធិការបន្ថែមថា រហូតមកដល់ខែមេសា ឆ្នាំ២០១៨ ឪពុកម្ដាយក៏ទទួលដំណឹងពីកូនស្រីតាមទូរស័ព្ទមកថា «ចាប់តាំងពីពេលដែលចេញដល់ម៉ាឡេស៊ីត្រូវបុរសឈ្មោះវណ្ណា មិនឲ្យចេញទៅណានោះទេ ថែមទាំងវាយធ្វើបាបលើរាងកាយ និងបង្ខំរួមផ្លូវភេទថែមទៀត និងថាយកពីរនាក់បងប្អូនធ្វើប្រពន្ធ ។ មិនតែប៉ុណ្ណោះបានយកទូរស័ព្ទមិនឲ្យនិយាយមកលេងផ្ទះ សួរសុខទុក្ខឪពុកម្ដាយ ព្រមទាំងចាប់កោសក់ក្បាល ។ លោកអធិការបញ្ជាក់ថា បុរសមេខ្យល់នេះត្រូវបានឃាត់ខ្លួននៅល្ងាចថ្ងៃទី០៣ សីហា ២០១៨ ចោទប្រកាន់នាំពលករចេញមិនស្របច្បាប់ដោយមានគោលដៅ ។ ហើយពីរនាក់បងប្អូនរងគ្រោះនោះកំពុងតែស្ថិតនៅប្រទេសម៉ាឡេស៊ី ដែលអង្គការមួយកំពុងតែអន្តរាគមន៍ ដើម្បីនាំត្រឡប់មកស្រុកកំណើតវិញហើយ ៕

## បាត់ខ្លួន3ថ្ងៃយុវតីម្នាក់រួចផុតពីការបង្ខាំងទុករបស់ឧក្រិដ្ឋជន

https://www.facebook.com/matemohachunnews/ សារព័ត៌មានមតិមហាជន ថ្ងៃទី០៦ សីហា ឆ្នាំ២០១៨

ភ្នំពេញ៖យុវតីជាសិស្សនៃវិទ្យាល័យទួលអំពិលម្នាក់ត្រូវបានជនមិនស្គាល់មុខចាប់ញាត់រថយន្តដឹកយកទៅបង្ខាំងទុកនៅភូមិគ្រិះមួយកន្លែងមិនចាំទីតាំងកាលពី3ថ្ងៃមុន។ បើតាមការរៀបរាប់ពីឪពុកបង្កើតជនរងគ្រោះបានបង្ហើបអោយដឹងថា កូនស្រីរបស់គាត់មានឈ្មោះស៊ុមណារិនអាយុ១៨ឆ្នាំ ជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យទួលអំពិលស្នាក់នៅភូមិ៣មសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញបានចេញពីផ្ទះជិះម៉ូតូមួយគ្រឿងម៉ាកសេ១២៥ សេរីឆ្នាំ២០១៣ពណ៌ខ្មៅពាក់ស្លាកលេខភ្នំពេញ1BO. 9927ទៅរៀនគួរកាលពីថ្ងៃទី៣ខែសីហាឆ្នាំ២០១៨នៅវេលាម៉ោង៣និង០០នាទីរសៀលមិនឃើញវិលត្រឡប់មកផ្ទះវិញ។ គាត់បន្តថាលុះវេលាម៉ោង១១ថ្ងៃត្រង់ថ្ងៃទី៤ខែសីហាក៏បានទទួលទូរសព្ទ័ពីកូនស្រីគាត់និយាយបានតែ២ទៅ៣ម៉ាត់ស្រែកអោយគាត់ជួយ ស្រាប់តែទូរសព្ទ័បានកាត់ផ្ដាច់ប្រពន្ធ័តែទៅវិញលែងចូល។ហើយរូបគាត់ក៏បានទៅដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលព្រៃសនិងអាវុធហត្ថខណ្ឌចំការមនអោយជួយអន្តរាគមន៏។ ស្រាប់តែនៅវេលាម៉ោង៦យប់ថ្ងៃទី៥ ខែសីហាឆ្នាំ២០១៨ រូបគាត់ក៏បានទទួលទូរសព្ទ័ពេទ៏ស្រាប់តែឮសម្លេងកូនស្រីតេមកថាជាលើកទី2អោយគាត់ទៅទទួលនាងនៅប៉ុស្តិ៍នគរបាលបឹងកេងកង២រូបគាត់មានអារម្មណ៏ត្រេកអរយ៉ាងខ្លាំងហើយក៏បានចេញទៅដឹកកូនស្រីតាមការណាត់យកត្រលប់ទៅផ្ទះវិញ។ខណៈពេលបានជួបកូនស្រីគាត់នាងមានសភាពទន់ខ្សោយ និងនិយាយលែងចង់រួចទៅហើយដោយមានអាការៈអស់កំលាំងទន់ខ្សោយសូម្បីអង្គុយស្ទើតែមិនចង់កើត។ពេលដែលគាត់សួថាមានរឿងអីកើតឡើងយុវតីរងគ្រោះបានឆ្លើយថានាងត្រូវជនមិនស្គាល់មុខចាប់ញាត់ចូលរថយន្តហើយយកទៅបង្ខាំងទុកក្នុងផ្ទះមួយកន្លែងដែលនាងមិនចាំ ឬសហគាល់នៅខណ្ឌចំការមនហើយក៏មានយុវតីជាង១០នាក់ទៀតកំពុងតែត្រូវបានគេបង្ខាំងទុកជាមួយ និងនាងនៅទីនោះដែរ។ដោយយុវតីខាងលើនេះមានសំណាងបានរត់គេចផុតចេញមករួចតែម្នាក់ឯង ហើយក៏បានស្រែកអោយគេជួយ។ ខណៈពេលនេះទាំងកម្លាំងអាវុធហត្ថនិងកម្លាំងនគរបាលកំពុងតែបើកការស្រាវជ្រាវនិងស៊ើបអង្កេតដើម្បីរំដោះក្មេងស្រីចំនួនជាង១០នាក់ទៀតដែលកំពុងតែបង្ខាំងទុកបង្អត់បាយបង្អត់ទឹកនិងស្វែងរកចាប់ឧក្រិដ្ឋជនខាងលើយកទៅផ្តន្ទារទោសតាមផ្លូវច្បាប់នាពេលឆាប់ៗខាងមុខនេះ៕ ដោយភ្នំព្រឹក

# ពលករខ្មែរម្នាក់ និងជនជាតិថៃម្នាក់បានស្លាប់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នៅប្រទេសថៃ

http://nokorwatnews.com/ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៨

ប្រទេសថៃ៖ មនុស្ស២នាក់ម្នាក់ជាពលករខ្មែរ និងម្នាក់ទៀតជនជាតិថៃបានស្លាប់ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍មួយនៅក្នុងប្រទេសថៃខណៈ ដែលភាគីម៉ូតូ ដែលជាជនជាតិថៃ បានបើកបរក្នុងល្បឿនលឿនទៅបុកជាមួយ និងពលករខ្មែរ ដែលកំពុងជិះកង់មិនដឹងខ្លួន ។

យោងតាមរបាយការណ៍ ដែលទទួលបានពីភាគីថៃបានឲ្យដឹងថា ករណីគ្រោះថ្នាក់ចរាចរណ៍នេះបានកើតឡើងនៅវេលាម៉ោង ១១ និង ៤៥ នាទី យប់ ថ្ងៃសៅរ៍ ៨រោច ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៨ លើកំណាត់ផ្លូវ សុខសុវត្តិ ទល់មុខមន្ទីរពេទ្យ ប៉ៅឡូព្រះប្រាក់ដែងក្នុងឃុំ ប៉ាកខ្លងបាងប្លាកុត ស្រុកព្រះសមុទ្រចេតីយ៍ ខេត្តសមុទ្រប្រាកាន ប្រទេសថៃ ។ របាយការណ៍មិនបានបញ្ជាក់ថា ការធ្វើដំណើររបស់ភាគីទាំងពីរ ក្នុងទិសដៅពីណាទៅណានោះឡើយ ដោយគ្រាន់តែបញ្ជាក់ថានៅកន្លែងកើតហេតុគេឃើញមានពលករខ្មែរម្នាក់ ដែលជិះកង់បានដេកស្លាប់នៅកណ្តាលទ្រូងផ្លូវ ឈ្មោះ ពេជ្រ ស៊ីណា ភេទប្រុស អាយុ ៣៩ឆ្នាំ ។ នៅចម្ងាយប្រមាណជាង ១០០ ម៉ែត្រ គេសង្កេតឃើញមានម៉ូតូមួយគ្រឿងម៉ាក យ៉ាម៉ាហា R3 រមូរជាប់ជាមួយ និងកង់មួយគ្រឿង ដោយនៅក្បែរនោះមានជនជាតិថៃម្នាក់ឈ្មោះ វ៉ន វុធ ភេទប្រុស អាយុ១៩ឆ្នាំ រងរបួសធ្ងន់ ដោយដាច់ ក ជើងស្តាំម្ខាង ដោយភ្លាមៗនោះដែរ សមត្ថកិច្ចបានបញ្ជូនចូលទៅក្នុងមន្ទីរពេទ្យ ដែលនៅក្បែរ ប៉ុន្តែអកុសលពួកគេក៏បានស្លាប់នៅពេលនោះដែរ។

សមត្ថកិច្ចបានសន្និដ្ឋានថា អ្នកជិះម៉ូតូជាជនជាតិថៃអាចបើកបរក្នុងល្បឿនលឿនហួសកំណត់ ។ បច្ចុប្បន្នសពពលករខ្មែរ ត្រូវបានសមត្ថកិច្ចស្រាវជ្រាវរកសាច់ញាតិ ដើម្បីបញ្ជូនទៅកាន់ស្រុកកំណើតវិញ ៕វណ្ណា

## ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨

### ក្រសួងការងារថៃប្រកាសថា កំពុងខ្វះខាតពលករនេសាទត្រីចំនួន 42,649 នាក់

https://www.facebook.com/ ទឹកចិត្ត-ពលករ-ឆ្លងដែន ថ្ងៃទី០៦ សីហា ២០១៨

បងប្អូនពលករខ្មែរអ្នកនេសាទត្រី ដែលមានបៃអនុញ្ញាតធ្វើការ របស់បងប្អូនដែលអស់អាយុនៅ ថ្ងៃទី30 ខែ 9 ឆ្នាំ2018នេះ សូមបងប្អូនពលករខ្មែរប្រញ៉ាប់រួសរាន់ទៅត៏អាយុ បៃអនុញ្ញាតធ្វើការនៅក្រសួងការងារថៃ នៅតាមខេត្តដែលបងប្អូនធ្វើការ បងប្អូនអាចទៅតអាយុ បៃអនុញ្ញាតធ្វើការបាន2 ឆ្នាំទៀតដល់ឆ្នាំ2020 ។ សូមបងប្អូនពលករខ្មែរអ្នកនេសាទត្រី សូមបងប្អូនរួសរាន់ឡើង ក្រសួងការងារថៃ បានអនុញ្ញាតឲ្យបងប្អូនទៅតអាយុបៃអនុញ្ញាតធ្វើការ ចាប់ផ្តើមតាំងតែថ្ងៃទី20 ខែ 8 រហូតដល់ថ្ងៃទី30 ខែ 9 ឆ្នាំ2018នេះ។

នៅថ្ងៃនេះដែរក្រសួងការងារថៃបានប្រកាសថា ក្រសួងការងារថៃកំពុងខ្វះខាតពលករនេសាទត្រីចំនួន 42,649នាក់ ។ ក្រសួងការងារថៃបានត្រៀមអញ្ជើញស្ថានទូតទាំង4ប្រទេស ក្នុងនោះមានស្ថានទូតកម្ពុជា ស្ថានទូតភូមា ស្ថានទូតឡាវ ស្ថានទូតវៀតណាម ដើម្បីអោយស្ថានទូតទាំង4ប្រទេសមកពិភាគសារគ្នារឿងខ្វះខាតពលករនេសាទត្រី ដើម្បីពិភាគសារគ្នានាំចូលពលករតាមៈរបប MOU ដើម្បីមកធ្វើការនេសាទត្រី ។

( អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន )

## អធិការខណ្ឌដង្កោ៖ គ្មានករណី ចាប់បង្ខាំង យុវតីសិស្សសាលា ទូលអំពិល ជាង១០នាក់ ដើម្បីចាប់ជំរិតនោះទេ

https://www.dap-news.com/kh/ អង្គារ, 07 សីហា ២០១៨ 10:43 ដោយ: ព្រឿង វិសាល ID:112

ភ្នំពេញ ៖ ក្រោយពីមានការផ្ទុះព័ត៌មាន ករណីជនជាតិចិន ចាប់យុវតី ជាង១០នាក់ ញាត់ចូល ឡាន យកទៅបង្ខាំងទុកក្នុងផ្ទះមួយកន្លែង នៅក្នុង ខណ្ឌចំការមន ដើម្បីជំរិតទារប្រាក់ ប្រតិកម្ម តបនិងករណីនេះ លោក ជឹម ស៊ីថា អធិការខណ្ឌដង្កោ បានបញ្ជាក់ ប្រាប់មជ្ឈមណ្ឌលព័ត៌មាន ដើមអម្ពិល នៅព្រឹកថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៨ នេះថា ពុំមានការចាប់បង្ខាំងនោះទេ គឺជា ព័ត៌មាន មិនពិត គ្រាន់តែជាដំណឹងតៗគ្នា។

លោកបានបញ្ជាក់ទៀតថា ដំណើរក្មេងស្រីនោះ បានចេញពីផ្ទះតាំងពីថ្ងៃទី៣ វេលាម៉ោង៣និង ៣០ មានសម្ភារៈសិក្សា និងសម្លៀកបំពាក់ ហើយមិនឃើញត្រឡប់ចូលផ្ទះវិញនោះទេ ។ ក្រោយពីការបាត់កូនស្រីឪពុកក្មេងស្រីរងគ្រោះបានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ សង្កាត់ ព្រៃសរ ដើម្បីឲ្យជួយរកតែរកមិនឃើញ រហូតដល់ថ្ងៃទី៦ ទើបមានការប្រទះឃើញក្មេងស្រី បានដើរម្នាក់ឯង នៅក្នុងសង្កាត់បឹងកេងកង២។ ក្រោយមកសមត្ថកិច្ចបានសួរនាំក្មេងស្រីនោះ គេបានប្រាប់ថា មានគេចាប់ខ្លួន ។ ភ្លាមៗនោះ សមត្ថកិច្ចបានយកលេខទូរសព្ទឪពុកក្មេងស្រី ដើម្បីខលប្រាប់ឪពុក តែត្រូវបានឪពុកប្រាប់ឲ្យជួយឃាត់ក្មេងស្រីនោះផង ព្រោះក្មេងស្រីបាន ចេញពីផ្ទះច្រើនថ្ងៃមកហើយ។

តែទោះជាយ៉ាងណា លោក អធិការខណ្ឌដង្កោ លើកឡើងថា នេះជាការចាកចេញពីផ្ទះដោយ ខ្លួនឯង ពុំមែនជាករណី ចាប់ជំរិតដើម្បីទារប្រាក់ និងការបង្ខាំងក្មេង១០នាក់ផ្សេងទៀតនោះទេ គឺជារឿងមិនពិត។ បច្ចុប្បន្ន សមត្ថកិច្ច កំពុងធ្វើការស្រាវជ្រាវបន្តទៀត ចំពោះករណីនេះ។

# ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨

## បុរសម្នាក់ត្រូវបានឃុំខ្លួន ក្រោយពីជាប់ចោទអំពើជួញដូរមនុស្ស

https://www.postkhmer.com/ វ៉ន ដារ៉ា 08 August 2018 | 10:02

ខេត្តត្បូងឃ្មុំៈ តុលាការខេត្តកាលពីម្សិលមិញបានសម្រេចឃុំខ្លួនបុរសម្នាក់ជាបណ្ដោះអាសន្ននៅក្នុងពន្ធនាគារ ក្រោយពីជាប់សង្ស័យថាបានបោកបញ្ឆោតនារីខ្មែរអ៊ិស្លាម ២ នាក់យកទៅបង្ខាំងទុកក្នុងផ្ទះឯកជនមួយកន្លែងនៅក្នុងប្រទេសម៉ាឡេស៊ី សម្រាប់បម្រើតណ្ហាផ្លូវភេទដោយប្រើអំពើហិង្សាអស់រយៈពេលប្រមាណ ១ ឆ្នាំមុនពេលដែលនគរបាលរកឃើញកាលពីដើមខែសីហានេះ។

មន្ត្រីនគរបាលខេត្តត្បូងឃ្មុំបានឲ្យដឹងកាលពីម្សិលមិញថាជនសង្ស័យត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ៣ ខែសីហានៅក្នុងផ្ទះស្ថិតក្នុងភូមិព្រែកពាម ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ក្រោយពីត្រឡប់មកពីប្រទេសម៉ាឡេស៊ីដោយបានបោកបញ្ឆោតនារី ២ នាក់នៅក្នុងគ្រួសារតែមួយទៅប្រទេសម៉ាឡេស៊ី។ នារីរងគ្រោះ ២ នាក់កំពុងរស់នៅក្នុងប្រទេសម៉ាឡេស៊ី ខណៈអង្គការក្រៅរដ្ឋាភិបាលមួយកំពុងធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរពាក់ព័ន្ធដើម្បីសង្គ្រោះជនរងគ្រោះមកស្រុកកំណើតវិញ។

លោក ថេង គៀង អ្នកនាំពាក្យតុលាការខេត្តបានប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីម្សិលមិញថា ជនជាប់ចោទឈ្មោះ ជូ ចំរើន ហៅ វណ្ណា ភេទប្រុស អាយុ ៥៥ ឆ្នាំ មានលំនៅក្នុងភូមិព្រែកពាម ឃុំពាមជីលាំង ស្រុកត្បូងឃ្មុំត្រូវបញ្ជូនទៅឃុំឃាំងនៅពន្ធនាគាបណ្ដោះអាសន្នហើយ ដើម្បីរង់ចាំការកាត់ក្ដីបន្ត។ លោក គៀង ថ្លែងថា៖ «យើងបានធ្វើការចោទប្រកាន់ពីបទនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅតាមមាត្រា ៨ និង មាត្រា ១០ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយរឿងនេះក៏បញ្ជូនទៅឲ្យចៅក្រមស៊ើប ចៅក្រមក៏បានឲ្យចាប់បញ្ជូនទៅឃុំខ្លួននៅពន្ធនាគារកាលពីថ្ងៃអាទិត្យទី ៥»។

លោក សេង និ អធិការរងស្រុកត្បូងឃ្មុំឲ្យដឹងថា កាលពីឆ្នាំ ២០១៧ ជនជាប់ចោទបានប្រើល្បិចលួងលោមឪពុកម្តាយនារី ២ នាក់បងប្អូនបង្កើត ឱ្យចេញទៅធ្វើការនៅប្រទេសម៉ាឡេស៊ីដោយចេញមុខជានាវគ៌ការចេញសោហ៊ុយឱ្យទាំងអស់រហូតម្តាយនារីរងគ្រោះយល់ព្រមឲ្យកូនស្រីទាំង ២ នាក់ចេញទៅជាមួយ។ លោកអធិការថ្លែងថា ក្រោយមកជនសង្ស័យនាំនារីរងគ្រោះចេញទៅប្រទេសម៉ាឡេស៊ីរួចបង្ខាំងទុកឲ្យនៅតែក្នុងផ្ទះខ្លួនមិនបានឲ្យទៅធ្វើការងារអ្វីទេ ដោយឲ្យរស់នៅជាមួយគាត់ ដោយទុកយកជាប្តីប្រពន្ធ។ ក្រោយមកជនជាប់ចោទបានប្រើទារុណកម្មវាយដំ និងចាប់កោរសក់ជនរងគ្រោះថែមទៀត ទើបនារីរងគ្រោះរកទូរស័ព្ទ ខលមកប្រាប់ម្តាយនៅស្រុកខ្មែររហូតដល់រឿងរ៉ាវបែកធ្លាយ ម្តាយនារីរងគ្រោះបានទៅដាក់ពាក្យបណ្តឹងក៏ត្រូវសមត្ថកិច្ចស្រាវជ្រាវឃាត់ខ្លួនជនសង្ស័យបានកាលពីវេលាម៉ោង ៨ ព្រឹកថ្ងៃសុក្រ ទី ៣ ខែសីហា ឆ្នាំ ២០១៨ នេះ។ លោក សេង និ ថ្លែងដោយសុំលាក់អត្តសញ្ញាណនារីរងគ្រោះទាំង ២ នាក់ដោយគ្រាន់តែអះអាងថាជនរងគ្រោះម្នាក់អាយុ ២៨ ឆ្នាំ និងម្នាក់ទៀតអាយុ ១៨ ឆ្នាំ។ នារីរងគ្រោះទាំង ២ នាក់ជាជនជាតិខ្មែរ-អ៊ិស្លាម និងត្រូវជាបងប្អូនបង្កើតនឹងគ្នាមានលំនៅក្នុងស្រុកត្បូងឃ្មុំ។

ក្នុងខែកុម្ភៈឆ្នាំ ២០១៨ ឈ្មោះ ជូ ចំរើន បានត្រឡប់មកពីប្រទេសម៉ាឡេស៊ីវិញបានមកជួបឪពុកម្តាយនារីរងគ្រោះម្តងទៀតដោយបានប្រាប់ថាកូនស្រីរបស់គាត់ម្នាក់មុនដែលបានទៅដល់កាលពីខែកក្កដា ២០១៧ សុខសប្បាយទេ ហើយបានលួងលោមសុំយកកូនស្រីម្នាក់ទៀតមានអាយុ ១៨ ឆ្នាំ។ មកដល់ពេលនេះនារីរងគ្រោះទាំង ២ នៅមិនទាន់ត្រឡប់មកដល់ស្រុកខ្មែរវិញនៅឡើយទេ ប៉ុន្តែមានអង្គការក្រៅរដ្ឋាភិបាលមួយបានទាក់ទងទៅស្ថានទូតខ្មែរនៅប្រទេសម៉ាឡេស៊ី និងបានឆ្លើយឆ្លងគ្នាតាមទូរស័ព្ទ ដើម្បីដោះស្រាយបញ្ជូននារីរងគ្រោះត្រឡប់មកស្រុកខ្មែរវិញ៕

## កម្ពុជា-ថៃ រួមគ្នាពង្រឹងទប់ស្កាត់បទល្មើសគ្រឿងញៀន និងបទល្មើសឆ្លងដែនខុសច្បាប់ នៅតាមព្រំដែន

http://www.freshnewsasia.com/index.php/ 2018-08-08

**(ប៉ៃលិន)៖** លោក ផាន់ ចាន់ធុល អភិបាលខេត្តប៉ៃលិន អមដំណើរដោយលោក ធូ ភា អភិបាលរងខេត្តបានដឹកនាំគណៈប្រតិភូអញ្ជើញចូលរួមប្រជុំស្តីពីការបង្ក្រាប និងទប់ស្កាត់គ្រឿងញៀនតាមព្រំដែន (BLO) ជាមួយលោក វីធូរ៉ាត់ ស្រ៊ីណាម អភិបាលខេត្តចាន់បុរី ប្រទេសថៃ នៅការិយាល័យទេសចរណ៍ និងពាណិជ្ជកម្មព្រំដែនកម្ពុជា-ថៃ ផ្សារបានឡែម ដើម្បីរួមគ្នាពង្រឹងទប់ស្កាត់ បទល្មើសគ្រឿងញៀនឆ្លងដែន ការជួញដូរមនុស្ស ជួញដូរអាវុធ និងទំនិញគេចពន្ធតាមព្រំដែនរួមគ្នា។

នៅក្នុងកិច្ចប្រជុំនារសៀលថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨លោក ផាន់ ចាន់ធុល បានលើកឡើងថា កិច្ចសហប្រតិបត្តិការ និងសម្របសម្រួលវិធានការប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយ (BLO) កម្ពុជា-ថៃ ដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីធ្វើកិច្ចសហប្រតិបត្តិការអប់រំផ្សព្វផ្សាយបង្ការទប់ស្កាត់បញ្ហាគ្រឿងញៀន តាមព្រំដែន និងធ្វើការផ្លាស់ប្តូរព័ត៌មាន តាមបន្ទាត់ព្រំដែន រាល់បញ្ហាដែលពាក់ព័ន្ធនឹងការដាំដុះ ការផលិត ការចរាចរណ៍ ការជួញដូរ ការប្រើគ្រឿងញៀន និងការចរាចរណ៍សារជាតុគីមីផ្សំ។ លោកអភិបាលខេត្តប៉ៃលិន ក៏បានសំណូមពរដល់ (BLO) កម្ពុជា-ថៃ ត្រូវតែបង្កើនកិច្ចសហប្រតិបត្តិការគ្នាឲ្យបានកាន់តែល្អ ដើម្បីពង្រឹង និងទប់ស្កាត់បទល្មើសគ្រឿងញៀនឆ្លងដែន និងការជួញដូរមនុស្ស ការជួញដូរអាវុធ ព្រមទាំងទំនិញគេចពន្ធដោយខុសច្បាប់ តាមបន្ទាត់ព្រំដែនឲ្យមានប្រសិទ្ធភាពខ្ពស់ និងបន្តសហប្រតិបត្តិការនូវបញ្ហាមួយចំនួនដូចជា៖ ការប្រើប្រាស់ប័ណ្ណឆ្លងព្រំដែនថ្មី Border Pass ការកសាងស្ពានឆ្លងព្រំដែន បញ្ហាពលករខ្មែរឆ្លងដែនខុសច្បាប់ ព្រមទាំងបទល្មើសឆ្លងដែននានា និងការនាំចេញកសិផល និងការធ្វើពាណិជ្ជកម្មឆ្លងដែនរវាងខេត្តចាន់បុរី-ប៉ៃលិនផងដែរ។

លោក វីធូរ៉ាត់ ស្រ៊ីណាម បានឲ្យដឹងថា កិច្ចសហប្រតិបត្តិការរវាង (BLO) ប្រទេសកម្ពុជា មានខេត្តប៉ៃលិន ខេត្តបាត់ដំបង និងប្រទេសថៃ មានខេត្តចាន់បុរី នាពេលកន្លងមក ដោយបានសហប្រតិបត្តិគ្នាបានល្អ លើការទប់ស្កាត់បទល្មើសគ្រឿងញៀន និងបទល្មើសផ្សេងៗទៀត តាមបន្ទាត់ព្រំដែន រវាងខេត្តជាប់ព្រំដែននៃប្រទេសទាំងពីរ ហើយក៏សំណូមពរដល់ (BLO) ថៃ-កម្ពុជា ត្រូវសហការគ្នា សម្របសម្រួលការងារបន្ថែមជាមួយគម្រោងអនុតំបន់ ស្តីពីភាពជាដៃគូ នៃមន្ត្រីអនុវត្តន៍ច្បាប់ក្នុងតំបន់ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។

សូមបញ្ជាក់ផងដែរថា បើតាមរបាយការណ៍របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានឲ្យដឹងថា បទល្មើសគ្រឿងញៀនដល់ទៅ ៨,១៧៣ករណី ត្រូវសមត្ថកិច្ចបង្ក្រាបបាននៅឆ្នាំ២០១៧ ដោយមានកំណើនដល់ ៩២.៤៨ភាគរយ បើធៀបនឹងតួលេខឆ្នាំ២០១៦ ដែលមានចំនួន ៤,២៤៦ករណី ខណៈដែលមនុស្សដល់ទៅ ១៧,៧៩៥នាក់ ត្រូវបានសមត្ថកិច្ចចាប់ខ្លួនក្នុងអំឡុងប្រតិបត្តិការនោះផងដែរ៕

## ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករបានចុះទៅខេត្តផាធុមថានី ដើម្បីជួបប្រជុំដោះស្រាយបញ្ហាជូនពលករ

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨

ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករបានចុះទៅខេត្តផាធុមថានី ដើម្បីជួបប្រជុំដោះស្រាយបញ្ហាជូនពលករដែលត្រូវបាននិយោជកមិនអនុញ្ញាតអោយរក្សាលិខិតឆ្លងដែន និងឯកសារសម្រាប់ធ្វើការរបស់ពួកគាត់ទុកដោយខ្លួនឯង ដោយមានការចូលរួមពីមន្ទីរការងារខេត្ត និងសមត្ថកិច្ចខេត្ត។ ជាលទ្ធផលនិយោជកយល់ព្រមប្រគល់ឯកសាររបស់ពលករទាំងអស់ អោយពលកររក្សាទុកវិញ បន្ទាប់ពីនិយោជកបានយកឯកសារទាំងអស់នោះទៅបំពេញបែបបទផ្សេងៗរួច។

# ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨

## សាងសង់មណ្ឌលសំចតប៉ោយប៉ែត ត្រៀមជួយជនរងគ្រោះពីការជួញដូរ ពីសំណាក់ប្រទេសថៃ

http://www.cen.com.kh/ August 10, 2018

បន្ទាយមានជ័យ ៖ លោករដ្ឋមន្ត្រី វង សូត បានលើកឡើងថា ការបង្កើតមជ្ឈមណ្ឌលសំចតជួយជនរងគ្រោះ នៅតាមព្រំដែនជាច្រើនកន្លែង នៅតាមច្រកព្រំដែន ពិតជាមានសារសំខាន់ណាស់ និងបានចូលរួម ចំណែកការងារសង្គមកិច្ច ក្នុងការទទួលមើលខុសត្រូវលើជនងាយរងគ្រោះឲ្យកាន់តែប្រសើរ និងមានប្រសិទ្ធភាពជាងមុន ជាពិសេសជាការលើកមុខមាត់រាជរដ្ឋាភិបាល និងប្រទេសកម្ពុជា។

នារសៀលថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨លោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងគណៈប្រតិភូអមដំណើរ ដែលមកពីក្រសួងស្ថាប័នពាក់ព័ន្ធបានចុះ ត្រួតពិនិត្យផ្ទៃដីទំហំ១ហិចតា សាងសង់រួចរាល់ជំហានទី១ មណ្ឌលសំចតប៉ោយប៉ែត ស្ថិតនៅក្នុងភូមិប្រជាធម្ម សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ក្នុងឱកាសនោះ លោក វង សូត បានជំរុញឲ្យក្រុមហ៊ុន កែសម្រួលខ្វះខាតបន្តិចបន្តួច ដើម្បីជួយសង្គ្រោះ ជនរងគ្រោះពីការជួញដូរ ពីសំណាក់ប្រទេសជិតខាងឲ្យបានលឿន និងមានប្រសិទ្ធភាពខ្ពស់ ស្របទៅនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល។ លោករដ្ឋមន្ត្រី បានបញ្ជាក់ថា មណ្ឌលសំចតប៉ោយប៉ែតនេះ នឹងរួចរាល់ជាស្ថាពរ នៅខែខាងមុខនេះ ក្រោយការបើកដំណើរការជាផ្លូវការ មណ្ឌលសំចត ប៉ោយប៉ែតមួយនេះ នឹងចាប់ទទួលយកជនរងគ្រោះ ពីការជួញដូរមនុស្សពីប្រទេសថៃផងដែរ។

បើតាមរបាយការណ៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានឲ្យដឹងថា គិតមកដល់ពេលនេះ នាយកដ្ឋានមួយនេះ បានទទួលជនរងគ្រោះ ពីការធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានាសរុប

ចំនួន១១៧នាក់ ក្នុងនោះស្ត្រី៥៧នាក់ ដែលជនរងគ្រោះទាំងនោះ មកពីប្រទេសម៉ាឡេស៊ី៤១នាក់ ឥណ្ឌូនេស៊ី២០នាក់ ថៃ៤៥នាក់ ចិន៤នាក់ ជប៉ុន៦នាក់ និងប្រទេសសឹង្ហបុរី ១នាក់៕ ដោយ ៖ បញ្ញាស័ក្តិ

## ស្ត្រីនៅតែងាយរងគ្រោះនៃការជួញដូរកម្លាំងពលកម្មនិងផ្លូវភេទ

https://wmc.org.kh/ ថ្ងៃព្រហស្បតិ៍ ទី៩ ខែសីហា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ នារីវ័យក្មេងនៅតាមតំបន់ដាច់ស្រយ៉ាលដែលទទួលព័ត៌មាន និងមានចំណេះដឹងនៅមានកម្រិត នៅតែក្លាយជាក្រុមគោលដៅ ឬជាជនងាយគ្រោះពីការជួញដូរកម្លាំងពលកម្មនិងផ្លូវភេទទាំងក្នុងនិងក្រៅប្រទេស។ ទាក់ទិនរឿងនេះ អ្នកជំនាញ យល់ថា រដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិលមានផលវិបាកក្នុងការកំណត់អត្តសញ្ញាណដើម្បីជួយសង្គ្រោះឱ្យទាន់ពេលវេលាព្រោះក្រុមមេខ្យល់មានល្បិចកលក្នុងភាពថ្មីៗក្នុងការបោកបញ្ឆោតជនរងគ្រោះ។ អង្គការសង្គមស៊ីវិលមានការព្រួយបារម្ភថា ស្ត្រីវ័យក្មេងនៅប្រឈមនឹងការជួញដូរផ្លូវភេទ និងកម្លាំងពលកម្មទៅក្រៅប្រទេស។ ជនរងគ្រោះត្រូវបានជួយសង្គ្រោះច្រើនតែជាជនអន្តោប្រវេសន៍ចំណាក់ស្រុកដោយខុសច្បាប់តាមរយៈមេខ្យល់ ឬ តាមក្រុមហ៊ុននាំពលករគ្មានអាជ្ញាប័ណ្ណស្របច្បាប់ចុះបញ្ជីនៅក្រសួងការងារ។

យោងតាមរបាយការណ៍របស់អង្គការសង្គមស៊ីវិលចំនួនពីរដែលធ្វើការពាក់ព័ន្ធនឹងការទប់ស្កាត់អំពើជួញដូរមនុស្ស បានបង្ហាញថា គេបានជួយសង្គ្រោះជនរងគ្រោះ និងធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើតវិញជិត១០០ករណីក្នុងឆមាសទី១ ដើមឆ្នាំនេះ។ អ្នកស្រី ធន សុគន្ធា ប្រធានផ្នែកស្ត្រីនិងកុមារនៃអង្គការសមាគមអាដហុកមានប្រសាសន៍ថា ក្នុងរយៈពេល៦ខែដើមឆ្នាំ ២០១៨ អង្គការអាដហុកបានជួយសង្គ្រោះជនរងគ្រោះនៃអំពើជួញដូរមនុស្សនៅប្រទេសចិន ម៉ាឡេស៊ី ថៃ និងអារ៉ាប៊ីសាអូឌីតសរុប ៧៩ នាក់ ដែលមាន២៧ ករណី។ក្នុងនោះស្ត្រី ៤០ នាក់ និងបុរស ៣៩ នាក់។ អ្នកស្រី សុគន្ធា បន្ថែមថា ក្នុងចំណោម ២៧ ករណីនេះ ជនល្មើសពីរនាក់ត្រូវបានតុលាការផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ។ ទោះបីយ៉ាងណា អ្នកស្រី យល់ថា ជនល្មើស ឬ មេខ្យល់មិនខ្លាចរអានឹងច្បាប់ព្រោះតែបញ្ហានិទណ្ឌភាព។

ជនរងគ្រោះស្ត្រីនិងកុមារ ៩៩ ភាគរយ ត្រូវបានគេងប្រវ័ញ្ចកម្លាំងពលកម្មនៅក្នុងឧស្សាហកម្មផ្លូវភេទ ហើយ ៥៨ ភាគរយ ក្នុងវិស័យផ្សេងទៀត។ នេះបើតាមរបាយការណ៍អង្គការពលកម្មអន្តរជាតិ(ILO)។ ក្នុងរបាយការណ៍របស់អង្គការសម្ព័ន្ធចាប់ដៃនៅឆមាសទី១ដើមឆ្នាំនេះ បានជួយសង្គ្រោះជនរងគ្រោះនិងមាតុភូមិនិវត្តន៍មកកម្ពុជាមាន ៧២ ករណី។ ក្នុងចំណោមនោះស្ត្រីរងគ្រោះ ៦០ ករណី ត្រូវបានចាញ់បោកមេខ្យល់យកទៅលក់ ដើម្បីរៀបការដោយបង្ខំជាមួយជនជាតិចិន។ ហើយជនរងគ្រោះ ៦ នាក់ ត្រូវបានគេលក់ទៅម៉ាឡេស៊ី និងម្នាក់នៅអារ៉ាប់ប៊ីសាអូឌីត។

លោក ស្រ៊ន់ ឡង់ដា ប្រធានគម្រោងក្នុងគម្រោងគាំទ្រការទប់ស្កាត់អំពើជួញដូរមនុស្សរបស់អង្គការសម្ព័ន្ធចាប់ដៃ អះអាងថា ការជួយសង្គ្រោះជនរងគ្រោះពីប្រទេសចិនមានចំនួនច្រើនករណីដោយសារការសហការណ៍គ្នាល្អរវាងរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងជាមួយអាជ្ញាធរចិនក្នុងការអន្តរាគមន៍ជួយសង្គ្រោះជនអន្តោប្រវេសន៍ខុសច្បាប់ត្រូវបានគេជួញដូរ។ លោកស្រ៊ន់ឡង់ដា៖ *«ផ្លាស់ប្តូរអេរិយាបថគេហៅថាគាត់រាយការណ៍ជូនមកអគ្គស្នងការប៉ូលិសប្រឆាំងការជួញដូរមនុស្សនៅរាជធានីភ្នំពេញ ឯរាជធានីភ្នំពេញគេបានបញ្ជូនសំណុំរឿងទៅក្រសួងការបរទេស ក្រសួងការបរទេសគេរុញសំណុំរឿងទៅស្ថានទូតប្រចាំប្រទេសគោលដៅ ដើម្បីស្រាវជ្រាវករណីមួយនេះ អញ្ចឹងខ្ញុំគិតថាវាវាងបានល្អតែតោះបីយ៉ាងណាក៏ដោយយើងនូវតែមានកម្រិតផ្នែកមួយចំនួនដូចជាការចូលរួមទាក់ទងផ្លូវច្បាប់យើងហាក់ដូចជាពិបាកក្នុងការទទួលសំណងដោយសារមេខ្យល់គាត់មានលុយច្រើនគាត់អាចប្រើប្រាស់លុយការដោះដូរឬបញ្ចុះបញ្ចូលឱ្យជនរងគ្រោះដកពាក្យបណ្តឹងជាដើម»*។

ក្រៅពីការជួញដូរទៅក្រៅប្រទេសជនរងគ្រោះជាស្ត្រីភាគច្រើនត្រូវគេជួញដូរកម្លាំងពលកម្ម និងផ្លូវភេទនៅក្នុងស្រុក។បើតាមរបាយការណ៍បឋមរបស់ក្រសួងមហាផ្ទៃ បង្ហាញថា ក្នុងរយៈពេល ៦ ខែ ដើមឆ្នាំនេះការបង្ក្រាបជួញដូរមនុស្សមានការថយចុះជាងឆ្នាំមុនបន្តិច បើធៀបនឹងរយៈពេលដូចគ្នា។

លោកស្រី ជូ ប៊ុនអេង អនុរដ្ឋលេខាធិការ និងជាអនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ឱ្យដឹងថា អាជ្ញាធរបង្ក្រាបអំពើជួញដូរមនុស្សក្នុងស្រុកមានចំនួន ១៨ ករណី ខណៈដែលឆ្នាំមុនមាន១៦ករណី បើធៀបទៅនឹងរយៈពេលដូចគ្នា។ លោកស្រី បន្ថែមថា ការបង្ក្រាបអំពើជួញដូរផ្លូវភេទបានចំនួន ៤៤ ករណី ខណៈដែលឆ្នាំមុន មាន ៥០ ករណី បើគិតរយៈពេលដូចគ្នា។ លោកស្រី ជូ ប៊ុនអេង៖ *«យើងមើលឃើញភាពសកម្មនៅក្នុងសហប្រតិបត្តិការណ៍របស់សមត្ថកិច្ចយើង ក៏ដូចជាអ្នករងគ្រោះដែលគាត់ធ្វើការរាយការណ៍ឬផ្តល់ព័ត៌មានដើម្បីឱ្យយើងបានទទួលព័ត៌មានច្បាស់លាស់សិនហើយការស៊ើបអង្កេតក្នុងការប្រតិបត្តិទាន់ពេលវេលា។ក្នុងឆ្នាំក៏យើងមានកិច្ចសហការណ៍ជាមួយនឹងប្រទេសថៃ ដើម្បីធ្វើការបង្ក្រាបករណីជួញដូរឆ្លងដែន»។*

បើតាម លោក ស្រ៊ន់ ឡុងដា មន្ត្រីអង្គការសម្ព័ន្ធចាប់ដៃ មានប្រសាសន៍ថា អង្គការលោកជួយសង្គ្រោះក្មេងស្រីអាយុក្រោម១៨ឆ្នាំចំនួន៤នាក់នៅពេលមានការប៉ុនប៉ងលក់នៅតាមហាងការ៉ាអូខេ និងក្លឹមកម្សាន្ត នៅរាជធានីភ្នំពេញ។

តែបើតាមលោកស្រី ជូ ប៊ុនអេង អនុប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ ឲ្យដឹងថា នៅឆ្នាំ ២០១៧ អាជ្ញាធរបង្ក្រាបអំពើជួញដូរមនុស្ស ៤៨ ករណី បើធៀបនឹងឆ្នាំ ២០១៦ មាន ២៧ ករណី ហើយការបង្ក្រាបអំពើជួញដូរផ្លូវភេទមានចំនួន ១១១ ករណីនៅឆ្នាំ ២០១៧ ខណៈដែលឆ្នាំ ២០១៦ មាន ៦៥ ករណី៕

## ដើមខែសីហានេះក្រុមអាជ្ញាធរថៃ ដោះលែងអ្នកទោសខ្មែរជាបន្តបន្ទាប់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៨ ម៉ោង ១៨:៤៨ ឱម សារឿន

ខេត្តឧត្តរមានជ័យ ៖ អ្នកទោសខ្មែរ១០នាក់ត្រូវបានក្រុមអាជ្ញាធរថៃធ្វើការដោះលែងឱ្យមានសេរីភាព ឡើងវិញជាបន្តបន្ទាប់នៅក្នុងដើមខែសីហា ២០១៨នេះ ហើយនាំខ្លួនមកប្រគល់ឱ្យក្រុមអាជ្ញាធរកម្ពុជា នៅមាត់ច្រកទ្វារអន្តរជាតិជាំ(ដែលថៃហៅថាច្រកទ្វារអន្តរជាតិសាង៉ាំ ស្ថិតនៅក្នុងភូមិជាំ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ អ្នកទោសខ្មែរដែលក្រុមអាជ្ញាធរថៃដោះលេងទាំង១០នាក់នោះរួមមាន៖

១-ឈ្មោះ ញ៉ា ញេន ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិថ្នល់ថ្មី ឃុំប្រជាគុ ស្រុកអូរាំងឪ ខេត្តត្បូងឃ្មុំ (ថៃចាប់ខ្លួនថ្ងៃទី៧ មេសា ២០១៤)។ ទី២-ឈ្មោះ សុង ម៉ៅ ភេទប្រុស អាយុ៣៣ឆ្នាំ រស់នៅភូមិស្រឡៅ ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ (ថៃចាប់ខ្លួនថ្ងៃទី២៧ មេសា ២០១៧) ទី៣-ឈ្មោះ ឆេន ស៊ូ ភេទប្រុស អាយុ៣២ឆ្នាំ រស់នៅភូមិគោកក្តុក សង្កាត់កូនគ្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ (ថៃចាប់ខ្លួនថ្ងៃទី៦ កុម្ភៈ ២០១៧) ទី៤-ឈ្មោះ វ៉ា ថុន ភេទស្រី អាយុ៤៨ឆ្នាំ រស់នៅភូមិថ្មី ឃុំល្វា ស្រុកពួក ខេត្តសៀមរាប (ថៃចាប់ខ្លួនថ្ងៃទី៥ សីហា ២០១៨) មូលហេតុធ្វើចំណាកស្រុករកការងារធ្វើ ទី៥-ឈ្មោះ នឿន នាម ភេទប្រុស អាយុ១៥ឆ្នាំ ៦-ឈ្មោះ តាំង ផានិត អាយុ១៥ឆ្នាំ ទាំង២នាក់រស់នៅភូមិកន្ទួត ឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ (ថៃចាប់ខ្លួនថ្ងៃទី៥ សីហា ២០១៨)។ ទី៧-ឈ្មោះ រិត ចាន់រ៉ៃ ភេទប្រុស អាយុ១១ឆ្នាំ ទី៨-ឈ្មោះ រិត សំណាង ភេទប្រុស អាយុ១៣ឆ្នាំ ទី៩-ឈ្មោះ រិត វ៉ាន់ឌី ភេទប្រុស អាយុ១៥ឆ្នាំ រស់នៅភូមិត្រពាំង៣ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ (ថៃចាប់ខ្លួនថ្ងៃទី២០ មិថុនា ២០១៨) និងទី១០-ឈ្មោះ ជីម ម៉ូវ ភេទប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិទួលសាលា ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

មន្ត្រីដែលបម្រើការងារនៅមាត់ច្រកទ្វារអន្តរជាតិដាំបានឱ្យដឹងថា អ្នកទោសខ្មែរ ដែលក្រុមអាជ្ញាធរថៃដោះលែងនាំខ្លួនមកប្រគល់ឱ្យអាជ្ញាធរកម្ពុជាចាប់ពីដើមខែសីហានេះ រហូតមកទល់ថ្ងៃទី៩ សីហា មានចំនួន១០នាក់ ក្នុងនោះម្នាក់ជាស្ត្រីធ្វើចំណាកស្រុករកការងារធ្វើ ដោយ៩នាក់ជាបុរសឆ្លងដែនរុកកាប់ឈើគ្រញូង។ មន្ត្រីដដែលបានបញ្ជាក់ថា ក្រោយពីបានទទួលអ្នកទោសខ្មែរពីក្រុមអាជ្ញាធរថៃ សមត្ថកិច្ចបានធ្វើការអប់រំ នឹងឱ្យវិលត្រឡប់ទៅជួបជុំគ្រួសារវិញនៅក្នុងថ្ងៃដដែល៕

## កងកម្លាំងអាជ្ញាធរថៃមានទាំងទាហាននិងតម្រួតបានចុះត្រួតពិនិត្យពលករធ្វើការសំណង់

https://www.facebook.com/ ទឹកចិត្ត ពលករ ឆ្លងដែន ថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៨

កងកម្លាំងអាជ្ញាធរថៃមានទាំងទាហាន និង តម្រួត បានចុះត្រួតពិនិត្យពលករធ្វើការសំណង់ ដើម្បីត្រួតចាប់ពលករខុសច្បាប់និងត្រួតពិនិត្យគ្រឿងញៀនតាមរាងកាយពលករ ក្នុងកន្លែងធ្វើកាសំណង់នេះមានពលករខ្មែរ ពលករភូមា និងពលករឡាវ ពលករថៃ ក្នុងការចុះត្រួតពិនិត្យនេះបានអោយឃើញថា..មានពលករថៃចំនួន 34នាក់ អាជ្ញាធរថៃបានត្រួតពិនិត្យគ្រឿងញៀននៅតាមរាងកាយពលករថៃ ពលករថៃមានសារគ្រឿងញៀននៅក្នុងរាងកាយចំនួន7នាក់។ ក្នុងការត្រួតពិនិត្យនេះដែរមានពលករកម្ពុជា និង ពលករឡាវ ពលករភូមា ចំនួន95 នាក់ ពលករទាំង95នាក់មានឯកសារស្របច្បាប់ចំនួន81នាក់ ពលករបរទេស14នាក់ទៀតអត់មានឯកសារអ្វីទាំងអស់មកបង្ហាញអាជ្ញាធរថៃ ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនយកទៅតាមផ្លូវច្បាប់ព្រមទាំងចាប់ពលករថៃដែលពាក់ព័ន្ធគ្រឿងញៀនចំនួន7នាក់ ។ ហេតុការណ៍នេះអាជ្ញាធរថៃចុះចាប់នៅថ្ងៃទី9 ខែសីហា ឆ្នាំ2018 នៅត្រង់ចំនុចសួនផត្រីក នៅខេត្តប៉ថុមថានី នៅប្រទេសថៃ ។ (អំពីខ្ញុំ ទឹកចិត្ត ពលករ ឆ្លងដែន)

## ថៃបញ្ជូនសពពលករខ្មែរម្នាក់តាមច្រកប៉ោយប៉ែត

https://www.facebook.com/matemohachunnews/ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៨

បន្ទាយមានជ័យ៖ សពពលករខ្មែរម្នាក់បានស្លាប់លើទឹកដីថៃ ហើយត្រូវគេបញ្ជូនសពត្រឡប់ប្រគល់ឲ្យសាច់ញាតិតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតនៅព្រលប់ថ្ងៃទី៩ សីហា 2018 តែករណីនេះបើមិនជួបសាកសួរសាច់ញាតិប្រាកដជាមិនអាចដឹងថា ជនរងគ្រោះស្លាប់ដោយសារអ្វីឡើយ ព្រោះរបាយការក្នុងឯកសាររបស់អគ្គកុងស៊ុលខ្មែរប្រចាំនៅស្រុកអារញ្ញខេត្តស្រះកែវ ប្រទេសថៃអក្សមើលមិនយល់៕

# ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨

## អស់ទាស់ហ្នឹង, ចិននៅព្រះសីហនុបង្កើតសេវាកម្មពិសេស!

http://www.rasmeinews.com/ August 11, 2018, 11:28 AM

ដោយ: មុនីរ័ត្ន / ភ្នំពេញ: ខិត្តប័ណ្ណរូបស្ត្រីចិនស្រស់ស្អាតស្រាតននលគោក និងមានសរសេរអក្សរចិនអមជាមួយ រួមទាំងដាក់លេខទូរស័ព្ទសម្រាប់ទំនាក់ទំនង ត្រូវបានចែកចាយពេញខេត្តព្រះសីហនុ។ ខេត្តព្រះសីហនុ គឺជាខេត្តមួយដែលជាសំបូរដោយភ្ញៀវទេសចរចិន។ ខិត្តប័ណ្ណនេះ គឺមានក្រុមស្រីៗដើរចែកនៅតាមបន្ទប់ភ្ញៀវដែលស្នាក់នៅសណ្ឋាគារ និងនៅតាមទីសាធារណៈមួយចំនួននៅក្នុងខេត្តព្រះសីហនុ។

លោកឧត្តមសេនីយ៍ទោ ជួន ណារិន ស្នងការនគរបាលខេត្តព្រះសីហនុ បានប្រាប់រស្មីកម្ពុជានៅព្រឹកថ្ងៃទី ១១ ខែសីហា នេះថា ចំពោះករណីនេះ ពិតជាកើតមាននៅខេត្តព្រះសីហនុ ពិតប្រាកដមែន ហើយលោកបានបញ្ជាឲ្យខាងជំនាញធ្វើការស្រាវជ្រាវករណីនេះ។ លោកបានបញ្ជាក់ថា "សមត្ថកិច្ចកំពុងតែឃ្លាំចាំចាប់ និងស្រាវជ្រាវពីព្រោះមានស្រីៗកាន់ខិត្តប័ណ្ណនឹងដើរចែកតាមបន្ទប់ភ្ញៀវ។ យើងកំពុងឲ្យខាងជំនាញស្រាវជ្រាវករណីនេះ ជាពិសេសអាជ្ញាធរមូលដ្ឋាន និងការិយាល័យជួញដូរផ្លូវភេទ ដើម្បីចុះធ្វើការងារនេះ។ យើងមានចំណាត់ការហើយ"។

លោកស្នងការបានបន្តថា រហូតមកដល់ពេលនេះ នៅមិនទាន់មានការឃាត់ខ្លួនអ្នកដើរចែកខិត្តប័ណ្ណនោះនៅឡើយទេ៕ *ល/សរ*

**អាជ្ញាធរខេត្តព្រះសីហនុ កំពុងសិក្សាផ្លូវច្បាប់ ដើម្បីចាត់វិធានការអ្នកចែកខិត្តប័ណ្ណរកស៊ីផ្លូវភេទ**

http://km.rfi.fr/cambodia/ ដោយ សរ ពិសី 13/08/2018

អាជ្ញាធរខេត្តព្រះសីហនុ កំពុងសិក្សាផ្លូវច្បាប់ ដើម្បីចាត់វិធានការអ្នកដែលដើរចែកខិត្តប័ណ្ណរកស៊ីផ្លូវភេទ នៅតាមបណ្តាទីតាំងកំសាន្តនានា ខណៈអាជ្ញាធរទើបបានចាប់ខ្លួនជនជាតិចិនចំនួន៦នាក់ ដែលធ្វើសកម្មភាពចែកខិត្តប័ណ្ណកាលពីយប់ម្សិលមិញនេះ។ វិធានការរបស់អាជ្ញាធរបានធ្វើឡើងបន្ទាប់ពីមានការផ្សព្វផ្សាយជាសាធារណៈស្តីពីការចែកចាយខិតប័ណ្ណ រកស៊ីផ្លូវភេទយ៉ាងកក្រើកកាលពីពេលថ្មីៗនេះ នៅខេត្តព្រះសីហនុ។

ស្នងការនគរបាលខេត្តព្រះសីហនុ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ បានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិ RFI ថា ករណីចែកខិត្តប័ណ្ណរកស៊ីផ្លូវភេទ ដោយជនជាតិចិន នៅក្នុងខេត្តនេះ មិនមែនជារឿងថ្មីនោះទេ។ មិនមែនជាករណីថ្មី ព្រោះថា អាជ្ញាធរខេត្តព្រះសីហនុ ក៏ធ្លាប់ឃាត់ខ្លួន អ្នកដើរចែកខិត្តប័ណ្ណរបៀបនេះ ពីរដងរួចមកហើយ កាលពីដើមឆ្នាំ២០១៨។ ស្នងការនគរបាលខេត្តព្រះសីហនុដដែល បញ្ជាក់ថា កាលពី៦-៧ខែ មុន អាជ្ញាធរក៏បានឃាត់ខ្លួនជនជាតិចិនជាច្រើននាក់ ដែលធ្វើសកម្មភាពចែកខិត្តប័ណ្ណ រកស៊ីផ្លូវភេទនេះ យកទៅអប់រំ និងព្រមាន កុំឱ្យប្រព្រឹត្តទង្វើនេះជាថ្មីទៀត។ យ៉ាងណាក៏ដោយ ចំពោះករណីដែលទើបផ្ទុះឡើង និងត្រូវបានចែកចាយយ៉ាងព្រោងព្រាត តាមបណ្តាញសង្គមហ្វេសប៊ុក កាលពីសប្តាហ៍មុននេះ ត្រូវបាន លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ គូសបញ្ជាក់ថា អាជ្ញាធរកំពុងសិក្សាផ្លូវច្បាប់ ដើម្បីចាត់វិធានការលើបុគ្គល ឬក្រុម ដែលនៅតែផ្តើនធ្វើសកម្មភាពចែកខិត្តប័ណ្ណ រកស៊ីផ្លូវភេទ នៅតាមបឹងហ្គាឡូ ផ្ទះសំណាក់ សណ្ឋាគារ និងកន្លែងកម្សាន្តនានាជាដើម។ ជាសកម្មភាពដែលអាជ្ញាធរខេត្តព្រះសីហនុ ទទួលស្គាល់ថា ធ្វើឱ្យប៉ះពាល់ដល់ប្រពៃណី វប្បធម៌ និងកិត្តិយសខេត្តទេសចរណ៍មួយនេះ។

ក្រៅតែពីកំពុងសិក្សាតាមផ្លូវចំពោះករណីនេះ ស្នងការខេត្តព្រះសីហនុ ក៏បានពង្រាយកម្លាំង នៅតាមទីតាំងសំខាន់នៅក្នុងភូមិសាស្ត្រ ខេត្តព្រះសីហនុ ដើម្បីឃាត់ខ្លួនអ្នកលួចដើរចែកខិត្តប័ណ្ណនេះនៅហ្នឹងកន្លែងផងដែរ។ ជាក់ស្តែង កាលពីយប់ថ្ងៃអាទិត្យ ទី១២ សីហា កម្លាំងសមត្ថកិច្ច ទើបឃាត់ខ្លួនជនជាតិចំនួន ៦នាក់ ដែលប៉ុនប៉ងសៀតខិត្តប័ណ្ណ នៅតាមទ្វារឡាន និងបន្ទប់ផ្ទះសំណាក់ជាដើម។

ព្រមជាមួយគ្នានេះ លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ក៏បានអំពាវនាវដល់មន្ត្រីវប្បធម៌ និងទេសចរណ៍ខេត្ត អ្នកពាក់ព័ន្ធទាំងអស់ ដែលឃើញអ្នកចែកចាយខិត្តប័ណ្ណបែបនេះ ឱ្យជូនដំណឹងដល់អាជ្ញាធរ។ ចំណាត់ការរបស់ស្នងការនគរបាលខេត្តព្រះសីហនុ ត្រូវបានធ្វើឡើងបន្ទាប់ពីមានការចែកចាយជាច្រើនក្នុងបណ្តាញសង្គមហ្វេសប៊ុក កាលពីពេលថ្មីៗកន្លងទៅ ពីរឿងដើរចែកខិត្តប័ណ្ណកន្លែងរកស៊ីផ្លូវភេទ នៅខេត្តគោលដៅទេសចរណ៍មួយនេះ។

សូមបញ្ជាក់ថា ខិត្តប័ណ្ណ ដែលមានការទាក់ទាញភ្ញៀវបុរសៗក្នុងការរកសេវាផ្លូវភេទ ត្រូវបានគេចែកចាយជាសាធារណៈ កាលពីសប្តាហ៍មុន ដែលក្នុងខិត្តប័ណ្ណតូចៗ ប៉ុននាមប័ណ្ណនោះ មានជាក់រូបភាពស្ត្រីចិនអាក្រាតកាយ សរសេរអក្សរចិន និងលេខទូរស័ព្ទទំនាក់ទំនងផងដែរ។

បើតាមរបាយការណ៍ ផ្ញើទៅកាន់លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តព្រះសីហនុលើកឡើងថា កំណើនជនបរទេសដែលភាគច្រើនជាជនជាតិចិនក្នុងខេត្តមានសក្តានុពលមួយនេះកំពុងធ្វើឱ្យមានផលប៉ះពាល់ផ្សេងៗ តាមរយៈការធ្វើសកម្មភាពខុសច្បាប់។ យ៉ាងណាក៏ដោយ ស្ថានទូតចិនប្រចាំកម្ពុជា ធ្លាប់បានបញ្ជាក់ពីជំហររបស់ខ្លួនរួចហើយថា ស្ថានទូតប្រឆាំងដាច់ខាត ចំពោះជនជាតិចិនមួយចំនួនតូចនៅកម្ពុជា ដែលបានប្រព្រឹត្តិអំពើល្មើសច្បាប់ ធ្វើឱ្យប៉ះពាល់មុខមាត់ប្រជាជនចិនទាំងមូល។ ស្ថានទូតចិនប្រចាំនៅកម្ពុជា ស្នើឲ្យស្ថាប័នអនុវត្តន៍

ច្បាប់នៅកម្ពុជា ចាត់វិធានការតឹងរឹងចំពោះប្រជាជនចិន ដែលប្រព្រឹត្តិបទល្មើសទាំងនោះ និងអំពាវនាវឲ្យប្រជាជនចិនទាំងឡាយដែលមកកម្ពុជា រក្សាភាពត្រឹមត្រូវ ស្អាតបាត និងជៀសវាងពីល្បែងស៊ីសង៕

## ក្រុមទាហានឈុតខ្មៅថៃបានចាប់ខ្លួនពលករខ្មែរ២០នាក់ និង១០នាក់ទៀតកំពុងរត់ក្នុងព្រៃករណីឆ្លងចូលទៅកាប់ឈើគ្រញូង

https://chsknews.com/ 2018/08/12/

ថៃ៖ កាលពីថ្ងៃសៅរ៍ ទី១១ ខែសីហា ឆ្នាំ២០១៨ មានករណីឃាត់ខ្លួនពលករខ្មែរ២០នាក់ ក្នុងចំណោម ៣០នាក់ បានធ្វើឡើងក្នុងតំបន់ឧទ្យានជាតិ ថាប់ឡាន ស្ថិតក្នុងឃុំឡាំកៀក ស្រុកខនបុរី ខេត្តនគររាជសីមា ប្រទេសថៃ ដោយមានពលករខ្មែរសរុបចំនួន៣០នាក់ ប៉ុន្តែឃាត់បានតែ២០នាក់ប៉ុណ្ណោះ រីឯ១០នាក់ទៀត បានរត់គេចខ្លួនចូលក្នុងព្រៃបាត់អស់។ យ៉ាងហោចណាស់ពលករខ្មែរ២០នាក់ ក្នុងចំណោម៣០នាក់ ត្រូវបានក្រុមទាហានឈុតខ្មៅថៃចាប់ខ្លួន កាលពីម្សិលមិញ ខណៈពួកគេទាំងអស់គ្នា បានធ្វើដំណើរតាមការដឹកនាំរបស់មេឈ្មួញខ្មែរ-ថៃ ចូលទៅក្នុងតំបន់ហាមឃាត់របស់ថៃ ដើម្បីត្រៀមលក្ខណៈកាប់ឈើគ្រញូងឲ្យពួកគេ។

ពលករខ្មែរម្នាក់ ក្នុងចំណោមពលករទាំងអស់ ដែលត្រូវបានឃាត់ខ្លួន បានសារភាពថា ពួកគេទាំងអស់មានគ្នា៣០នាក់ ដោយត្រូវបានមេឈ្មួញខ្មែរនិងថៃ ដឹកនាំមកកាន់តំបន់នេះ ដោយម្នាក់ៗត្រៀមនូវស្បៀងអាហារ និងឧបករណ៍គ្រប់យ៉ាង ដែលសម្រាប់ប្រើប្រាស់ក្នុងការកាប់ឈើគ្រញូងនៅក្នុងតំបន់នេះ។ ខណៈពួកគេត្រូវបានមេឈ្មួញយកមកទម្លាក់ក្នុងព្រៃនេះ ហើយគេក៏បានចាកចេញទៅបាត់អស់ ដោយទុកឲ្យពួកគេទាំងអស់រៀបចំឧបករណ៍ ដើម្បីត្រៀមកាត់ឈើ ប៉ុន្តែមិនទាន់ទាំងបានកាត់ឈើមួយដុំផង ក៏ត្រូវក្រុមទាហានឈុតខ្មៅថៃឡោមព័ទ្ធនិងចាប់ខ្លួនតែម្តង។ ខាងយើងនៅមិនទាន់ដឹងថាពលករទាំង២០នាក់ ត្រូវបានភាគីថៃបញ្ជូនទៅដល់ណាហើយនោះទេ រីឯពលករ១០នាក់ទៀត ដែលសម្ងំក្នុងព្រៃក៏មិនដឹងថា ហ្នឹងទៅជាយ៉ាងណាដែរ ព្រោះគ្មានស្បៀងបន្តិចទាល់តែសោះ ដោយសារស្បៀងអាហារ និងសម្ភារៈទាំងអស់ ត្រូវបានភាគីថៃប្រមូលគ្មានសល់។

# ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨

## នគរបាលខេត្តព្រះសីហនុ បង្ក្រាបទីតាំងហាងម៉ាស្សា បង្កប់បទល្មើស ប្រព្រឹត្តសច្ចារកម្ម ឃាត់ជនសង្ស័យ៧នាក់

http://cambodiapolice.com/ ម៉ោង 6:56 pm 13 សីហា 2018

**ព្រះសីហនុ៖** លោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុបានដឹកនាំកម្លាំងជំនាញផែននគរបាលព្រហ្មទណ្ឌ សហការជាមួយកម្លាំងអន្តរាគមន៍ពិសេស និងកម្លាំងប៉ុស្តិ៍សង្កាត់៣ និងសម្រប សម្រួលពីលោក កៀង សុន្ទរោ ព្រះរាជអាជ្ញារងនៃសាលាដំបូងខេត្តព្រះសីហនុ បង្ក្រាបទីតាំងហាងម៉ាស្សា ដែលបង្កប់បទល្មើស ប្រព្រឹត្តិសច្ចារកម្ម ( ជួញដូរផ្លូវភេទខុសច្បាប់ )នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង២២ និង ៣០នាទី ស្ថិតនៅចំណុច ហាងម៉ាស្សា ប៉ាយជឹងហាន់កុង ស្ថិតនៅក្រុមទី០៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ។ លោកស្នងការបន្តថា កម្លាំងជំនាញបានឆែកឆេរហាងម៉ាស្សាជនជាតិចិនមួយកន្លែង ដែលមានស្លាកយីហោ ប៉ាយជឹងហាន់កុង ហើយកម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនជនសង្ស័យជនជាតិចិនចំនួន ២៩នាក់ ( បុរស ១៥នាក់ , នារី ១៤នាក់ )។

បន្ទាប់ពីស្រាវជ្រាវ ស៊ើបអង្កេតនិងសួរបំភ្លឺឃើញថា នារីចំនួនទាំង១៤នាក់ប្រកបមុខរបរផ្លូវភេទ។ ភ្ញៀវដែលមករកសេវាកម្ម សច្ចារកម្ម មានចំនួន ០៨នាក់ ហើយអ្នកដែលពាក់ព័ន្ធ ប្រព្រឹត្តិសច្ចារកម្ម ( ជួញដូរផ្លូវភេទខុសច្បាប់ ) មានចំនួន ០៧នាក់ រួមមាន៖

ទី១-ឈ្មោះ CHEN ZHIMIN ភេទប្រុស អាយុ ៤១ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែនលេខ: ED ៤៧៤៧៩៣១ ស្នាក់នៅ ក្រុម៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ( ថៅកែ )។

ទី២-ឈ្មោះ WU XIANGYUN ភេទប្រុស អាយុ ៤៨ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែនលេខៈ ED ៣៨៥៨៥៣១ ស្នាក់នៅ ក្រុម៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ( អ្នកគិតលុយ ) ។

ទី៣-ឈ្មោះ XU FEI ភេទប្រុស អាយុ ២៩ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែនលេខៈ ED៥៨៥៨២៧៣ ស្នាក់នៅ ក្រុម៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ( អ្នកគ្រប់គ្រងនារីនៅជាន់លើ ) ។

ទី៤-ឈ្មោះ ZHUANG FEI YUN ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែនលេខៈ ED ៨៩១៣២៧១ ស្នាក់នៅ ក្រុម៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ( អ្នកបើកឡានជូនភ្ញៀវ ) ។

ទី៥-ឈ្មោះ CHEN GANG ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិចិន ស្នាក់នៅ ក្រុម៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ( អ្នកទិញឥវ៉ាន់ ) ។

ទី៦-ឈ្មោះ ZHANG BING ភេទប្រុស អាយុ ២៧ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែនលេខៈ G៥៩៣៨៧៥១៩ ស្នាក់នៅ ក្រុម៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ( អ្នកចែកខិតប័ណ្ណ ) ។

ទី៧-ឈ្មោះ SHI YOUDAN ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិចិន លិខិតឆ្លងដែនលេខៈ ED ៦៦៧០០៥៨ ស្នាក់នៅ ក្រុម៨ ភូមិ១ សង្កាត់៣ ក្រុង-ខេត្តព្រះសីហនុ ( អ្នកចែកខិតប័ណ្ណ ) ។

វត្ថុតាងចាប់យកបានៈស្រោមអនាម័យប្រើប្រាស់រួច ( មានទឹកកាម ) ចំនួន ០១, ស្រោមអនាម័យមិនទាន់ប្រើប្រាស់ មួយចំនួនធំ, នាមប័ណ្ណហាងម៉ាស្សា ១០ប្រអប់, វិក័យប័ត្រមួយចំនួន, ឧបករណ៍ជំនួយក្នុងការរួមភេទ ( បាល់ខ្យល់ , ដើងទ្រធំ , ដើងទ្រតូច ), ទូរស័ព្ទដៃ ១៣គ្រឿង, រួមទាំងវត្ថុមួយចំនួនទៀតដែលពាក់ព័ន្ធនិងអាជីកម្មផ្លូវភេទនេះ ។

ចំពោះជនសង្ស័យទាំង ០៧នាក់ ខាងលើនេះ ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល កំពុងកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តព្រះសីហនុ ៕

## សមត្ថកិច្ចដោះលែងចិន៧នាក់វិញ បន្ទាប់ពីឃាត់ខ្លួនសាកសួររឿងផ្សព្វផ្សាយខិត្តប័ណ្ណបែបពេស្យាចារ

https://www.postkhmer.com/ ឃុត សុភចរិយា | Publication date 13 August 2018 | 20:09 ICT

**ព្រះសីហនុ:** ជនជាតិចិន ៧ នាក់ ត្រូវបានក្រុមកម្លាំងសមត្ថកិច្ចនគរបាលខេត្តព្រះសីហនុ ចាប់ឃាត់ខ្លួន ធ្វើការអប់រំណែនាំអស់រយៈពេលជាច្រើនម៉ោង បន្ទាប់ពីពួកគេ បានធ្វើសកម្មភាព ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីសេវាកម្មម៉ាស្សា ដែលមានរូបភាពទាក់ទាញ បែបពេស្យាចារ នៅតាមទីសាធារណៈ ក្នុងក្រុងព្រះសីហនុ កាលពីយប់ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១៨។

លោក កុល ភស្តា អធិការក្រុងព្រះសីហនុ បានថ្លែងថា កាលពីពេលថ្មីៗនេះ មានជនជាតិចិនមួយក្រុម បានប៉ុនប៉ងប្រកបមុខរបររកស៊ីខុសច្បាប់នៅកម្ពុជា តាមរយៈការបើកហាងម៉ាស្សា បង្កប់សេវាកម្មផ្លូវភេទ។ ក្រុមជនជាតិចិន ដ៏គួរឲ្យសង្ស័យទាំងនោះមានគ្នា ៧ នាក់ បានដើរផ្សព្វផ្សាយនិងចែកខិត្តបណ្ណម៉ាស្សា ដែលមានរូបភាពបែបពេស្យាចារ នៅតាមទីសាធារណៈ ក្នុងក្រុងព្រះសីហនុ ដែលនាំឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋខ្មែរ។ លោក បានបន្តថា ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់និងរបៀបរៀបរយនៅក្នុងសង្គម ពិសេសលុបបំបាត់អំពើពេស្យាចារនៅក្នុងសង្គម នៅយប់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៨ នគរបាលក្រុងព្រះសីហនុ បានសហការគ្នាជាមួយកម្លាំងនគរបាលខេត្ត ស្រាវជ្រាវធ្មេក់ចាប់បានជនជាតិចិន ដែលដើរផ្សព្វផ្សាយចែកខិត្តបណ្ណម៉ាស្សានោះ បានចំនួន ៦ នាក់ រួមមានឈ្មោះ Lu Jian, Fan Chao Jun, Wen Xiao Hu, Ly Yuhang, Li Zhu Zhi, និងឈ្មោះ Li Ziming និង ដកហូតបានខិត្តប័ណ្ណ ជាច្រើនសន្លឹក។ លោកបានបញ្ជាក់ថា៖«ក្រោយការឃាត់ខ្លួន ពួកគេនិងវត្ថុតាងទាំងអស់ ត្រូវបានបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ ដើម្បីធ្វើការសាកសួរទៅតាមនីតិវិធីច្បាប់»។

ប៉ុន្តែក្រោយពីមន្ត្រីជំនាញ បានធ្វើការសាកសួរ និងបានបកប្រែអត្ថន័យនិងខ្លឹមសារនៃខិត្តប័ណ្ណឃោសនារបស់ពួកគេ ដែលសរសេរជាភាសាចិនរួច រកពុំឃើញមានពាក្យពេចន៍ណាមួយ ដែលពាក់ព័ន្ធដល់ការផ្តល់សេវាកម្មផ្លូវភេទ ឬពេស្យាចារ ដែលជាអំពើខុសច្បាប់ នៅប្រទេសកម្ពុជានោះ ទើបសមត្ថកិច្ចសម្រេចធ្វើការដោះលែងពួកគេវិញ បន្ទាប់ពីពួកគេ បានចុះកិច្ចសន្យាបញ្ឈប់ការធ្វើសកម្មភាពឃោសនា ដោយប្រើប្រាស់រូបភាពក្នុងខិត្តប័ណ្ណបែបពេស្យាចារនេះតទៅទៀត។ នេះបើតាមការបញ្ជាក់បន្ថែមពីលោក ជួន ណារិន្ទ ស្នងការ ខេត្តព្រះសីហនុ។ លោកបានថ្លែងថា៖«យើងបានសម្រេចដោះលែងពួកគេ បន្ទាប់ពីរកមិនឃើញមានភ័ស្តុតាងណាមួយពាក់ព័ន្ធដល់ការលួចលាក់ផ្តល់សេវាកម្មផ្លូវភេទ។ ប៉ុន្តែបើសិនជាពួកគេនៅតែបន្តការដើរឃោសនាចែកខិត្តប័ណ្ណដែលមានរូបភាពបែបពេស្យាចារ យ៉ាងដូច្នេះទៀត យើងនឹងចាត់វិធានការទៅតាមច្បាប់របស់យើង»៕

## មេបញ្ជាការយោធាចុះត្រួតពិនិត្យភូមិសាស្ត្រតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ

http://www.rasmeinews.com/ August 14, 2018, 8:53 AM

*ដោយៈសៅរ៉ាន់ឌី/ព្រះវិហារៈ* កាលពីល្ងាចថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨លោកឧត្តមសេនីយ៍ទោ ចាន់ សុភ័ក្រ្តា មេបញ្ជាការរងយោធភូមិភាគទី៤ និងជាមេបញ្ជាការតំបន់ប្រតិបត្តការសឹករងខេត្តព្រះវិហារ ។ លោកបានដឹកនាំនាយនាយទាហានរងក្នុងតំបន់ប្រតិបត្តការសឹករងខេត្តព្រះវិហារចុះសួរសុខទុក្ខកងកម្លាំងរបស់ផ្នែកសឹករងស្រុកជាំក្សាន្ត និងត្រួតពិនិត្យភូមិសាស្ត្រនៅចំណុចអូរក្រូច និងភ្នំខ្មោច តាមខ្សែបន្ទាត់ព្រំដែនកម្ពុជាថៃ ។ លោកឧត្តមសេនីយ៍ទោចាន់សុភ័ក្រ្តាក៏បានពាំនាំនូវប្រសាសន៍ផ្តាំផ្ញើ និងសួរសុខទុក្ខពីសំណាក់ឧត្តមសេនីយ៍ឯក ជា ម៉ន មេបញ្ជាការយោធភូមិភាគទី៤និងលោកអ៊ុនចាន់ដាអភិបាលខេត្តព្រះវិហារ ។ លោកក៏បានណែនាំឲ្យកងកម្លាំងតាមបន្ទាត់ព្រំដែនទាំងអស់ ថែរក្សាសុខភាពឲ្យបានគ្រប់ៗគ្នា ពីព្រោះរដូវនេះជារដូវវស្សានិងត្រូវខិតខំបង្កបង្កើនផលដើម្បីលើកស្ទួយដល់ជីវភាពប្រចាំថ្ងៃឲ្យកាន់តែរីកចម្រើនបន្ថែមទៀត ។

លោកបានបន្តថាសុំឲ្យកងកម្លាំងតាមបន្ទាត់ព្រំដែនទាំងអស់សូមឲ្យមានសហការល្អជាមួយស្ថាប័នផ្សេងៗក៏ដូចជាអាជ្ញាធរដែនដីទប់ស្កាត់ឲ្យបាននូវរាល់បទល្មើសឆ្លងដែនផ្សេងៗ។ ដូចជាបទល្មើសគ្រឿងញៀនជាពិសេសត្រូវទប់ស្កាត់មិនឲ្យពលរដ្ឋខ្មែរឆ្លងដែនដោយខុសច្បាប់ចូលទៅកាប់ឈើគ្រញូងនៅទឹកដីថៃ។ដើម្បីចៀសវាងឲ្យបាននូវការចាប់ចងបាញ់សម្លាប់ពីសំណាក់ទាហានថៃ ។ ក្នុងពេលចុះត្រួតពិនិត្យភូមិសាស្ត្រនេះ លោកមេបញ្ជាការ ក៏បានឧបត្ថម្ភថវិកាសម្រាប់កសាងអង្គភាព និងជូនដល់គ្រួសារទ័ព រួមមានសម្ភារៈ និងគ្រឿងឧបភោគបរិភោគមួយចំនួនទៀត៕S/

# ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨

## បុរសចិន ៧ នាក់ត្រូវបានបញ្ជូនទៅតុលាការរឿងជួញដូរផ្លូវភេទ

https://www.postkhmer.com/ យុត សុភចរិយា | Publication date 15 August 2018 | 10:07 ICT

**ព្រះសីហនុៈ** បុរសជនជាតិចិនចំនួន ៧ នាក់ក្នុងចំណោមបុរស-ស្ត្រីជនជាតិចិន ២៩ នាក់ត្រូវបាននគរបាលខេត្តព្រះសីហនុកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តកាលពីម្សិលមិញ ខណៈអ្នកផ្សេងត្រូវបានដោះលែងវិញ បន្ទាប់ពីឃាត់ខ្លួនពាក់ព័ន្ធនឹងបទល្មើសជួញដូរផ្លូវភេទនៅហាងម៉ាស្សាមួយកន្លែងក្នុងក្រុងព្រះសីហនុកាលពីយប់ថ្ងៃចន្ទ។ នេះបើតាមលោកឧត្តមសេនីយ៍ទោ ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុកាលពីម្សិលមិញ។ លោក ណារិន្ទ បានថ្លែងថាកាលពីវេលាម៉ោង ៨:៣០ នាទីយប់ថ្ងៃចន្ទ បន្ទាប់ពីទទួលបានព័ត៌មានពីភ្នាក់ងារសម្ងាត់ថាទីតាំងហាងម៉ាស្សាប៉ាយជឹងហាន់កុងនៅក្រុមទី ៨ ភូមិ ១ សង្កាត់ ៣ ក្រុងព្រះសីហនុ មានបង្កប់សេវាកម្ម

ជួញដូរផ្លូវភេទ និងកំពុងធ្វើសកម្មភាពនោះរូបលោកក៏បានស្នើសុំកិច្ចសហការពីលោក កៀង សុទ្ធរោ ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តព្រះសីហនុ និង បានដឹកនាំកម្លាំងចម្រុះចុះទៅបង្ក្រាបទីតាំងខាងលើដោយបានឃាត់ខ្លួនបុរស-ស្ត្រី ជនជាតិចិន ២៩ នាក់។ លោកបានបញ្ជាក់ថា៖ «ក្រោយការសាកសួរ និងអប់រំណែនាំពីផ្លូវច្បាប់រួចសមត្ថកិច្ចយើងបានសម្រេចដោះលែងពួកគេ២២ នាក់ក្នុងនោះស្ត្រីបម្រើផ្លូវភេទ១៤នាក់ និងបុរសជាភ្ញៀវមកទិញសេវាផ្លូវភេទចំនួន ៨ នាក់ បន្ទាប់ពីពួកគេចុះកិច្ចសន្យាបញ្ឈប់ការប្រកបមុខរបររកស៊ីផ្លូវភេទដែលផ្ទុយនឹងច្បាប់កម្ពុជា»។

លោក ណារិទ្ធ បានបន្ថែមថា៖ «ដោយឡែកបុរសជាម្ចាស់ហាង និងបក្ខពួក ៦ នាក់ទៀតត្រូវបានសមត្ថកិច្ចយើងកសាងសំណុំរឿងចោទប្រកាន់ពីបទប្រព្រឹត្តអំពើសញ្ចារកម្ម និងបានបញ្ជូនខ្លួនទៅសាលាដំបូងខេត្តព្រះសីហនុដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់»។ បើតាមលោក ណារិទ្ធ បុរសជនជាតិចិនទាំង ៧ នាក់នោះរួមមានឈ្មោះ CHEN ZHIMIN អាយុ ៤១ ឆ្នាំកាន់លិខិតឆ្លងដែនលេខ ED៤៧៤៧៩៣១ ជាម្ចាស់ហាងម៉ាស្សាប៉ាយជើងហាន់កុង ,WU XIANGY-UN អាយុ ៤៨ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ ED៣៨៥៨៥៣១ ជាអ្នកគិតលុយ,XU FEI អាយុ ២៩ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ ED៥៨៥៨២៧៣ ជាមេការ, ZHU-ANG FEI YUN អាយុ ៣៧ ឆ្នាំកាន់លិខិតឆ្លងដែនលេខ ED៨៩១៣២៧១ ជាអ្នកបើកឡានជូនភ្ញៀវ,C-HEN GANG អាយុ ៣៥ ឆ្នាំជាអ្នកទិញអីវ៉ាន់,ZHA-NG BING អាយុ ២៧ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ G៥៩៣៨-៧៥១៩ និងម្នាក់ទៀតឈ្មោះ SHI YOUDAN អាយុ ៣៦ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ ED៦៦៧០០៥៨ ជាអ្នកចែកខិត្តប័ណ្ណផ្សព្វផ្សាយ។ ពួកគេទាំង ៧ នាក់បានមកជួលផ្ទះស្នាក់នៅបណ្ដោះអាសន្ន និងបើកហាងម៉ាស្សាបង្កប់សេវាផ្លូវភេទ។ លោកបានប្រាប់ទៀតថា ការបង្ក្រាបនេះសមត្ថកិច្ចក៏បានរឹបអូសវត្ថុតាងមួយចំនួនពាក់ព័ន្ធនឹងអាជីវកម្មផ្លូវភេទផងដែរ ក្នុងនោះរួមមានស្រោមអនាម័យប្រើប្រាស់រួច និងមិនទាន់ប្រើប្រាស់ជាច្រើនប្រអប់ឧបករណ៍ជំនួយក្នុងការរួមភេទ (បាល់ខ្យល់, ជើងទ្រធំ, ជើងទ្រតូច) និងទូរស័ព្ទដៃ ១៣ គ្រឿង។

កាលពីរសៀលថ្ងៃម្សិលមិញពួកគេទាំង ៧ នាក់ត្រូវបានសមត្ថកិច្ចនគរបាលខេត្តព្រះសីហនុបញ្ជូនខ្លួនទៅដល់សាលាដំបូងខេត្តព្រះសីហនុ ហើយតុលាការកំពុងបន្តនីតិវិធីស៊ើបសួរ។ នេះបើតាមលោកព្រះរាជអាជ្ញារង កៀង សុទ្ធរោ ដែលកាន់សំណុំរឿងនេះ។ លោកបានបញ្ជាក់ថា៖ «ពេលនេះជនសង្ស័យទាំង ៧ នាក់បានបញ្ជូនមកដល់ស្ថាប័នអយ្យការអមសាលាដំបូងខេត្តព្រះសីហនុហើយ ហើយយើងកំពុងបន្តសួរចម្លើយពួកគេទៅតាមនីតិវិធីច្បាប់»៕

## ទូតខ្មែរ ប្រចាំប្រទេសជប៉ុន អំពាវនាវឲ្យប្រុងប្រយ័ត្នចាញ់បោកមេខ្យល់

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង ១៣:៤៣

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន បានធ្វើការអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេស កម្មសិក្សាការីដែលកំពុងរស់នៅ និងធ្វើការនៅប្រទេសជប៉ុន ឬប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់ស្វែងរកការងារធ្វើនៅប្រទេសជប៉ុនឲ្យប្រុងប្រយ័ត្នខ្ពស់ ចំពោះមេខ្យល់ដែលធ្វើការបោកប្រាស់ដើម្បីធ្វើអាជីវកម្ម។ សេចក្ដីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន ដែលចុះថ្ងៃទី១៥សីហា ឆ្នាំ២០១៨នេះបានឲ្យដឹងថា មេខ្យល់បានប្រើប្រាស់វិធីសាស្ត្របោកប្រាស់ដោយអះអាងថា នឹងស្វែងរកការងារដែលមានប្រាក់ខែខ្ពស់ ធានាជួយធ្វើឬបន្តបណ្ណស្នាក់នៅ និងសុំសិទ្ធិធ្វើការនៅប្រទេសជប៉ុនជូនប្រជាពលរដ្ឋខ្មែរ។ ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន បានអំពាវនាវដល់ប្រជាពលរដ្ឋ ទាក់ទងមកស្ថានទូត ដើម្បីប្រឹក្សាយោបល់ និងស្វែងរកដំណោះស្រាយ តាមរយៈ ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន (ទូរសព្ទលេខ៖ ០៣ ៥៤១២ ៨៥២១), (ហ្វេសប៊ុក៖ Royal Embassy of Cambodia in Japan) ឬ ទីប្រឹក្សាទទួលបន្ទុកពលករ (ទូរសព្ទលេខ៖ ០៨០ ៣៤៥៩ ៧៨៨៩), (ហ្វេសប៊ុក៖ Labour Counsellor in Japan)៕

## ជួយរកយុត្តិធម៌ឲ្យកូនខ្ញុំផង...សមត្ថកិច្ចថៃថា សពជនរងគ្រោះត្រូវឆក់ចរន្តអគ្គីសនីស្លាប់ តែក្រុមគ្រួសារនិងសាច់ញាតិសង្ស័យថា ជាអំពើឃាតកម្ម ព្រោះលើខ្លួនសពមានស្នាមរបួសជាច្រើនកន្លែង...ជីវិតជាពលករពិតជាគ្រោះថ្នាក់ណាស់

https://www.khmernews.news/ ដោយ ស៊ីថា ១៥/០៨/២០១៨

បន្ទាយមានជ័យ ៖ យុវជនម្នាក់មានឈ្មោះថា វ៉ាន ជីហួរ អាយុ២០ឆ្នាំ បានទៅធ្វើពលករនៅក្រុងបាងកក ហើយក៏បានស្លាប់បាត់បង់ជីវិត នៅប្រទេសថៃ ដោយសារតែឆក់ចរន្តអគ្គីសនី ប៉ុន្តែឪពុកម្តាយនិងសាច់ញាតិ មិនជឿ ដោយលើកឡើងថា នេះជាអំពើឃាតកម្មជាក់ជាមិនខាន ព្រោះថានៅលើសពជនរងគ្រោះ បានបន្សល់នៅស្នាមរបួសជាច្រើន និងមានទាំងឈាមទៀតផង។ ជនរងគ្រោះឈ្មោះ វ៉ាន ជីហួរ ហៅកក្កា ភេទប្រុស អាយុ២០ឆ្នាំ ជាពលករធ្វើការ នៅប្រទេសថៃ ផ្នែករោងចក្រផលិតម៉ាស៊ីនត្រជាក់ និងមានទីលំនៅភូមិរាមសេនា ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង បានស្លាប់បាត់បង់ជីវិតកាលពីវេលាទៀបភ្លឺថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨។ សពជនរងគ្រោះត្រូវបានគេបញ្ជូនមកកម្ពុជា តាមច្រកតំបន់បឹងត្រកួន យប់ថ្ងៃទី១០ ខែសីហា ហើយសាច់ញាតិ ជួលរថយន្តដឹកបន្តទៅលំនៅដ្ឋាន ដើម្បីធ្វើបុណ្យ តាមប្រពៃណី។ សាច់ញាតិសព បានលើកឡើងថា ជនរងគ្រោះសង្ស័យ ស្លាប់ដោយសារ អំពើឃាតកម្ម ហើយបានអំពាវនាវ ដល់ក្រសួងពាក់ព័ន្ធ របស់កម្ពុជាមេត្តាជួយរកយុត្តិធម៌ផង៕

## ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨

### លោកជំទាវ ហ៊ុន កុសនី អភិបាលរងខេត្តកណ្តាល អញ្ជើញផ្សព្វផ្សាយច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស នៅស្រុកកៀនស្វាយ

http://matemohachunnews.com/local-news/ August 15, 2018

ខេត្តកណ្តាល ៖ នៅស្រុកកៀនស្វាយខេត្តកណ្តាល កាលពីព្រឹក ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨នេះ បានប្រារព្ធពិធីបើកវេទិកាផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងក្រុមគ្រួសារ និងកិច្ចការពារជនរងគ្រោះ នៅសាលាឃុំដីឥដ្ឋ ក្រោមអធិបតីភាពលោកជំទាវ ហ៊ុន កុសនី អភិបាលរងខេត្ត ជាតំណាងឯកឧត្តមបណ្ឌិត ម៉ៅ ភិរុណ អភិបាលខេត្តកណ្តាល, លោកសេង រិទ្ធី ព្រះរាជអាជ្ញារងអយ្យការអមសាលាដំបូងខេត្ត,លោកស្រីឧត្តមសេនីយ៍ត្រីឈឹម វណ្ណីស្នងការ រងខេត្តនិងលោកស្រី វ៉ែន កន្និការជាអភិបាលរងស្រុកកៀនស្វាយនិងបងប្អូនប្រជាពលរដ្ឋយ៉ាងច្រើនកុះករ។

លោកស្រី វ៉ែន កន្និការ បានថ្លែងថា៖ ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈក្នុងរយៈពេល០៦ខែដើមឆ្នាំ២០១៨គណៈបញ្ជាការឯកភាពស្រុកកៀនស្វាយ និងរួមជាមួយអាជ្ញាធរឃុំបានខិតខំយកចិត្តទុកដាក់ពង្រឹងកិច្ចការសហការការពារសន្តិសុខសណ្តាប់ធ្នាប់សង្គមជូនថ្នាក់ដឹកនាំ,ប្រជាពលរដ្ឋ និងពិធីបុណ្យផ្សេងៗមានសុវត្ថិភាពល្អដោយសម្រេចលទ្ធផលល្អប្រសើរ។ លោកស្រីអភិបាលរងស្រុក បានថ្លែងបន្តថា៖សភាពការណ៍បទល្មើសកើតឡើង២០ករណី/២៥ករណី(ប្រៀបធៀបនឹងឆមាសទី១ឆ្នាំ២០១៧ថយចុះ៥ករណី) និងជនសង្ស័យ២៥នាក់ (ឃាត់ខ្លួន១៥នាក់ និងគេចខ្លួន១០នាក់) ក្នុងនោះបទល្មើសព្រហ្មទណ្ឌ១៤ករណី/០៨ករណី(កើនឡើង០៦ករណី)និងជនសង្ស័យ ១៧នាក់ (ឃាត់ខ្លួន០៧នាក់ និងគេចខ្លួន១០នាក់)។ លោកស្រី អភិបាលរងបានបន្តថា៖ការងារបទល្មើសគ្រឿងញៀនមាន០៦ករណីជនល្មើស០៨នាក់ ក្នុងនោះជួញដូរនូវសាធាតុញៀន០៤ករណី នៅភូមិកោះរៀឃុំគគីរ,ភូមិព្រែកត្រែងឃុំសំរោងធំ,ភូមិពោធិ៍មៀវឃុំគគីរធំនិងភូមិគគីរឃុំគគីរនិងរក្សាទុកដើម្បីប្រើប្រាស់០២ករណី នៅឈភូមិកំពង់ស្វាយឃុំកំពង់ស្វាយស្រុកកៀនស្វាយ និងក្រោមការចង្អុលបង្ហាញណែនាំពីគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកណ្តាលពីឯកឧត្តមបណ្ឌិតម៉ៅភិរុណ អភិបាលខេត្ត និងក៏ដូចជាគណៈបញ្ជាការឯកភាពស្រុកកៀន

ស្ទាយក្រោមការដឹកនាំពីលោកអ៊ូឈាងបានខិតខំតស៊ូស្រាវជ្រាវ និងបង្ក្រាបបទល្មើសក្នុងឆមាសទី១ ឆ្នាំ២០១៨ ជាលទ្ធផលបានចំនួន១៣ករណី ឃាត់ខ្លួនជនសង្ស័យ១៥នាក់ (បទឧក្រិដ្ឋ០២ករណី ឃាត់ខ្លួន០២នាក់ បទមជ្ឈឹម ០៥ករណី ជនល្មើស០៥នាក់)(បទល្មើសគ្រឿងញៀន០៦ករណី ជនល្មើស០៥នាក់។

លោកជំទាវ ហ៊ុន កុសនី និងលោកស្រីឧត្តមសេនីយ៍ត្រី ឈឹម វណ្ណិបា នថ្លែងថា៖ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ត្រូវមានការប្រុងប្រយ័ត្នចំពោះជនសង្ស័យទាំងឡាយ ដែលពួកគេបានចូលមកក្នុងមូលដ្ឋានរបស់បងប្អូនដែលរស់នៅ និងពួកគេបានបោកបញ្ឆោតថា៖ គេនិងនាំរកការងារឱ្យធ្វើជាដើម។ លោកស្រីបានថ្លែងបន្តថា៖ បើមានជនសង្ស័យមកធ្វើការអូសទាញគួរមានការសង្ស័យ និងត្រូវរាយការណ៍ជូនទៅសមត្ថកិច្ចដែលបងប្អូនរស់នៅជាបន្ទាន់ ដើម្បីមានវិធានការទប់ស្កាត់ខាងតែបាន៕ ដោយ ដៃ ដែក

## ពលរដ្ឋខ្មែររត់គេចពីកន្លែងធ្វើការស្របច្បាប់ និងចាញ់បោកមេខ្យល់នៅប្រទេសជប៉ុន មានការថយចុះគួរឱ្យកត់សម្គាល់

http://www.freshnewsasia.com/index.php/en/ 2018-08-15

**(ភ្នំពេញ)៖** ចំនួនកម្មសិក្សាការីខ្មែរ ដែលបានចាញ់បោកមេខ្យល់ និងរត់គេចពីកន្លែងធ្វើការនៅប្រទេសជប៉ុន មានការថយចុះគួរឱ្យកត់សម្គាល់។ នេះបើយោងតាមសេចក្តីជូនដំណឹងរបស់ស្ថានទូតកម្ពុជា ប្រចាំប្រទេសជប៉ុនដែលបណ្តាញព័ត៌មាន Fresh News ទទួលបាននៅព្រលប់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨នេះ។ ការថយចុះនេះ បានកើតឡើងបន្ទាប់ពីក្រសួងយុត្តិធម៌ជប៉ុន បានរឹតបន្តឹងក្នុងការផ្តល់សិទ្ធិ ធ្វើការចំពោះជនបរទេសទាំងឡាយណា ដែលបានរត់គេចពីកន្លែងធ្វើការស្របច្បាប់ និងរឹតបន្តឹងការដាក់ពាក្យស្នើសុំជ្រកកោនជាជនភៀសខ្លួននៅប្រទេសជប៉ុន។

ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសជប៉ុន បានអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសកម្មសិក្សាការីដែលកំពុងរស់នៅ និងធ្វើការនៅប្រទេសជប៉ុន ឬប្រជាពលរដ្ឋខ្មែរ ដែលមានបំណងចង់ស្វែងរកការងារធ្វើនៅប្រទេសជប៉ុនទាំងអស់ សូមប្រុងប្រយ័ត្នខ្ពស់ ចៀសវាងចាញ់បោកតាមការអូសទាញរបស់មេខ្យល់ដែលធ្វើអាជីវកម្មលើប្រជាពលរដ្ឋ ដោយអះអាងថានឹងស្វែងរកការ ដែលមានប្រាក់ខែខ្ពស់ធានាជួយធ្វើ ឬបន្តប័ណ្ណស្នាក់នៅ និងសុំសិទ្ធិធ្វើការនៅប្រទេសជប៉ុនជូនបងប្អូន។ ទាំងនេះជាការបោកបញ្ឆោត ផ្ទុយទៅនឹងការប្រកាសរបស់ក្រសួងយុត្តិធម៌ជប៉ុន ហើយធ្វើឱ្យបងប្អូនប្រឈមនឹងផ្លូវច្បាប់ខាតបង់ថវិកា និងពេលវេលាផ្ទាល់ខ្លួន។ ស្ថានទូតកម្ពុជាបានបន្តថា នៅក្នុងន័យនេះ ប្រសិនបើបងប្អូនមានបញ្ហា ឬចម្ងល់ផ្សេងៗ ពាក់ព័ន្ធនឹងការងាររបស់បងប្អូននៅក្នុងប្រទេសជប៉ុន ឬចាញ់បោកមេខ្យល់ សូមបងប្អូនមេត្តាទាក់ទងមកស្ថានទូត ដើម្បីប្រឹក្សាយោបល់ និងស្វែងរកដំណោះស្រាយទៅតាមនីតិវិធីច្បាប់តាមរយៈ៖

១៖ ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន ទូរស័ព្ទលេខ៖ ០៣ ៥៤ ១២ ៨៥ ២១ ឬហ្វេសប៊ុក៖ Royal Embassy of Cambodia in Japan

២៖ ទីប្រឹក្សាទទួលបន្ទុកពលករ ទូរស័ព្ទដៃលេខ ០៨០ ៣៤៥៩ ៧៨៤៩ ឬហ្វេសប៊ុក៖ Labour Counsellor in Japan៕

សម្រាប់ព័ត៌មានលម្អិត សូមអានសេចក្តីជូនដំណឹងរបស់ស្ថានទូតកម្ពុជា ប្រចាំប្រទេសជប៉ុន ទាំងស្រុងដូចខាងក្រោម៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

# សេចក្តីជូនដំណឹង

ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន សូមជម្រាបជូនដំណឹងដល់សាធារណជន ជាពិសេសបងប្អូនកម្មសិក្សាការីខ្មែរដែលកំពុងរស់នៅ និងធ្វើការនៅប្រទេសជប៉ុនទាំងអស់ឱ្យបានជ្រាបថា ក្រោយពីក្រសួងយុត្តិធម៌ជប៉ុនបានរឹតបន្តឹងក្នុងការផ្តល់សិទ្ធិធ្វើការចំពោះជនបរទេសទាំងឡាយណាដែល បានរត់គេចពីកន្លែងធ្វើការស្របច្បាប់ ហើយដាក់ពាក្យស្នើសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួនរួចមក ចំនួន កម្មសិក្សាការីដែលបានចាញ់បោកមេខ្យល់និងរត់គេចពីកន្លែងធ្វើការ មានការថយចុះគួរឱ្យកត់សម្គាល់។

ជាថ្មីម្តងទៀត ស្ថានទូតសូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសបងប្អូន កម្មសិក្សាការីដែលកំពុងរស់នៅ និងធ្វើការនៅប្រទេសជប៉ុន ឬបងប្អូនប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់ មកស្វែងរកការងារធ្វើនៅប្រទេសជប៉ុនទាំងអស់ សូមមេត្តាប្រុងប្រយ័ត្នខ្ពស់ **ជៀសវាងចាញ់បោកតាមការអូស ទាញរបស់មេខ្យល់ដែលធ្វើអាជីវកម្មលើបងប្អូន ដោយអះអាងថានឹងស្វែងរកការងារដែលមានប្រាក់ខែខ្ពស់ ធានាជួយធ្វើឬបន្តប័ណ្ណស្នាក់នៅ និងសុំសិទ្ធិធ្វើការនៅប្រទេសជប៉ុនជូនបងប្អូន។** ទាំងនេះគឺជាការបោក បញ្ឆោត ផ្ទុយទៅនឹងការប្រកាសរបស់ក្រសួងយុត្តិធម៌ជប៉ុន ហើយធ្វើឱ្យបងប្អូនប្រឈមមុខនឹងផ្លូវច្បាប់ ខាត បង់ថវិកា និងពេលវេលាផ្ទាល់ខ្លួន។

នៅក្នុងន័យនេះ ប្រសិនបើបងប្អូនមានបញ្ហាឬចម្ងល់ផ្សេងៗពាក់ព័ន្ធនឹងការងាររបស់បងប្អូននៅក្នុង ប្រទេសជប៉ុន ឬបានចាញ់បោកមេខ្យល់ សូមបងប្អូនមេត្តាទាក់ទងមកស្ថានទូត ដើម្បីប្រឹក្សាយោបល់ និង ស្វែងរកដំណោះស្រាយទៅតាមនីតិវិធីច្បាប់ តាមរយៈ៖

១. **ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន៖** ទូរស័ព្ទលេខ ០៣ ៥៤១២ ៨៥២១
   ហ្វេសប៊ុក៖ Royal Embassy of Cambodia in Japan

២. **ទីប្រឹក្សាទទួលបន្ទុកពលករ៖** ទូរស័ព្ទដៃលេខ ០៨០ ៣៤៥៩ ៧៨៨៩
   ហ្វេសប៊ុក៖ Labour Counsellor in Japan

ស្ថានទូតរង់ចាំសហការ និងជួយដោះស្រាយរាល់បញ្ហារបស់បងប្អូនគ្រប់ពេលវេលា ហើយនឹងរក្សា ការសម្ងាត់បំផុតចំពោះព័ត៌មានដែលផ្តល់ជូនស្ថានទូត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជាពិសេសបងប្អូនដែលកំពុងធ្វើការ ឬមាន បំណងមកធ្វើការនៅប្រទេសជប៉ុន មានការប្រុងប្រយ័ត្នខ្ពស់ និងចូលរួមផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះឱ្យ បានទូលំទូលាយតាមការគួរ។

ថ្ងៃពុធ ៤ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
តូក្យូ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel: (81 3)5412-8521 Fax: (83 1)5412-8
E-mail : camemb.jpn@mfa.gov.kh

# ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨

## ខ្លាំងបាត់! សេវាម៉ាស្សាពិសេសរបស់ចិនមកដល់ភ្នំពេញហើយ

http://www.rasmeinews.com/ August 16, 2018, 8:28 PM

ដោយ: មុនីរ័ត្ន / ភ្នំពេញ: ខិត្តប័ណ្ណរូបស្រីចិនស្លៀកសិចស៊ីបង្ហាញភាពស្រើបស្រាល និងរូបបុរសចិនស្រាតនលគោកជាច្រើនសន្លឹកត្រូវបានដើរចេញនៅតាមតំបន់សំខាន់មួយចំនួននៅក្នុងរាជធានីភ្នំពេញ និងតាមទីសាធារណៈផ្សេងៗមួយចំនួនទៀត ដែលធ្វើឲ្យប្រជាពលរដ្ឋមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ខិត្តប័ណ្ណបែបនេះ គឺនាពេលកន្លងមកត្រូវបានដើរចែកយ៉ាងអនាធិបតេយ្យនៅក្នុងខេត្តព្រះសីហនុ ដែលជាខេត្តទេចរណ៍មួយសំបូរទៅដោយភ្ញៀវទេសចរចម្រុះជាតិសាសន៍ ជាពិសេសជនជាតិចិនច្រើនជាងគេ។ ប៉ុន្តែករណីនេះ ត្រូវបានសមត្ថកិច្ចខេត្តព្រះសីហនុ ឃាត់ខ្លួនក្រុមអ្នកដើរចែក និងឈានទៅដល់ការបង្ក្រាបថែមទៀតផង។ បើតាមខិត្តប័ណ្ណដែលទទួលបាន គឺនៅក្នុងខិត្តប័ណ្ណនោះមានផ្ទៃពណ៌ផ្កាឈូក មានសរសេរអក្សរខ្មែរ "ភ្នំពេញទីមួយ" និងមានសរសេរអក្សរចិន និងអង់គ្លេស (Health massage) អមជាមួយ និងថែមទាំងមានដាក់លេខទូរស័ព្ទទំនាក់ទំនងថែមទៀតផង។ ហើយជាពិសេសគឺបានដាក់រូបស្រីចិនស្លៀកពាក់សិចស៊ីលេចលើលេចក្រោម ដែលបង្ហាញពីភាពស្រើបស្រាល។ ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺនៅក្នុងខិត្តប័ណ្ណនោះ ក៏មានដាក់រូបបុរសចិនស្រាតនលគោក បម្រើសេវាម៉ាស្សាផងដែរ។

បើតាមស្ត្រីអ្នកបកប្រែនៅហាង ភ្នំពេញទីមួយ បានថ្លែងកាលពីរសៀលថ្ងៃទី ១៦ ខែសីហា ថា ខិត្តប័ណ្ណនេះចែកផ្សព្វផ្សាយអំពីការម៉ាស្សាសម្រាប់ ដោយក្នុងតម្លៃ ៧៥នាទី ថ្លៃ១៨០ដុល្លារ។ ហើយហាងភ្នំពេញទីមួយ នឹងបើកសំណើការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ទីតាំស្ថិតនៅទល់មុខសណ្ឋាគារកាំបូឌីយ៉ា។ ប៉ុន្តែព័ត៌មានលំអិតយ៉ាងណានោះ អ្នកបកប្រែមិនបានបញ្ជាក់លំអិតទេ។

ទាក់ទងករណីនេះ លោកនាយឧត្តមសេនីយ៍ ជួន សុវណ្ណ អគ្គស្នងការរងនគរបាលជាតិ និងជាស្នងការនគរបាលរាជធានីភ្នំពេញ មិនអាចសុំការអត្ថាធិប្បាយបានទេដោយទូរស័ព្ទចូលជាប់រវល់រហូត បើទោះបីជាព្យាយាមជាច្រើនដងក៏ដោយ។

ចំណែកលោកនាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គស្នងការរងនគរបាលជាតិ និងជាអ្នកនាំពាក្យ បានបញ្ជាក់ថា លោកនៅមិនទាន់ទទួលបានព័ត៌មាននេះនៅឡើយទេ៕ ល

## លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ បញ្ជាឲ្យបិទទីតាំងម៉ាស្សា "ភ្នំពេញទីមួយ" និងចាប់ខ្លួនក្រុមចែកខិត្តប័ណ្ណ

https://chsknews.com/ 2018/08/17

ភ្នំពេញ៖ នៅថ្ងៃទី១៧ខែសីហាឆ្នាំ២០១៨នេះ លោកបានបញ្ជាឲ្យអាជ្ញាធរមានសមត្ថកិច្ចចុះបិទទីតាំងម៉ាស្សា "ភ្នំពេញទីមួយ" និងតាមស្វែងរកចាប់ខ្លួនក្រុមដែលចែកខិត្តប័ណ្ណមានរូបស្រើបស្រា ដើម្បីធ្វើការសាកសួរ។ ការដាក់បទបញ្ជានេះ គឺធ្វើឡើងក្រោយពីមានការរិះគន់តាមបណ្តាញសង្គមហ្វេសប៊ុក ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងទៅថ្មីៗនេះ។ ខិត្តប័ណ្ណរូបស្រីចិនស្លៀកសិចស៊ីបង្ហាញភាពស្រើបស្រាល និងរូបបុរសចិនស្រាតនលគោកជាច្រើនសន្លឹក ត្រូវបានដើរចេញនៅតាមតំបន់សំខាន់មួយចំនួន នៅក្នុងរាជធានីភ្នំពេញ និងតាមទីសាធារណៈផ្សេងៗមួយចំនួនទៀត ដែលធ្វើឲ្យប្រជាពលរដ្ឋមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ខិត្តប័ណ្ណបែបនេះ គឺនាពេលកន្លងមកត្រូវបានដើរចែកយ៉ាងអនាធិបតេយ្យនៅក្នុងខេត្តព្រះសីហនុ ដែលជាខេត្តទេចរណ៍មួយសំបូរទៅដោយភ្ញៀវទេសចរចម្រុះជាតិសាសន៍ ជាពិសេសជនជាតិចិនច្រើនជាងគេ។ ប៉ុន្តែករណីនេះ ត្រូវបានសមត្ថកិច្ចខេត្តព្រះសីហនុ ឃាត់ខ្លួនក្រុមអ្នកដើរចែក និងឈានទៅដល់ការបង្ក្រាបថែមទៀតផង។ ខិត្តប័ណ្ណដែលទទួលបាន គឺនៅក្នុងខិត្តប័ណ្ណនោះ

មានផ្ទៃពណ៌ផ្កាឈូក មានសរសេរអក្សរខ្មែរ "ភ្នំពេញទីមួយ" និងមានសរសេរអក្សរចិន និងអង់គ្លេស (Health massage) អមជាមួយ និងថែមទាំងមានដាក់លេខទូរស័ព្ទទំនាក់ទំនងថែមទៀតផង។ ហើយជាពិសេសគឺបានដាក់រូបស្រីចិនស្លៀកពាក់សិចស៊ីលេចលើលេចក្រោម ដែលបង្ហាញពីភាពស្រើបស្រាល។ ប៉ុន្តែអ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺនៅក្នុងខិត្តប័ណ្ណនោះ ក៏មានដាក់រូបបុរសចិនស្រាតននលគោក បម្រើសេវាម៉ាស្សាផងដែរ ៕

## សមត្ថកិច្ចស្វែងរកមុខអ្នកអ្នកចែកចាយខិត្តប័ណ្ណសេវាផ្លូវភេទ ក្នុងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់

https://peoplenews.asia/ ដោយ ៖ សុខ សាន្ត ថ្ងៃទី17 ខែ08 ឆ្នាំ2018 ម៉ោង 8:07 AM

ភ្នំពេញ៖ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ បានអំពាវនាវឲ្យប្រកាសស្វែងរកមុខអ្នកអ្នកចែកចាយខិត្តប័ណ្ណសេវាផ្លូវភេទ ក្នុងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់។មហាជនលើកឡើងថាមិនពិបាករកដូចរាវម្ជុលក្នុងបាតសមុទ្រ ទេ ព្រោះនៅលើស្ទិកឃ័រ មានលេខទូរសព្ទ័ស្រាប់ហើយ។ យោងតាម ហ្វេសប៊ុកផេកការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនរាជធានីភ្នំពេញ សរសេរនៅថ្ងៃទី១៧ ខែសីហា នេះ ថា "សូមបងប្អូនប្រជាពលរដ្ឋដែលបានឃើញជនណាដែលដើរចែកនាមប័ណ្ណឬខិត្តប័ណ្ណដែលមានខ្លឹមសារ ពាក់ព័ន្ធនឹងសេវាម៉ាស្សា ឬ សេវាផ្លូវភេទ នៅរាជធានីភ្នំពេញសូមមេត្តារាយការណ៍ជូនសមត្ថកិច្ចដែលនៅជិតបំផុតឬរាយការណ៍មកលេខទូរសព្ទ ០១២៦៩០០៩៩ ឬ ០៨៨២១២៨៨៨៨ ដេ៉ីម្បីមានវិធានការតាមផ្លូវច្បាប់ជាធរមាន ។

មហាជនលើកឡើងថា អស់ពីខេត្តព្រះសីហនុ , ឥឡូវនេះរាជធានីភ្នំពេញ មានអ្នកចែកចាយខិត្តប័ណ្ណសេវាម៉ាស្សា ឬ សេវាផ្លូវភេទម្តង ជាសាធារណៈ ។ ករណីនេះ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និង សីលធម៌ដ៏ល្អនៃជនជាតិខ្មែរ ។

## អាមេរិកមានគម្រោងនឹងបញ្ជូនពលរដ្ឋខ្មែរ៣០ទៀតទៅកាន់កម្ពុជានៅចុងខែសីហានេះ

https://www.rfa.org/khmer/news/ ថន ថារ៉ូ 2018-08-16

អាជ្ញាធរសហរដ្ឋអាមេរិកនឹងបញ្ជូនពលរដ្ឋខ្មែរដែលបានប្រព្រឹត្តបទល្មើសនៅអាមេរិក ៣០នាក់បន្ថែមទៀតទៅកាន់ប្រទេសកម្ពុជា នៅថ្ងៃទី២២ ខែសីហា ខាងមុខនេះ។ ទាំងអង្គការសង្គមស៊ីវិល និងសមត្ថកិច្ចកម្ពុជា អោយដឹងថាពលរដ្ឋខ្មែរដែលត្រឡប់មកកម្ពុជាទាំងចាប់បង្ខំនោះ ជួបការលំបាកក្នុងការរស់នៅដោយសារពួកគេបែកបាក់ពីក្រុមគ្រួសារ និងមួយចំនួនពិបាកសម្របខ្លួនទៅក្នុងសង្គម និងវប្បធម៌ថ្មី ។ ទោះជាយ៉ាងណា ការនិរទេសពលរដ្ឋខ្មែរដែលរំលោភច្បាប់អាមេរិកទៅកម្ពុជាវិញនេះ គឺជាផ្នែកមួយនៃកិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរដែលបានចុះហត្ថលេខានៅឆ្នាំ២០០២។

នាយកប្រតិបត្តិអង្គការគាំពារពលរដ្ឋខ្មែរគ្មានទីពឹង លោក តាន់ សូនិក (Sonec Tan) បានអោយអាស៊ីសេរីដឹងថា អាជ្ញាធរអាមេរិកនឹងបញ្ជូនពលរដ្ឋខ្មែរចំនួន៣០នាក់ ពីសហរដ្ឋអាមេរិកវិញ នៅចុងខែសីហានេះ។ ទោះជាយ៉ាងណា លោកថា អង្គការរបស់លោកនៅមិនទាន់បានទទួលបញ្ជីឈ្មោះ ពីអាជ្ញាធរអាមេរិកនៅឡើយទេ រហូតមកដល់ពេលផ្សាយនេះ។ លោក តាន់ សូនិក បញ្ជាក់ថា រហូតមកដល់ពេលនេះ មានពលរដ្ឋខ្មែរចំនួន ៦៣៩នាក់ហើយ ត្រូវបានអាជ្ញាធរអាមេរិកបញ្ជូនមកដល់កម្ពុជាវិញ ក្នុងនោះមានបុរស៦២៣នាក់ និងស្រ្តី ១៦នាក់។ លោកបន្ថែមថា ការប្រឈមខ្លាំងនោះ គឺពលរដ្ឋខ្មែរមួយចំនួនដែលត្រលប់មកកម្ពុជាវិញហើយនោះ ខ្វះការជួយជ្រោមជ្រែងពីគ្រួសារនៅអាមេរិក និងនៅស្រុកខ្មែរ នៅពេលអ្នកត្រូវបញ្ជូនត្រលប់មកវិញមានចំនួនកាន់តែច្រើនឡើង។ ពលរដ្ឋខ្មែរទាំងនេះខ្វះចំណេះដឹងផ្នែកវប្បធម៌ និងភាសាខ្មែរ ដែលធ្វើអោយពួកគេមានការលំបាកក្នុងការផ្ញើស

មាហរណកម្ម សម្របខ្លួនចូលទៅក្នុងសង្គមខ្មែរ។ លោក តាន់ សូនិក ក៏បានអោយដឹងដែរថា ពលរដ្ឋខ្មែរប្រមាណ ២០ភាគរយដែលត្រូវបានបញ្ជូនត្រលប់មកវិញនោះ មានការលំបាកក្នុងការសម្របខ្លួនទៅក្នុងសង្គមដែលគេគិតថា មិនមែនជាប្រទេសរបស់ពួកគេ។ រហូតមកដល់ពេលនេះ ពលខ្មែរដែលត្រូវបានបញ្ជូនត្រលប់មកកម្ពុជាវិញនោះ មានចំនួន២៩នាក់បានស្លាប់ ដែលក្នុងនោះ ២នាក់ បានធ្វើអត្តឃាត។

យោងតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលអាមេរិក និងរដ្ឋាភិបាលខ្មែរកាលពីឆ្នាំ២០០២ សហរដ្ឋអាមេរិកនឹង បញ្ជូនពលរដ្ឋខ្មែរ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋនៅសហរដ្ឋអាមេរិកទៅកាន់ប្រទេសកំណើតវិញ ក្រោយពីពួកគេបាន ជាប់ពន្ធនាគារនៅអាមេរិកតាមការកំណត់របស់តុលាការរួចហើយ។ អ្នកដែលត្រូវបាននិរទេសចេញពីអាមេរិកទាំង នោះ គឺត្រូវតែជាអ្នកមិនទាន់មានសញ្ជាតិអាមេរិក ទោះបីជាពួកគេបានមករស់នៅក្នុងទឹកដីសហរដ្ឋអាមេរិកអស់រ យៈពេលជាច្រើនឆ្នាំយ៉ាងណាក្តី។ ពួកគេភាគច្រើនមករស់នៅសហរដ្ឋអាមេរិកតាំងពីវ័យកុមារ មកជាមួយឪពុក ម្តាយក្នុងឋានៈជាជនភៀសខ្លួនក្រោយរបបខ្មែរក្រហមបានដួលរលំ។ ក្នុងករណីពលរដ្ឋខ្មែរដែលមានសញ្ជាតិអាមេរិ កហើយ ក្រោយពេលជាប់ទោស ពួកគេនឹងមិនអាចត្រូវបានបញ្ជូនចេញពីប្រទេសអាមេរិកឡើយ នេះបើផ្អែកតាម ច្បាប់អាមេរិក។

លោក អេរិន ធ្វាតជេស (Arend Zwartjes) អ្នកនាំពាក្យស្ថានទូតអាមេរិកប្រចាំក្រុងភ្នំពេញ បានប្រាប់ អាស៊ីសេរីតាមសារអេឡិកត្រូនិចកាលពីពេលថ្មីៗនេះថា សហរដ្ឋអាមេរិកនឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីទទួលយកពលរដ្ឋកម្ពុជាដែលពុំមានសិទ្ធិរស់នៅក្នុងសហរដ្ឋអាមេរិក។ លោកបន្ថែមទៀតថា ស្ថានទូតសហរដ្ឋ អាមេរិក បានផ្តល់ជំនួយឧបត្ថម្ភដល់អង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះថា អង្គការគាំពារពលរដ្ឋខ្មែរគ្មានទីពឹង ឬហៅ កាត់ថាខ្វាវ (KVAO) ដើម្បីជួយដល់ពលរដ្ឋខ្មែរដែលត្រូវបានបញ្ជូនមកវិញទាំងនេះ ធ្វើការសម្របខ្លួនក្នុងការរស់ នៅក្នុងសង្គមកម្ពុជា។

ថ្មីៗនេះមន្ត្រីអាជ្ញាធរអាមេរិក ដែលពាក់ព័ន្ធការបញ្ជូនជនជាតិខ្មែរទៅកាន់ប្រទេសកម្ពុជាវិញ បានប្រាប់សារ ព័ត៌មានបរទេសថា រហូតមកដល់ខែធ្នូ ឆ្នាំ២០១៧ មានពលរដ្ឋខ្មែរជិត ២.០០០នាក់ មានឈ្មោះក្នុងបញ្ជីដែលត្រូវ អាជ្ញាធរអាមេរិកនឹងបញ្ជូនត្រលប់ទៅកាន់ប្រទេសកម្ពុជាវិញ។ ភាគច្រើននៃពួកគេទាំងនេះ បានទទួលទោសពីបទ ឧក្រិដ្ឋនៅក្នុងប្រទេសអាមេរិក។

ពលរដ្ឋខ្មែរម្នាក់ដែលបានមករស់នៅក្នុងសហរដ្ឋអាមេរិកតាំងពីវ័យកុមារ ហើយត្រូវបានអាជ្ញាធរអាមេរិក បញ្ជូនទៅកាន់ប្រទេសកម្ពុជាវិញក្នុងឆ្នាំ២០០៤ និយាយថា លោកបានមករស់នៅក្នុងរដ្ឋកាលីហ្វញ៉ា (California) ទឹកដីអាមេរិកក្នុងឆ្នាំ១៩៨៤ ដែលកាលនោះលោកទើបមានអាយុ ៣ ឬ៤ឆ្នាំប៉ុណ្ណោះ។ លោក ហេង ខាល វិន (Calvin Heng) បន្តថា នៅពេលលោកមានអាយុ១៩ឆ្នាំ មានពេលមួយនោះ លោកមានទំនាស់ទាស់ទែងវាយ គ្នាជាមួយអ្នកផ្សេង ក៏ត្រូវបានអាជ្ញាធរអាមេរិកចាប់កាត់ទោសដាក់ពន្ធនាគារអស់ចំនួន ៤ឆ្នាំ រហូតដល់លោកអាយុ ២៣ឆ្នាំ។ សព្វថ្ងៃនេះលោកមានអាយុ ៣៧ឆ្នាំកំពុងរស់នៅក្នុងប្រទេសកម្ពុជា។ ក្រោយមកដល់ប្រទេសកម្ពុជា លោកក៏មានភរិយាជាជនជាតិអាមេរិកហើយមានកូនស្រីពីរនាក់ ម្នាក់អាយុ១០ឆ្នាំ និងម្នាក់ទៀតអាយុ១១ឆ្នាំ។ លោកថា បើទោះបីលោកមិនអាចវិលត្រលប់ទៅកាន់សហរដ្ឋអាមេរិកវិញក្តី តែភរិយានិងកូនស្រីរបស់លោកបានទៅ រស់នៅអាមេរិកដើម្បីអោយកូនៗបានសិក្សា និងរៀនសូត្រនៅទីនោះ តែពួកគេបានមកលេងលោកជារៀងរាល់ឆ្នាំ ពេលទំនេរពីការសិក្សា។ លោក ហេង ខាលវិន បន្ថែមទៀតថា ពេលលោកមកដល់ស្រុកខ្មែរដំបូង លោកជួបការ លំបាកច្រើនដោយសារតែលោកបានទៅរស់នៅអាមេរិកតាំងពីវ័យនៅក្មេង។ លោកថា ពេលមកដល់ស្រុកខ្មែរភ្លាម លោកបាននាំមិត្តភ័ក្តិដែលមកជាមួយគ្នា បង្កើតជាអង្គការស្ម័គ្រចិត្តជួយដល់ពលរដ្ឋកម្ពុជា អោយដឹងពីគ្រោះថ្នាក់នៃ ការប្រើប្រាស់គ្រឿងញៀន នឹងការឆ្លងជំងឺអេដស៍ ជាដើម។

លោក ហេង ខាលវិន ដែលបច្ចុប្បន្នកំពុងបំរើការនៅក្នុងក្រុមហ៊ុនមួយនាក្រុងភ្នំពេញ បន្ទាប់ពីលោកបានធ្វើ ការនៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍ អស់រយៈ៦ឆ្នាំក្នុងនាមជានាយកទីផ្សារ។ លោកបានអំពាវនាវអោយរដ្ឋាភិបាលអាមេ រិកកែសម្រួលផ្លូវច្បាប់ហើយបញ្ឈប់ការបញ្ជូនពលរដ្ឋខ្មែរដែលបានទៅរស់នៅអាមេរិកតាំងពីក្មេងៗ មកកាន់ប្រទេស

កម្ពុជាវិញ ព្រោះការបញ្ជូនពួកគេមកប្រទេសកម្ពុជាវិញជារឿងអយុត្តិធម៌ ដោយពួកគេត្រូវរស់នៅបែកក្រុមគ្រួសារ ប្រពន្ធកូន។ លោកថា ពលរដ្ឋខ្មែរដែលត្រូវបានបញ្ជូនមកដល់ប្រទេសកម្ពុជាវិញ គួរត្រូវបានផ្ដល់ឱកាសជាលើកទីពីរក្នុងការបានរស់នៅលើទឹកដីអាមេរិក។

លោកឧត្ដមសេនីយ៍ ម៉ៅ ចាន់តារា អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ថ្មីៗនេះត្រូវបានកាសែតភ្នំពេញប៉ុស្ដិ៍ ស្រង់សំដីចុះផ្សាយថា សមត្ថកិច្ចកម្ពុជាមានការខ្វះខាតសម្ភារៈនិងអាគារសម្រាប់ទទួលជនជាតិខ្មែរដែលអាជ្ញាធរអាមេរិកបញ្ជូនមកវិញ ដូចនេះធ្វើអោយមានការលំបាកខ្លាំង ក្នុងការធ្វើសមាហរណកម្មពួកគេទៅក្នុងសង្គមកម្ពុជា។ លោកថា ភាគីកម្ពុជាបានស្នើទៅខាងភាគីអាមេរិកអោយជួយផ្ដល់នូវអ្វីដែលកម្ពុជាត្រូវការ តែរហូតមកដល់ពេលនេះ កម្ពុជានៅតែមិនទាន់បានទទួលការឆ្លើយតបណាមួយពីភាគីសហរដ្ឋអាមេរិកនោះនៅឡើយទេ។ អាស៊ីសេរី បានព្យាយាមទាក់ទងមន្ត្រីអាជ្ញាធរកម្ពុជា ដើម្បីបញ្ជាក់បន្ថែមពីរឿងនេះ ប៉ុន្តែ ទូរស័ព្ទចូល ពុំមានអ្នកទទួល។

ទោះជាយ៉ាងណា អង្គការគាំពារពលរដ្ឋខ្មែរគ្មានទីពឹង ធ្វើការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរកម្ពុជាក្នុងការជួបដោយផ្ទាល់ជាមួយពលរដ្ឋខ្មែរ គ្រប់រូប នៅពេលដែលពួកគេត្រូវបានបញ្ជូនមកដល់កម្ពុជា ហើយជួយសម្រួលដល់ការទទួលបានឯកសារផ្សេងៗនៅក្នុងប្រទេសកម្ពុជា ដូចជាសំបុត្រកំណើត សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណជាដើម ហើយថាការសហការរបស់អាជ្ញាធរកម្ពុជាមានសារសំខាន់។

លោក តាន់ សូនិក ដែលជានាយកប្រតិបត្តិអង្គការគាំពារពលរដ្ឋខ្មែរគ្មានទីពឹង អោយដឹងថា អង្គការរបស់លោកទទួលជំនួយឧបត្ថម្ភដើម្បីធ្វើការងារនេះ ពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ហៅកាត់ថា យូសេដ (USAID) និងអង្គការនៃគណៈកម្មាធិការកណ្ដាល Mennomite។

កាលពីខែកញ្ញា ឆ្នាំ២០១៧ ក្រសួងការបរទេសសហរដ្ឋអាមេរិក បានផ្អាកផ្ដល់ទិដ្ឋាការដល់មន្ត្រីរដ្ឋាភិបាលនៃប្រទេសចំនួនបួន ដែលមិនព្រមសហការទទួលយកពលរដ្ឋរបស់ខ្លួនត្រលប់ទៅប្រទេសកំណើតវិញ ក្នុងនោះក៏មានប្រទេសកម្ពុជាផងដែរ។ ប្រទេសបីទៀតមកពីទ្វីបអាហ្វ្រិក មានប្រទេសអេរីថ្រេ (Eritrea) ហ្គីនេ (Guinea) និងប្រទេសសារ៉ាឡេអូន (Sierra Leone)។ ភ្លាមៗក្រោយអាមេរិកប្រកាសផ្អាកទិដ្ឋាការដល់មន្ត្រីរដ្ឋាភិបាលកម្ពុជា លោក ហ៊ុន សែន ក៏បានប្រកាសសងសឹកដល់អាមេរិកវិញដោយប្រកាសអោយផ្អាកនូវកិច្ចសហប្រតិបត្តិការជាមួយអាមេរិក ក្នុងការស្រាវជ្រាវរុករកអដ្ឋិធាតុទាហានអាមេរិកាំង ដែលបានស្លាប់កាលពីសម័យសង្គ្រាមនៅឥណ្ឌូចិន ដែលកាលនោះមានទាហានអាមេរិកជិត ១០០នាក់ បានបាត់ខ្លួននិងស្លាប់ ហើយដែលជិតពាក់កណ្ដាលនៃចំនួននេះ ត្រូវបានគេកំណត់អត្តសញ្ញាណនិងរកឃើញអដ្ឋិធាតុរួចមកហើយ។ នៅក្នុងខែកុម្ភៈកន្លងទៅនេះរាជរដ្ឋាភិបាលកម្ពុជា បានយល់ព្រមសហការជាមួយភាគីអាមេរិកវិញបន្ទាប់ពីបានជួបជាមួយមន្ត្រីក្រសួងការបរទេសអាមេរិក ដោយព្រមទទួលយកនូវពលរដ្ឋរបស់ខ្លួនពីអាមេរិកមកប្រទេសកម្ពុជាវិញ៕

## ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករបានចុះទៅសាកសួរសុខទុក្ខពលការិនី ថោង ច្រឹប ដែលបានទទួលរងគ្រោះថ្នាក់ក្នុងពេលបំពេញការងារ ខេត្តរ៉ាក់យ៉ង

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ ថ្ងៃទី ១៧ សីហា ២០១៨

នៅថ្ងៃសុក្រ ៦កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករបានចុះទៅខេត្តរ៉ាក់យ៉ង ដើម្បី សាកសួរសុខទុក្ខបងស្រី ថោង ច្រឹប ដែលបានទទួលរងគ្រោះថ្នាក់ក្នុងពេលបំពេញការងារ បណ្ដាលអោយបាត់បង់ម្រាមដៃចំនួន០១។ ជាមួយគ្នានេះដែរក្រុមការងារក៏បានពាំនាំនូវថវិកាមួយចំនួនជូនដល់បងស្រី និងទំនាក់ទំនងជាមួយអាជ្ញារធរពាក់ពន្ធ័ ក៏ដូចជានិយោជកដើម្បីដោះស្រាយសំណងជូនបងស្រីតាមនិតិវិធី។

# ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨

## កងកម្លាំងអាវុធហត្ថ ចុះយុទ្ធនាការបង្ក្រាបចំបែកសំបុកធ្វើអាជីវកម្មរកស៊ីផ្លូវភេទ

https://www.facebook.com/matemohachunnews/ August 18 2018 at 7:41 PM

ក្រុងព្រះសីហនុៈ ចុះចាប់កន្លែងរកស៊ីផ្លូវភេទរបស់កីកីក្នុងក្រុងព្រះសីហនុ លោកឧត្តមសេនីយ៍ត្រី ហេង ប៊ុនទី មេបញ្ជាការកងរាជអាវុធហត្ថខេត្តព្រះសីហនុ អោយដឹងថា នៅវេលាម៉ោងជិត១រំលងអាធ្រាត្រឆ្លងចូលថ្ងៃទីថ្ងៃទី១៨ ខែសីហាឆ្នាំ២០១៨ កម្លាំងមន្ទីរយុត្តិធម៌អាវុធហត្ថខេត្ត សហការជាមួយកម្លាំងអាវុធហត្ថក្រុងដឹកនាំដោយលោកវរសេនីយ៍ទោ ឆេង វុទ្ធី ប្រធានមន្ទីរយុត្តិធម៌អាវុធហត្ថខេត្ត និងលោកវរសេនីយ៍ទោ ហ៊ិត សីហា មេបញ្ជាការអាវុធហត្ថក្រុង ក្រោមការសម្របសម្រួលពីលោកព្រះរាជអាជ្ញារង រស់ សារាំ បានចុះបង្ក្រាបករណីសច្ចារកម្ម(ជួញដូរផ្លូវភេទ)មួយកន្លែងឈ្មោះ ម៉ាស្សាចិនស្ថិត នៅភូមិ៣ សង្កាត់លេខ៤ក្រុង ព្រះសីហនុ និងឃាត់ខ្លួនជនសង្ស័យចំនួន២១នាក់ ស្រី០៩នាក់ក្នុងនោះមានៈ ជនជាតិចិន ចំនួន១៦នាក់ ស្រី០៨នាក់ ជនជាតិខ្មែរ ចំនួន០៥នាក់ ស្រីម្នាក់ វត្ថុតាងរួមមានៈ ស្រោមអនាមយ័ប្រើប្រាស់រួចចំនួន២ ស្រោមអនាមយ័មិនទាន់ប្រើប្រាស់មួយចំនួនធំ-រថយន្តម៉ាកហាយលិនឌរ័មួយគ្រឿង។ បច្ចុប្បន្នជនសង្ស័យ ព្រមទាំងវត្ថុតាងកម្លាំងការិយាបទល្មើសជួញដូរមនុស្ស អ.ហខេត្តកំពុងធ្វើការសាកសួរបន្តនៅបញ្ជាការដ្ឋានអាវុធហត្ថខេត្ត៕

## កម្លាំងអាវុធហត្ថខេត្តព្រះសីហនុ ចាប់ឆ្លើមភាច់ចន្ទមចិនចំនួន១៦នាក់

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៨ ម៉ោង ០០:២៩ ឃឹម ប៊ុនណាក់

ខេត្តព្រះសីហនុ ៖ កម្លាំងសមត្ថកិច្ចកងរាជអាវុធហត្ថក្រុងព្រះសីហនុ កាលពីវេលាម៉ោង២រសៀល ថ្ងៃទី១៨ សីហា ២០១៨ ការិយាល័យបទល្មើសជួញដូរមនុស្ស បានបញ្ជូនជនសង្ស័យចំនួន១៦នាក់ (ស្រី០៨នាក់) ទៅកាន់សាលាដំបូងខេត្តព្រះសីហនុ ពាក់ព័ន្ធករណីប្រព្រឹត្តអំពើសញ្ចារកម្ម។ ជនសង្ស័យត្រូវកម្លាំងសមត្ថកិច្ចបង្ក្រាប និងឃាត់ខ្លួនកាលពីថ្ងៃទី១៧ សីហា នៅហាងយីហោម៉ាស្សាចិន ស្ថិតក្នុងភូមិ០៣ សង្កាត់៤ ក្រុង.ខេត្តព្រះសីហនុ។

ជនសង្ស័យទាំង១៦នាក់នេះរួមមាន៖ ១.ឈ្មោះ ជ័ង ម៉ីញឈិន ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិចិន មុខរបរម្ចាស់ហាងម៉ាស្សាចិន។ ២.ឈ្មោះ វ៉ន អ៊ីនយៀន ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិចិន។ ៣.ឈ្មោះ យ៉ាង ជឹកហ័រ ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិចិន។ ៤.ឈ្មោះ ស៊ី សិន ភេទប្រុស អាយុ២០ឆ្នាំ ជនជាតិចិន។ ៥.ឈ្មោះ YULI QING ភេទប្រុស អាយុ ៤៦ឆ្នាំ ជនជាតិចិន។ ៦.ឈ្មោះ ឆាវ ស៊ីរអ៊ឹង ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិចិន។ ៧.ឈ្មោះ YIN SONG PING ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិចិន។ ៨.ឈ្មោះ QIU LING MEI ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិចិន។ ៩.ឈ្មោះ ZHOU DONG YONG ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិចិន។ ១០.ឈ្មោះ ហ៊្កន អ៊ីម៉ី ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិចិន។ ១១.ឈ្មោះ ហ៊្វ មីុង ភេទស្រី អាយុ២៧ឆ្នាំ ជនជាតិចិន។ ១២.ឈ្មោះ MAO MEI YAN ភេទស្រី អាយុ២១ឆ្នាំ ជនជាតិចិន។ ១៣.ឈ្មោះ WANG WEIHOO ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិចិន។ ១៤.ឈ្មោះ YANG HONG YAN ភេទស្រី អាយុ៣០ឆ្នាំ ជនជាតិចិន។ ១៥.ឈ្មោះ PENG JING HONG ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិចិន។ ១៦.ឈ្មោះ WANG TAO ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិចិន រួមទាំងដកហូតបានវត្ថុតាងមាន៖ ស្រោមអនាម័យប្រើប្រាស់រួចចំនួន០២, ស្រោមអនាម័យមិនទាន់ប្រើប្រាស់មួយចំនួន, ប្រាក់ដុល្លារចំនួន ២៥០ដុល្លារអាមេរិក, ទូរស័ព្ទដៃចំនួន៥គ្រឿង និងរថយន្ត១គ្រឿង (ម៉ាកHIGHLANDER)។ មន្ត្រីជំនាញបានបញ្ជូនវត្ថុតាង និងជនសង្ស័យ ទៅកាន់សាលាដំបូងខេត្តព្រះសីហនុ ដើម្បីបន្តនីតិវិធី៕

## អាជ្ញាធរខណ្ឌដូនពេញចុះណែនាំម្ចាស់សណ្ឋាគារភ្នំពេញទី១ឱ្យបញ្ឈប់ជាបន្ទាន់ការចែករូបភាពអាសអាភាស និងបញ្ឈប់ការធ្វើអាជីវកម្ម

https://khmeread.com/ August 18, 2018 05:23PM

ភ្នំពេញ ៖ លោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ បានបញ្ជាឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះបិទទីតាំងម៉ាស្សា«ភ្នំពេញទីមួយ» និងតាមស្វែងរកចាប់ខ្លួនក្រុមដែលចែកខិត្តប័ណ្ណមានរូបស្រើបស្រាល ដើម្បីធ្វើការសាកសួរ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨។ ការដាក់បទបញ្ជានេះ គឺធ្វើឡើងក្រោយពីមានការរិះគន់តាមបណ្តាញសង្គមហ្វេសប៊ុក ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងទៅថ្មីៗនេះ។

នៅព្រឹកថ្ងៃទី១៨ សីហានេះ លោក ម៉ុក ច័ន្ទករុណា អភិបាលរងខណ្ឌដូនពេញ បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌ ចុះដល់ទីតាំងសណ្ឋាគារភ្នំពេញទី១ ដែលទើបនឹងសាងសង់រួចរាល់ ស្ថិតនៅទល់មុខសណ្ឋាគារកាំបូឌីយ៉ា ផ្លូវព្រះស៊ីសុវត្ថិ សង្កាត់ចតុមុខ ខណ្ឌដូនពេញ។ លោក ម៉ុក ច័ន្ទករុណា អភិបាលរងខណ្ឌដូនពេញបាននិយាយថា«គណបញ្ជាការឯកភាពខណ្ឌ បានចុះណែនាំម្ចាស់ទីតាំងឱ្យបញ្ឈប់ជាបន្ទាន់ពីការចែករូបភាពអាសអាភាស ដែលនាំឱ្យមានផលប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណីខ្មែរ និងបញ្ឈប់ការធ្វើអាជីវកម្មទៅលើទីតាំងខាងលើ រង់ចាំមានច្បាប់អនុញ្ញាតជាមុនសិន ទើបសម្រេចជាក្រោយ»។

គួររំលឹកថា ខិត្តប័ណ្ណរូបស្រីចិនស្លៀកសិចស៊ីបង្ហាញភាពស្រើបស្រាល និងរូបបុរសចិនស្រាតននលគោកជាច្រើនសន្លឹក ត្រូវបានដើរចេញនៅតាមតំបន់សំខាន់មួយចំនួន នៅក្នុងរាជធានីភ្នំពេញ និងតាមទីសាធារណៈផ្សេងៗមួយចំនួនទៀត ដែលធ្វើឱ្យប្រជាពលរដ្ឋមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ក្នុងខិត្តប័ណ្ណបែបនេះ គឺនាពេលកន្លងមកត្រូវបានដើរចែកយ៉ាងអនាធិបតេយ្យនៅក្នុងខេត្តព្រះសីហនុ ដែលជាខេត្តទេចរណ៍មួយសម្បូរទៅដោយភ្ញៀវទេសចរចម្រុះជាតិសាសន៍ ជាពិសេសជនជាតិចិនច្រើនជាងគេ។ ប៉ុន្តែករណីនេះ ត្រូវបានសមត្ថកិច្ចខេត្តព្រះសីហនុ ឃាត់ខ្លួនក្រុមអ្នកដើរចែក និងឈានទៅដល់ការបង្ក្រាបអ្នកប្រព្រឹត្តថែមទៀតផង។

បើតាមខិត្តប័ណ្ណដែលទទួលបាន គឺនៅក្នុងខិត្តប័ណ្ណនោះមានផ្ទៃពណ៌ផ្កាឈូក មានសរសេរអក្សរខ្មែរ " ភ្នំពេញទីមួយ" និងមានសរសេរអក្សរចិន និងអង់គ្លេស (Health massage) អមជាមួយ និងថែមទាំងមានដាក់លេខទូរស័ព្ទទំនាក់ទំនងថែមទៀតផង។ ជាពិសេសគឺបានដាក់រូបស្រីចិនស្លៀកពាក់សិចស៊ីលេចលើលេចក្រោមដែលបង្ហាញពីភាពស្រើបស្រាល។ ប៉ុន្តែអ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺនៅក្នុងខិត្តប័ណ្ណនោះ ក៏មានដាក់រូបបុរសចិនស្រាតននលគោក បម្រើសេវាម៉ាស្សាផងដែរ។

បើតាមស្ត្រីអ្នកបកប្រែនៅហាង ភ្នំពេញទីមួយ បានថ្លែងថា ខិត្តប័ណ្ណនេះ ចែកផ្សព្វផ្សាយអំពីការម៉ាស្សាសម្រាប់ ដោយក្នុងតម្លៃ ៧៥នាទី ថ្លៃ១៨០ដុល្លារ។ ហើយហាងភ្នំពេញទីមួយ នឹងបើកដំណើរការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ខាងមុខនេះ៕

## ស្ត្រី១០០នាក់ត្រូវបានសង្គ្រោះពីបណ្តាញជួញដូរមនុស្សនៅ Mexico

http://www.cen.com.kh/archives/ August 20, 2018

ស្ត្រីប្រមាណ១០០នាក់ដែលមកពីបណ្តាប្រទេសអាមេរិកឡាទីននិងអឺរ៉ុបខាងកើត ទើបត្រូវបានប៉ូលិសរំដោះពីផ្ទះបនមួយ។ ស្ត្រីពេស្យានៅតំបន់ Merced, Mexico City តាមAFP ដែលដកស្រង់សេចក្តីប្រកាសពីក្រសួង ជនរងគ្រោះត្រូវបានគេរកឃើញក្រោយការវាយឆ្មក់ កាលពីព្រឹកព្រលឹមថ្ងៃទី១៧សីហា នៅផ្ទះបនមួយនាទីក្រុង Mexico City។ ក្រុមស្ត្រីទាំងអស់នេះមកពីបណ្តាប្រទេស Mexico, Argentina, Brazil, Colombia, Paraguay, Venezuela, Hungary, Ukraine និងRussia ។ សមត្ថកិច្ចបានកម្ចាត់បណ្តាញជួញដូរស្ត្រីនិងផ្ទះបន

អស់ជាច្រើនក្នុងអំឡុងប៉ុន្មានខែមកនេះ។បណ្តាជនរងគ្រោះត្រូវបានពួកជនទុច្ចរិតអូសទាញថាទៅធ្វើជាតារាបង្ហាញម៉ូត ប៉ុន្តែក្រោយមកត្រូវបានចាប់ជំរិតនិងបង្ខំឱ្យលក់ខ្លួន។ មានស្រីជាច្រើនក្នុងចំណោមនោះ ពិសេសគឺមកពី Venezuela៕ សូយន

## មីយ៉ាន់ម៉ាត្រៀមបញ្ជូនពលករ៤០,០០០នាក់ ទៅបម្រើការងារនេសាទនៅប្រទេសថៃ ក្រោយទទួលបានការអនុគ្រោះ!

http://freshnewsasia.com/index.php/en/ 2018-08-17

**(រ៉ង់ហ្គូន)៖** មីយ៉ាន់ម៉ានឹងបញ្ជូនពលករចំណាកស្រុកចំនួន ៤០,០០០នាក់ ដើម្បីទៅធ្វើការក្នុងវិស័យឧស្សាហកម្មនេសាទនៅប្រទេសថៃ ក្រោមប្រព័ន្ធអនុស្សរណៈនៃការយោគយល់គ្នា ដែលស្របទៅតាមការសំណើរបស់ភាគីថៃ។ នេះបើតាមការដកស្រង់ការផ្សាយចេញពីទីភ្នាក់ងារព័ត៌មានចិន ស៊ីនហួរ នៅល្ងាចថ្ងៃសុក្រ ទី១៧ ខែសីហា ឆ្នាំ២០១៨។

បញ្ហាខាងលើនេះគឺជាប្រធានបទចម្បងគេ នៅក្នុងកិច្ចពិភាក្សាស្តីពីវិស័យការងាររវាងរដ្ឋមន្ត្រីការងារមីយ៉ាន់ម៉ាលោក យូ ធេន ស្វេ (U Thein Swe) និងសមភាគីថៃលោក អាឌុល សាសស៊ីកែវ (Adul Sangsingkeo) នៅរដ្ឋធានីណៃពិដោ នាថ្ងៃព្រហស្បតិ៍សប្តាហ៍នេះ។ កិច្ចពិភាក្សានោះក៏បានលើកឡើងពីករណី នៃការបញ្ជូនពលករដែលកាន់ទិដ្ឋាការក្លែងក្លាយ ដោយទីភ្នាក់ងារជួយរកការងារទាំងឡាយ ដែលរកស៊ីដោយគ្មានភាពស្មោះត្រង់ផងដែរ។ ក្រៅពីនេះរដ្ឋមន្ត្រីទាំងពីរ បានពិគ្រោះពីសហការសម្រាប់ការលើកកម្ពស់និងការពារសិទ្ធិរបស់ពលករចំណាកស្រុកមីយ៉ាន់ម៉ា នៅប្រទេសថៃថែមទៀតផង។

គួរជម្រាបថា នាដើមសប្តាហ៍នេះមីយ៉ាន់ម៉ានិងថៃ ក៏បានបើកកិច្ចប្រជុំលើកទី ០៩ នៃគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី នៅទីក្រុងណៃពិដោ ដែលមានរដ្ឋមន្ត្រីការបរទេសមីយ៉ាន់ម៉ា និងរដ្ឋមន្ត្រីការបរទេសថៃជាសហប្រធានផងដែរ៕

## ជប៉ុន ជ្រើសរើសអ្នកថែទាំបន្ថែម ពីប្រទេសអាស៊ីអាគ្នេយ៍ចំនួន៣

http://kleykley.sabay.com.kh/ ថ្ងៃនេះ ម៉ោង ០៩:៥៤

រដ្ឋាភិបាលជប៉ុន នឹងធ្វើការជ្រើសរើសអ្នកថែទាំ មកពីប្រទេស ឥណ្ឌូណេស៊ី ហ្វីលីពីន និងវៀតណាម ដែលអាចនិយាយភាសាជប៉ុនបានល្អ ចាប់ពីខែមេសា ឆ្នាំ២០១៩ តទៅ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ជាមួយទីក្រុងតូក្យូ។ ការសម្រេចនេះ គឺដោយសារកង្វះកម្លាំងពលកម្ម នៅក្នុងប្រទេសជប៉ុន។ ជប៉ុន នឹងជ្រើសរើសអ្នកថែទាំចំនួន ៣០០នាក់ ពីប្រទេសនីមួយៗ ក្នុងមួយឆ្នាំ។ ចំនួនអ្នកចង់ធ្វើការជាអ្នកថែទាំនៅជប៉ុន កំពុងកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជប៉ុន នឹងជួបវិបត្តិខ្វះអ្នកថែទាំ ជាង ៣៤ម៉ឺននាក់ នៅត្រឹមឆ្នាំ២០២៥ ស្របពេលដែលប្រជាពលរដ្ឋជប៉ុនដែលកើតក្នុងជំនាន់ដែលមានទារកកើតច្រើន ឈានដល់អាយុ៧៥ឆ្នាំ ឬចាស់ជាងនេះ។

សូមជម្រាបថា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី បានជួយឲ្យប្រជាជនប្រទេស ឥណ្ឌូណេស៊ី ហ្វីលីពីន និងវៀតណាម ទទួលបានការងារជាអ្នកថែទាំ នៅប្រទេសជប៉ុន ប្រហែល ៤៣០០នាក់។ ពួកគេអាចធ្វើការងារនេះរយៈពេល ៣ឆ្នាំ និងអាចចូលសិក្សាដើម្បីធ្វើការប្រឡង អំឡុងការស្នាក់នៅប្រទេសជប៉ុនរយៈពេល ៤ឆ្នាំ។ ប្រសិនបើប្រឡងជាប់ ពួកគេអាចបន្តការងាររបស់ពួកគេទៀតបាន៕

## ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨

## តុលាការបង្គាប់ឱ្យឃុំខ្លួនចិន៨នាក់ ខណៈអ្នកប្រព្រឹត្តល្មើសជាតិចិនមានច្រើនជាងគេ

https://www.postkhmer.com/ យុត សុភចរិយា | Publication date 20 August 2018 | 21:16 ICT

ព្រះសីហនុៈ មន្ត្រីនាំពាក្យសាលាដំបូងខេត្តព្រះសីហនុ លោក លឹម ប៊ុនហេង បានថ្លែងនៅថ្ងៃទី២០ សីហានេះថា បុរសជនជាតិចិន៨នាក់ក្នុងចំណោមមនុស្សប្រុស-ស្រី២១នាក់ដែលកងរាជអាវុធហត្ថខេត្តឃាត់ខ្លួនកាលពីថ្ងៃសៅរ៍នោះត្រូវបានតុលាការខេត្តព្រះសីហនុសម្រេចចោទប្រកាន់ពីបទ«ប្រព្រឹត្តអំពើសច្ចារកម្ម» និងបានបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារខេត្ត ខណៈជនល្មើសជាតិចិនមានច្រើនជាងក្នុងចំណោម២៥ជាតិសាសន៍។ បុរសជនជាតិចិនទាំង៨នាក់ រួមមាន ឈ្មោះ Jung Ming Chin អាយុ៣៣ឆ្នាំ ជាម្ចាស់ហាងម៉ាស្សាចិន, Yang Chekhov អាយុ២៣ឆ្នាំ, Shi Sin អាយុ២០ឆ្នាំ, YULI QING អាយុ៤៦ឆ្នាំ, WANG WEIHOO អាយុ១៥ឆ្នាំ, YIN SONG PING អាយុ៣២ឆ្នាំ, ZHOU DONG YONG អាយុ២៨ឆ្នាំ និង ម្នាក់ទៀតឈ្មោះ WANG TAO អាយុ២៣ឆ្នាំ។ ពួកគេទាំង៨នាក់ មានទីលំនៅបណ្ដោះអាសន្ននៅភូមិ៣សង្កាត់៤ ក្រុង-ខេត្តព្រះសីហនុ។ លោក ប៊ុន ហេង បានបញ្ជាក់ថា៖«ពេលនេះ ជនសង្ស័យទាំង៨នាក់ខាងលើនេះត្រូវបានសមត្ថកិច្ចនគរបាលយុត្តិធម៌នាំយកទៅឃុំខ្លួនជាបណ្ដោះអាសន្ន នៅពន្ធនាគារខេត្ត បន្ទាប់ពីចៅក្រមស៊ើបសួរ បានចោទប្រកាន់ពីបទ សច្ចារកម្ម»។ យោងបទចោទប្រកាន់ខាងលើនេះពួកគេនឹងប្រឈមការផ្ដន្ទាទោសជាប់ពន្ធនាគារក្នុងម្នាក់ៗយ៉ាងតិចរយៈពេល២ឆ្នាំ។

លោក ប៊ុន ហេង ក៏បានឲ្យដឹងផងដែរថា ចំពោះបុរស-ស្ត្រី១៣នាក់រួមទាំងពលរដ្ឋខ្មែរ៥នាក់ផងត្រូវបានតុលាការសម្រេចដោះលែងឲ្យមានសេរីភាពឡើងវិញ ដោយសារតុលាការរកឃើញថា ពួកគេជាជនរងគ្រោះ។ ក្នុងរយៈពេល៦ខែដើមឆ្នាំនេះជនជាតិចិនត្រូវបានរកឃើញថា ស្ថិតក្នុងលំដាប់ទី១ក្នុងចំណោមជនបរទេសចំនួន២៥ជាតិសាសន៍ដែលបានប្រព្រឹត្តបទល្មើសនៅកម្ពុជាជាពិសេសបទល្មើសគ្រឿងញៀន។ នេះតាមរបាយការណ៍របស់បណ្ដាញសារព័ត៌មានក្នុងស្រុកដែលបានដកស្រង់សម្ដី លោក ថោង លឹម អគ្គស្នងការរងនគរបាលជាតិកន្លងទៅនេះ។ លោកបានបញ្ជាក់ថា ជនបរទេសដែលបានប្រព្រឹត្តបទល្មើសលើទឹកដីកម្ពុជាក្នុងរយៈពេល៦ខែដើម ឆ្នាំ២០១៨នេះមានចំនួន៨៨ករណីក្នុងនោះ១៧ករណីជាបទល្មើសគ្រឿងញៀន ហើយត្រូវបានសមត្ថកិច្ចឃាត់ខ្លួន៣៧៨នាក់ដែលមាន២៥ ជាតិសាសន៍ក្នុងនោះជនជាតិចិនមាន«ច្រើនជាងគេ»គឺមាន២៥៧នាក់, នីហ្សេរីយ៉ា ៣៧នាក់, វៀតណាម ១៤នាក់, ថៃ ១២នាក់ និងកូរ៉េខាងត្បូង ៨នាក់។ ភូមិសាស្ត្រដែលកើតមានច្រើនជាងគេគឺនៅរាជធានីភ្នំពេញ»។

លោក គៀត ច័ន្ទថារិទ្ធ អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិនៅថ្ងៃទី២០សីហានេះក៏បានថ្លែងស្រដៀងគ្នាដែរថាតួលេខនៃរបាយការណ៍ខាងលើនេះគឺអគ្គស្នងការនគរបាលជាតិប្រមូលបានពីតាមបណ្ដាខេត្ត និងរាជធានីទាំង២៥នៅទូទាំងប្រទេសកម្ពុជា ហើយថាវាជារបាយការណ៍«ត្រឹមត្រូវ»។

ជុំវិញករណីនេះ ក្រុមអ្នកវិភាគសង្គមជាច្រើនបានលើកឡើងថា វត្តមានរបស់ជនជាតិចិនមិនមានអ្វីគួរឲ្យបារម្ភឬភ័យខ្លាចនោះទេប្រសិនបើអាជ្ញាធរពាក់ព័ន្ធពង្រឹងការអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវ និងទទួលខុសត្រូវចំពោះមុខងាររបស់ខ្លួន។ លោក សន ជ័យ នាយកប្រតិបត្តិអង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជាបានកោតសរសើរនិងលើកទឹកចិត្តចំពោះសមត្ថកិច្ចចំពោះការប្រឹងប្រែងចុះបង្ក្រាបចាប់ជនបរទេសដែលបានប្រព្រឹត្តបទល្មើសផ្សេងៗនៅកម្ពុជាក្នុងនោះរួមមានបទល្មើស គ្រឿងញៀន ជួញដូរផ្លូវភេទ ចាប់ជំរិត ឃាតកម្ម លួច ប្លន់ និងបទល្មើសគ្រោះថ្នាក់ចរាចរណ៍ដើម្បីភាពសុខសាន្តរបស់ពលរដ្ឋកម្ពុជា។ ប៉ុន្តែ លោក សន ជ័យ ក៏បានរិះគន់ផងដែរថា៖«ការអនុវត្តច្បាប់របស់មន្ត្រីពាក់ព័ន្ធហាក់នៅមានភាពធូររលុង ដោយបានបណ្ដែតបណ្ដោយឲ្យជនបរទេសពិសេសជនជាតិចិនធ្វើសកម្មភាពបំពាបំពានច្បាប់កម្ពុជាដូចជាជួលរថយន្តពាក់ស្លាកលេខ(ខ.ម) និង (ន.ប) ទៅជិះហើយប្រព្រឹត្តបទល្មើសចរាចរណ៍ជាដើម»។

ចំណែក លោក ហង្ស វិទូ ប្រធានក្រុមវេទិកាអ្នកវិភាគវ័យក្មេង បានលើកឡើងថា វត្តមានរបស់ជនជាតិចិនដែលកំពុងបង្កភាពអនាធិបតេយ្យនៅកម្ពុជានាពេលថ្មីនេះបានបង្ហាញថា ប្រទេសកម្ពុជាកំពុងជួបនូវវិបត្តិសង្គមធ្ងន់ធ្ងរដោយសារភាពខ្វះចន្លោះនៃការអនុវត្តច្បាប់របស់មន្ត្រីពាក់ព័ន្ធកម្ពុជា។ លោកបានបន្តថា៖«ប្រសិនជាគ្រប់ស្ថាប័នពាក់ព័ន្ធមានការគោរព និងអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវនិងត្រូវញែកឲ្យដាច់ពីទំនាក់ទំនងមិត្តភាពនៃប្រទេសទាំងពីរកម្ពុជា-ចិនទៅនឹងរឿងបុគ្គលដែលប្រព្រឹត្តបទល្មើសដោយចាត់វិធានការឲ្យបានតឹងរ៉ឹងទៅតាមនីតិវិធីច្បាប់និងដោយគ្មានការលើកលែងនោះជនជាតិចិនដែលខិលខូចនឹងមិនអាចមានវត្តមាននៅកម្ពុជាឬ ប្រព្រឹត្តបទល្មើសបានទេ»៕

## រឿងខិត្តប័ណ្ណឃោសនាពាណិជ្ជកម្មបែបស្រើបស្រាលៈមេប៉ូលិសបញ្ជាឲ្យស្នងការនគរបាលរាជធានី-ខេត្តបង្ក្រាប

http://www.rasmeinews.com/ August 21, 2018, 11:36 AM

ដោយៈមុនីរ័ត្ន/ ភ្នំពេញៈ នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានបញ្ជាឲ្យស្នងការនគរបាលរាជធានី ខេត្ត ទាំង២៥ ធ្វើការទប់ស្កាត់ និងបង្ក្រាបក្រុមជនជាតិចិនដើរចែកខិត្តប័ណ្ណដែលមានរូបស្រីចិនស្លៀកពាក់សិចស៊ីបង្ហាញពីភាពស្រើបស្រាលបង្កប់ការរកស៊ីផ្លូវភេទ កុំឲ្យកើតមាននៅក្នុងទឹកដីរបស់ខ្លួន។ ការបញ្ជាឲ្យទប់ស្កាត់នេះ គឺបន្ទាប់ពីកើតមានករណីក្រុមជនជាតិចិនដើរចែកខិត្តប័ណ្ណរូបស្រីចិនស្លៀកសិុចស៊ីនៅខេត្តព្រះសីហនុ និងរាជធានីភ្នំពេញ។

នាយឧត្តមសេនីយ៍ គៀត ច័ន្ទថារិទ្ធ អគ្គស្នងការរងនគរបាលជាតិ បានថ្លែងថា ប៉ុន្មានថ្ងៃចុងក្រោយនេះ នៅខេត្តព្រះសីហនុ និងនៅរាជធានីភ្នំពេញប៉ុន្តែដោយឡែកនៅខេត្តព្រះសីហនុ មានជនជាតិចិនដើរចែកផ្សាយក្រដាសឃោសនាកន្លែងម៉ាស្សា ប៉ុន្តែនៅលើក្រដាសនោះ មានបោះពុម្ពរូបភាពនារីបង្ហាញពីភាពសិុចស៊ីជាការទាក់ទាញរបៀបជួញដូរផ្លូវភេទ ឬក៏ជារបៀបទាក់ទាញឲ្យមានការដោះដូរផ្លូវភេទជាដើម តែបានធ្វើការឃាត់ចាប់បង្ក្រាប និងធ្វើការអប់រំជនជាតិចិនចំនួន៦នាក់។ ហើយនៅភ្នំពេញក៏កើតមានករណីនេះស្រដៀងគ្នានេះដែរ។ លោកបានបញ្ជាក់ថា តាមគោលការណ៍របស់នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ គឺសូមឲ្យស្នងការនគរបាលរាជធានី ខេត្ត ទាំងអស់ បង្កើនការត្រួតពិនិត្យចំពោះបញ្ហានេះ កុំឲ្យកើតមាននៅតាមរាជធានី ខេត្ត ដែលខ្លួនទទួលខុសត្រូវ។ ហើយបើសិនជាជួបប្រទះសកម្មភាពបែបនេះ គឺត្រូវចាត់វិធានការដើម្បីឃាត់ធ្វើការស៊ើបអង្កេតស្រាវជ្រាវឲ្យដល់ឫសគល់ជាបន្ទាន់ និងទប់ស្កាត់ បង្ក្រាបសភាពការណ៍នេះ កុំឲ្យកើតមានឡើងជាថ្មី៕ **សរន**

## ក្រសួងការងារប្រាប់ឲ្យជនបរទេសទាំងថៅកែ និងពលករ ចុះបញ្ជីនៅក្រសួង

http://wmc.org.kh/ ថ្ងៃអង្គារ ទី២១ ខែសីហា ឆ្នាំ២០១៨ លៀ ស៊ីណា

ភ្នំពេញ ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី២០ ខែសីហា ម្សិលមិញ បានចេញសេចក្តីជូនដំណឹងមួយស្តីពីការស្នើសុំការអនុញ្ញាតិប្រើប្រាស់ហត្ថពលកម្មបរទេស (ពលករបរទេស) និងពន្យារសុពលភាពបណ្ណ ឬសៀវភៅការងារជនបរទេសសម្រាប់ឆ្នាំ២០១៩។ ក្រសួងការងារបានប្រាប់ឲ្យដឹងថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងជនបរទេសទាំងអស់ ដែលមានសេចក្តីត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ២០១៩ ត្រូវដាក់សំណើរ សុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨។ ដោយឡែកសម្រាប់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដែលបានប្រើប្រាស់ហត្ថពលកម្មបរទេសនាពេលកន្លងមក ក៏ដូចជាជនបរទេស ដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទពន្យារសុពលភាពបណ្ណ ឬសៀវភៅការងារជនបរទេសសម្រាប់ឆ្នាំ២០១៩ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ កាលពីដើមឆ្នាំ២០១៨កន្លងទៅនេះ បានបញ្ជាក់ថា ជនបរទេសដែលកំពុងស្នាក់នៅ និងធ្វើការនៅកម្ពុជាមានជាង ១៦ម៉ឺននាក់ ក៏ប៉ុន្តែមានជនបរទេសប្រមាណតែ ៥ម៉ឺន ៧ពាន់នាក់តែប៉ុណ្ណោះ ដែលមានប័ណ្ណការងារស្របទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។ សម្តេច ការដែលមានជនបរទេសធ្វើការងារនៅកម្ពុជា ដោយមិនបានបង់ពន្ធជូនរដ្ឋ គឺវាបានធ្វើឲ្យបាត់បង់ចំណូលរបស់រដ្ឋ និងឱកាសការងាររបស់ពលរដ្ឋខ្មែរ។ សម្តេចបន្តថា លើសពីនេះ រដ្ឋាភិបាលបានបាត់បង់ប្រាក់ចំណូលក្នុងមួយឆ្នាំៗ ជាង ២០លានដុល្លារ ព្រោះតែជនបរទេស ទាំងថៅកែ និងពលករ មួយចំនួនមិនបានបង់ពន្ធជូនរដ្ឋ។

ក្រសួងការងារ បានអះអាងថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយ និងជនបរទេស ដែលប្រកបមុខរបរណាមួយនៅកម្ពុជា ដែលមិនបានអនុវត្តត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ក្រសួងនឹងចាត់វិធានការអនុវត្តការផាកពិន័យតាមទោសប្បញ្ញត្តិដែលមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ៕

## វិទ្យុជាតិថៃគ្រោងផ្សាយកម្មវិធីជាភាសាខ្មែរ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៨ម៉ោង ១៤:៣៣ចន ណារិទ្ធ

រាជធានីភ្នំពេញ ៖ វិទ្យុជាតិថៃគ្រោងផ្សាយកម្មវិធីភាសាខ្មែរឡើងវិញ ដើម្បីជាប្រយោជន៍ដល់បងប្អូនប្រជាជនកម្ពុជា ដែលកំពុងស្នាក់នៅ និងកំពុងបំរើការងារនៅក្នុងប្រទេសថៃ ឱ្យកាន់តែច្រើនឡើង ។ នៅក្នុងជំនួបរវាងគណៈប្រតិភូវិទ្យុជាតិកម្ពុជា និងវិទ្យុជាតិថៃនៅឯប្រទេសថៃ លោកស្រីសូមន្តផាន កូសុនសិរីសិទ្ធ ប្រធានផលិតកម្មវិធីនៃវិទ្យុជាតិថៃ បានឱ្យដឹងថា វិទ្យុជាតិថៃនឹងខិតខំស្នើកញ្ចប់ថវិកាពីរាជរដ្ឋាភិបាលរបស់ខ្លួន ដើម្បីបើកដំណើរការផ្សាយកម្មវិធីភាសាខ្មែរឡើងវិញ បន្ទាប់ពីបានបិទមួយរយៈ ។ លោកស្រីបន្ថែមថា កម្មវិធីនេះ អាចធ្វើឡើងក្នុងរយៈពេល១៥នាទី ដែលផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធទៅនឹងបញ្ហាច្បាប់ថ្មីៗរបស់អាជ្ញាធរថៃ និងព័ត៌មានផ្សេងៗទៀតដើម្បីជាប្រយោជន៍ដល់មន្ត្រីកាទូត អ្នកទេសចរ អ្នកជំនួញ និងពលករកម្ពុជា បានដឹងជ្រួតជ្រាប ។ ទាំងនេះគឺជាកក្តាចម្បង ដែលធានាបានសុវត្ថិភាព និងភាពស្របច្បាប់ ។

លោកចាន់ ភារ៉ា ប្រធាននាយកដ្ឋានផ្សាយទៅបរទេសនៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា បានគាំទ្រទាំងស្រុងចំពោះគម្រោងបើកការផ្សាយកម្មវិធីភាសាខ្មែរឡើងវិញ នៅក្នុងម៉ោងណាមួយនៃវិទ្យុជាតិនេះ គឺជាការបង្ហាញពីការយកចិត្តទុកដាក់ ចំពោះប្រជាពលរដ្ឋខ្មែរដែលកំពុងស្នាក់នៅក្នុងប្រទេសថៃ អោយទទួលបានព័ត៌មានកាន់តែទូលំទូលាយ ។

## អ៊ីតាលី គំរាមបញ្ជូនជនចំណាកស្រុក ១៨០ នាក់ទៅលីប៊ីវិញ

https://www.postkhmer.com/ AFP | Publication date 21 August 2018 | 09:40 ICT

**ក្រុងរ៉ូមៈ** រដ្ឋមន្ត្រីមហាផ្ទៃអ៊ីតាលីកាលពីថ្ងៃអាទិត្យ បានគំរាមបញ្ជូនមនុស្សប្រហែល ១៨០ នាក់ ដែលជាប់ ៣ ថ្ងៃនៅលើនាវារបស់ឆ្មាំសមុទ្រអ៊ីតាលីត្រឡប់ទៅប្រទេសលីប៊ីវិញប្រសិនបើ EU មិនចូលរួមជួយដោះស្រាយបញ្ហាជនចំណាកស្រុកជាមួយប្រទេសម៉ាល់ត៍ទេនោះ។ មនុស្ស ១៧៧ នាក់ បានជាប់នៅកោះ Lampedusa របស់អ៊ីតាលី ចាប់តាំងពីថ្ងៃព្រហស្បតិ៍ ក្រោយពីត្រូវបានជួយសង្គ្រោះដោយនាវា Diciotti របស់ឆ្មាំសមុទ្រហើយអ៊ីតាលីកំពុងធ្វើការជាមួយប្រទេសម៉ាល់ត៍ថាតើនរណាគួរទទួលយកពួកគេ? នៅក្នុងសេចក្តីថ្លែងការណ៍មួយលោក Salvini បានថ្លែងថា៖«អឺរ៉ុបក៏បានសម្រេចចិត្តជួយប្រទេសអ៊ីតាលី ដោយបានចាប់ផ្តើមជាមួយជនចំណាកស្រុក ១៨០ នាក់ដែលនៅលើនាវា Diciotti នោះ ហើយយើងនឹងត្រូវបង្ខំចិត្តធ្វើអ្វីដែលនឹងបញ្ចប់ជំនួញរបស់ក្រុមអ្នកជួញដូរមនុស្ស។ នោះមានន័យថា នាំមនុស្សដែលត្រូវបានជួយនៅក្នុងសមុទ្រត្រឡប់ទៅប្រទេសលីប៊ីវិញ»។ ការរំលោភសិទ្ធិមនុស្សច្រើនរាប់មិនអស់ ត្រូវបានរាយការណ៍នៅក្នុងមជ្ឈមណ្ឌលឃុំឃាំង ដែលឃុំខ្លួនក្រុមជនចំណាកស្រុកដែលសង្ឃឹមថានឹងធ្វើដំណើរឆ្លងមហាសមុទ្រមេឌីទែរ៉ាណេ និងទៅដល់អឺរ៉ុប។ នាវា Diciotti ត្រូវបានចតនៅឆ្នេរ Lampedusa

ខណៈរដ្ឋាភិបាលអ៊ីតាលី ដែលបានឡើងកាន់តំណែង តាំងពីខែមិថុនាបានទាមទារថា ប្រទេសម៉ាល់ត៍ គួរតែទទួលយកអ្នកដំណើរទាំងនោះ៕

## ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨

### នគរបាលខេត្តមណ្ឌលគិរី ចុះអប់រំផ្សព្វផ្សាយអំពីច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ

http://cambodiapolice.com/policekh/ 5:20 pm 21 សីហា 2018

មណ្ឌលគិរី ៖ នៅវេលាម៉ោង៨និង០០នាទីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ លោកស្រីឧត្តមសេនីយ៍ ហួន គឹម ហេង ស្នងការរងទទួលផែនយេនឌ័រ លោកវរសេនីយ៍ទោ នន់ សុវណ្ណារ៉ា នាយការិយាល័យប្រឆាំងការជួញដូរមនុស្ស ព្រមទាំងសហការី បានអញ្ជើញចុះមកប្រជុំពិភាក្សា និងសហការជាមួយកម្លាំងអធិការកម្លាំងប៉ុស្តិ៍ស្រែខ្ទុម ដើម្បីចុះធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពីការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ព្រមទាំងស្ត្រីបម្រើការងារខារ៉ាអូខេ និងផ្ទះសំណាក់ ៕

### ជំនាញអាវុធហត្ថឃាត់ខ្លួនម្តាយ និងកូននាំទៅតុលាការ ពាក់ព័ន្ធជួញដូរអនីតិជន

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៨ ម៉ោង ០០:០១ យឹម ប៊ុនណាក់

រាជធានីភ្នំពេញ៖ ព័ត៌មានបឋមបានឲ្យដឹងថា កាលពីរសៀលថ្ងៃទី២១ សីហា កម្លាំងសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃទីបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានបញ្ជូន ជនសង្ស័យ២នាក់ម្តាយ និងកូនស្រី ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ ដែលជាករណីពាក់ជួញដូរអនីតិជន ក្រោមអាយុ១៥ឆ្នាំ។ នារសៀលថ្ងៃដដែលនេះ តំណាងអយ្យការមិនទាន់បានសាកសួរ ជនសង្ស័យ២នាក់ម្តាយ និងកូនចប់សព្វគ្រប់នៅឡើយទេ ហើយបានប្រគល់ឲ្យទៅកងរាជអាវុធហត្ថគ្រប់គ្រងវិញ តម្រូវឲ្យព្រឹកថ្ងៃទី២២ សីហា នាំមកសាកសួរបន្តទៀត។ ជនសង្ស័យត្រូវបានសមត្ថកិច្ចការិយាល័យប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន កងរាជអាវុធហត្ថរាជធានីភ្នំពេញ ឃាត់ខ្លួនកាលពីថ្ងៃទី១៩ សីហា ដែលពាក់ព័ន្ធលើបណ្តឹង របស់អាណាព្យាបាលក្មេងស្រី៤នាក់ ក្នុងនោះមាន៣នាក់ អាយុមិនដល់៧ឆ្នាំផង និងម្នាក់អាយុ១៣ឆ្នាំ។ ជនសង្ស័យបាននាំក្មេងស្រី៤នាក់នោះ ជួញដូរដោយមានគោលដៅ ពោលគឺយកទៅបម្រើការងារតាមផ្ទះជាថ្នូរនឹង ទទួលបានប្រាក់មកវិញ៕

### ឯកឧត្តម ឡុង វិសាលោ ឯកអគ្គរាជទូត ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃឡង់ដ៍ ចុះទៅសួរសុខទុក្ខបងប្អូនពលករខ្មែរ ដែលបានរងគ្រោះដោយសារ អគ្គីភ័យឆេះអគារស្នាក់នៅរបស់បងប្អូនពលករ

https://www.facebook.com/Royal-Embassy-of-Cambodia-in-Bangkok- 21/08/2018

កាលពីថ្ងៃច័ន្ទ ទី០៩កើត ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃច័ន្ទ ទី២០ ខែសីហា ឆ្នាំ ២០១៨ ឯកឧត្តម ឡុង វិសាលោ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសម្តភាពនៃស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃឡង់ដ៍ បានដឹកនាំមន្ត្រីស្ថានទូតចុះទៅសួរសុខទុក្ខបងប្អូនពលករខ្មែរកំពុងធ្វើការថ្នែកសំណង់ ប្រហែល ២៥០នាក់ ដែលបានរងគ្រោះដោយសារ អគ្គីភ័យឆេះអគារស្នាក់នៅរបស់បងប្អូនពលករខ្មែរនៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៨។

## ឧស្សាហកម្មនេសាទថៃ ត្រូវការពលករមីយ៉ាន់ម៉ាចំនួន ៦ម៉ឺននាក់

http://kleykley.sabay.com.kh/ ថ្ងៃទី ២១ សីហា ២០១៨ ម៉ោង ១៦:៣៤

ប្រទេសថៃនឹងជ្រើសរើសពលករមីយ៉ាន់ម៉ាប្រមាណ ៦ម៉ឺននាក់ ដើម្បីបំពេញការងារក្នុងឧស្សាហកម្មនេសាទរបស់ខ្លួន។ នេះការលើកឡើងរបស់រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Adul Sangsingkeo ទៅអ្នកសារព័ត៌មាន អំឡុងទស្សនកិច្ចរបស់លោកនៅទីក្រុង Nay Pyi Taw ប្រទេសមីយ៉ាន់ម៉ា កាលពីពេលថ្មីៗនេះ។ យោងតាមសារព័ត៌មាន Myanmar Time នៅថ្ងៃទី ២១ សីហានេះ បានដកស្រង់សម្ដីរបស់លោក Adul Sangsingkeo ថា គម្រោងជ្រើសរើសពលករមីយ៉ាន់ម៉ា នឹងត្រូវបង្កើតឡើង បន្ទាប់ពីប្រទេសទាំង២ សម្រេចចុះអនុស្សារណៈយោគយល់គ្នា ទៅលើសិទ្ធិការពារពលករនេសាទ។ ប្រភពដដែលបានឲ្យដឹងទៀតថា ភាគីទាំង២ ក៏បានពិភាក្សាគ្នា ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងរវាងប្រទេសទាំង២ ស្វែងរកវិធីដើម្បីផ្ញើប្រាក់ត្រឡប់ទៅកាន់មីយ៉ាន់ម៉ាដោយស្របច្បាប់ និងយកចិត្តទុកដាក់លើពលករទាំងក្នុងស្រុក និងក្រៅស្រុក ដែលកំពុងធ្វើការក្នុងប្រទេសថៃ។ រដ្ឋមន្ត្រីក្រសួងការងារមីយ៉ាន់ម៉ា លោក U Thein Swe បាននិយាយថា រដ្ឋាភិបាល ចង់ធានាឲ្យបានថា ពលករមីយ៉ាន់ម៉ា មានការការពារស្របច្បាប់ មុននឹងបញ្ជូនពួកគេទៅធ្វើការនៅប្រទេសថៃ។ គួរបញ្ជាក់ដែរថា ពលករមីយ៉ាន់ម៉ាច្រើនជាង ៤ម៉ឺននាក់ កំពុងធ្វើការនៅក្នុងឧស្សាហកម្មនេសាទថៃ និងច្រើនជាង ៤៥០០០ នាក់ កំពុងធ្វើការនៅឧស្សាហកម្មផ្សេងៗទៀត។ ចំណែកឯ ពលករប្រមាណ ៥៨ ៧៤១នាក់ផ្សេងទៀត កំពុងធ្វើការនៅក្នុងបណ្ដារោងចក្រផលិតផល ដែលនេសាទពីសមុទ្រ៕

# ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨

## កម្ពុជា-ថៃ មានទំនាក់ទំនងល្អ ក្នុងការទប់ស្កាត់ ការកាប់បំផ្លាញ ព្រៃឈើ

https://www.dap-news.com/kh/ ថ្ងៃពុធ, ២២ សីហា ២០១៨ 17:43 ដោយ: ធី លីថូ ID:115

ភ្នំពេញ៖សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានលើកឡើងថា កម្ពុជា-ថៃ នឹងបន្តកិច្ចសហ ប្រតិបត្តិការ ល្អជាមួយគ្នា ក្នុងការទប់ស្កាត់ការ កាប់ព្រៃឈើ របស់ប្រជាពលរដ្ឋកម្ពុជា នៅលើទឹកដីថៃ។ សម្ដេចបានថ្លែងក្នុងជំនួបជាមួយ លោក Panyarak poolthup ឯកអគ្គរាជទូតថៃទើបតែងតាំងថ្មី នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨ថា "ខ្ញុំសូមអបអរសាទរចំពោះថៃ ក្នុងការធ្វើកិច្ចសហការ បានល្អ ជាមួយកម្ពុជាក្នុងការទប់ស្កាត់ ការចូលកាប់ ឈើខុសច្បាប់ របស់ពលរដ្ឋខ្មែរ នៅលើទឹកដីថៃ ដែលយើង បានសហការគ្នា បានល្អប្រសើរ"។

ក្នុងឱកាសនោះដែរ ភាគីថៃក៏បាន អរគុណដល់កម្ពុជា ក្នុងការធ្វើកិច្ច សហប្រតិបត្តិការល្អ រវាងរាជរដ្ឋាភិបាលកម្ពុជា និងថៃ និងរវាងក្រសួងមហាផ្ទៃកម្ពុជា ជាមួយស្ថានទូតថៃប្រចាំកម្ពុជា ដែលបានបង្កលទ្ធភាព គ្រប់បែបយ៉ាង ជួយដល់ ប្រជាពលរដ្ឋថៃរស់ នៅលើទឹកដីកម្ពុជា ៕

## កម្ពុជា ថ្លែងអំណរគុណចំពោះភាគីថៃ ដែលបានជួយសម្រួលដល់ពលករកម្ពុជាឲ្យមានភាពល្អប្រសើរជាងមុន

http://cambodiapolice.com/policekh/ 6:09 pm 22 សីហា 2018

ភ្នំពេញ ៖ ថ្លែងនៅក្នុងកិច្ចជំនួបជាមួយលោក Panyarak poolthup ឯកអគ្គរាជទូតថៃ ដែលទើបតែងតាំងថ្មីប្រចាំនៅកម្ពុជានារសៀលថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨នេះ នៅទីស្ដីការក្រសួងមហាផ្ទៃ សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងអំណរ អគុណចំពោះភាគីថៃដែលបានយកចិត្ត

ទុកដាក់ជួយសម្រួលដល់ពលករកម្ពុជា ដែលកំពុងធ្វើការនៅប្រទេសថៃឲ្យមានភាពល្អប្រសើរជាងមុនខណៈដែលពលករខ្លះនៅតែធ្វើការមិនទាន់ស្របច្បាប់នៅឡើយ ។

ក្នុងជំនួបនេះដែរ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថាប្រទេសថៃគឺជាមិត្តល្អនិងជាប្រទេសភូមិផងរបងតែមួយជាមួយកម្ពុជា ហើយក៏បានជួយដល់ពលករកម្ពុជាជាច្រើនឲ្យមានភាពល្អ ប្រសើជាងមុនផងដែរ ។ ជាមួយគ្នានោះដែរ សម្តេចក្រឡាហោម ស ខេង ក៏បានសម្តែងការអបអរសាទរចំពោះអាជ្ញាធរនៃប្រទេសទាំងពីរដែលបានខិតខំទប់ស្កាត់ពលរដ្ឋខ្មែរដែលបានចូលទៅទឹកដីថៃ ដោយខុសច្បាប់ផងដែរ។

ថ្លែងនៅក្នុងកិច្ចជំនួបនោះដែរ លោក Panyarak poolthupបានលើកឡើងថាប្រទេសថៃ គឺជាមិត្តដ៏ល្អជាមួយកម្ពុជា ហើយថៃនៅតែបន្តពង្រឹងកិច្ចសហប្រតិបត្តការជាមួយកម្ពុជាគ្រប់ ពេលវេលាជាពិសេសគឺដើម្បីផលប្រយោជន៍ ចំពោះប្រជាជននៃប្រទេសទាំងពីរតែម្តង ៕

## កសិដ្ឋានកម្សាន្តចម្ការផ្លែឈើថៃ ផ្តល់ឱកាសការងារច្រើនដល់ពលករខ្មែរផ្នែកកសិកម្ម និងសេវាទេសចរណ៍

http://akp.gov.kh/kh/archives/ AKP រ៉ាក់យ៉ង, ប្រទេសថៃ ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០១៨

កសិដ្ឋានកម្សាន្តចម្ការផ្លែឈើថៃឈ្មោះ Suphattraland Rayong ស្ថិតនៅភូមិ Tambol Nong La Lok ស្រុក Bankai ខេត្ត Rayong បានផ្តល់ឱកាសការងារច្រើនដល់ពលករខ្មែរផ្នែក កសិកម្ម និងសេវាទេសចរណ៍។ លោក Chotchai Buadit អ្នកគ្រប់គ្រងទូទៅ នៃកសិដ្ឋានកម្សាន្តចម្ការផ្លែឈើ Suphattraland Rayong បានប្រាប់ទីភ្នាក់សារព័ត៌មានកម្ពុជាឱ្យដឹងនាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៨នេះថា បច្ចុប្បន្ននេះនៅក្នុងចំការរបស់លោកមានពលករខ្មែរចំនួន១៥០នាក់កំពុងធ្វើការងារផ្នែកថែទាំដំណាំហូបផ្លែ មានធុរេន សាវម៉ាវ មៀន មង្ឃុត ខ្នុរ ល្ហុង និងឈើហូបមួយចំនួនទៀតសរុបទាំងអស់២៥ប្រភេទ។ លោកបានបន្តថា ពលករខ្មែរដែលធ្វើនៅក្នុងចម្ការរបស់លោកមានអ្នកខ្លះមកធ្វើការជិត១០ឆ្នាំហើយ និងខ្លះទៀតទើបនឹងជ្រើសរើសចូលថ្មី ដោយបំពេញការងារផ្សេងៗពីគ្នាដោយមួយចំនួនថែទាំដើមឈើ និងមួយចំនួនទៀតបើកបររថយន្តដឹកភ្ញៀវកម្សាន្តផ្លែឈើក្នុងចម្ការ និងខ្លះទៀតជាអ្នករៀបចំប៊ូហ្វេផ្លែឈើ និងបុកល្ហុងទទួលភ្ញៀវ ទេសចរដែលជិះរថយន្តទស្សនាក្នុងចម្ការផ្លែឈើដែលមានទំហំ១៣២ហិកតា។

លោក ឈួន នីដា ពលករខ្មែរមកពីខេត្តកំពង់ស្ពឺបានឱ្យដឹងថា លោកបានមកធ្វើការ ក្នុងចម្ការនេះ រយៈពេល៧ឆ្នាំហើយទទួលបានប្រាក់ខែជិត១២.០០០បាត ដោយធ្វើជាអ្នកដឹកភ្ញៀវទេសចរទស្សនាផ្លែឈើផង ធ្វើជាមគ្គុទេសក៏ប្រាប់ភ្ញៀវផង។ ចំណែកអ្នកស្រី ឡាយ ចន្ទ អ្នករៀបប៊ូហ្វេផ្លែឈើទទួលភ្ញៀវទេសចរបានឱ្យដឹងថា ពលករធ្វើការនៅក្នុងកសិដ្ឋានកម្សាន្ត ចម្ការផ្លែឈើនេះគឺថៃផ្តល់កន្លែងស្នាក់នៅសេវាដឹកជញ្ជូនពលករទៅមកពីកន្លែងស្នាក់នៅមកដល់កន្លែងធ្វើការវិញជារៀងរាល់ថ្ងៃ។ អ្នកស្រីថា មានពលករខ្លះមកធ្វើការនៅទីនោះទាំង ប្តីទាំងប្រពន្ធតែម្តងដោយធ្វើការជាច្រើនឆ្នាំមកហើយ។

លោក Chotchai Buadit អ្នកគ្រប់គ្រងទូទៅ នៃកសិដ្ឋានកម្សាន្តចម្ការផ្លែឈើ Suphattraland Rayong បានសម្តែងការពេញចិត្តចំពោះពលករខ្មែរ និងបានចាត់ទុកពួកគេ ដូចជាបងប្អូនផងដែរ។ លោកបានបន្តថា ពលករខ្មែរម្នាក់ៗបំពេញការងារបានល្អណាស់។

សូមបញ្ជាក់ថា កសិដ្ឋានកម្សាន្តចម្ការផ្លែឈើ Suphattraland Rayong មានសេវា សម្រាប់ភ្ញៀវទេសចរដូចជា មគ្គុទ្ទេសន៍អធិប្បាយប្រាប់ភ្ញៀវ រថយន្តដឹកភ្ញៀវ សេវាកម្មប៊ូហ្វេ ផ្លែឈើ ញុំាផ្លែឈើស្រស់ៗ ញុំាបុកល្ហុង និងសិក្សាពីរបៀបចិញ្ចឹមឃ្មុំ ក្នុងចម្ការផ្លែឈើ ដោយ គ្រាន់តែចំណាយ៥០០បាតសម្រាប់ភ្ញៀវទេសចរម្នាក់បង់ថ្លៃចូលទស្ស នានិងសេវាកម្មទាំង អស់នេះ៕

## ពលរដ្ឋខ្មែរ ៣០នាក់ដែលមានទោសនៅអាមេរិក ត្រូវបានបញ្ជូនមកដល់កម្ពុជាហើយ

http://kleykley.sabay.com.kh/article/ ថ្ងៃទី ២៣ សីហា ២០១៨ ម៉ោង ០៨:២១

អ្នកនាំពាក្យស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅរាជធានីភ្នំពេញ លោក អេរិន ឆ្វាសចេស (Erend Zwatjest) ប្រាប់ឱ្យដឹងថា ពលរដ្ឋខ្មែរចំនួន ៣០នាក់ទៀត ដែលបានប្រព្រឹត្តិបទល្មើសឧក្រិដ្ឋ និងបានអនុវត្តទោសនៅសហរដ្ឋអាមេរិករួចហើយ ត្រូវបានរដ្ឋាភិបាលអាមេរិក បញ្ជូនមកដល់កម្ពុជាវិញហើយ កាលពីថ្ងៃទី២២ សីហា ឆ្នាំ២០១៨ម្សិលមិញ។

របាយការណ៍អង្គការគាំពារពលរដ្ឋខ្មែរគ្មានទីពឹង ឲ្យដឹងថា ចំនួនពលរដ្ឋខ្មែរដែលប្រព្រឹត្តខុសច្បាប់ធ្ងន់ធ្ងរ ឬបទឧក្រិដ្ឋ ត្រូវបានរដ្ឋាភិបាលអាមេរិកបញ្ជូនមកកាន់វិញជាបន្តបន្ទាប់ មកទល់ពេលនេះ មានចំនួនជិត៧០០ នាក់ហើយ ក្នុងនោះ មាន ២៩នាក់បានស្លាប់ (២នាក់ស្លាប់ដោយសារធ្វើអត្តឃាត)។

លោក តាន់ សូនិក នាយកប្រតិបត្តិអង្គការគាំពារពលរដ្ឋខ្មែរគ្មានទីពឹង បានឱ្យដឹងកាលពីសប្តាហ៍មុនថា ពលរដ្ឋខ្មែរមួយចំនួនដែលត្រលប់មកកម្ពុជាវិញហើយនោះ ខ្វះការជួយជ្រោមជ្រែងពីគ្រួសារនៅអាមេរិក និងនៅស្រុកខ្មែរ នៅពេលអ្នកត្រូវបញ្ជូនត្រលប់មកវិញមានចំនួនកាន់តែច្រើនឡើង។ ពលរដ្ឋខ្មែរទាំងនេះខ្វះចំណេះដឹងផ្នែកវប្បធម៌ និងភាសាខ្មែរ ដែលធ្វើឱ្យពួកគេមានការលំបាកក្នុងការធ្វើសមាហរណកម្ម សម្របខ្លួនចូលទៅក្នុងសង្គមខ្មែរ។

សូមជម្រាបថា ស្ថានទូតសហរដ្ឋអាមេរិក បានផ្តល់ជំនួយឧបត្ថម្ភដល់អង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះថា អង្គការគាំពារពលរដ្ឋខ្មែរគ្មានទីពឹង ឬហៅកាត់ថាខ្វាវ (KVAO) ដើម្បីជួយដល់ពលរដ្ឋខ្មែរដែលត្រូវបានបញ្ជូនមកវិញទាំងនេះ ធ្វើការសម្របខ្លួនក្នុងការរស់នៅក្នុងសង្គមកម្ពុជា។

យោងតាមកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ២០០២ សហរដ្ឋអាមេរិកនឹងបញ្ជូនពលរដ្ឋខ្មែរ ដែលបានប្រព្រឹត្តបទឧក្រិដ្ឋនៅសហរដ្ឋអាមេរិកមកកាន់ប្រទេសកំណើតវិញ ក្រោយពីពួកគេបានជាប់ពន្ធនាគារនៅអាមេរិកតាមការកំណត់របស់តុលាការរួចហើយ។ អ្នកដែលត្រូវបាននិរទេសចេញពីអាមេរិកទាំងនោះ គឺត្រូវតែជាអ្នកមិនទាន់មានសញ្ជាតិអាមេរិក ទោះបីជាពួកគេបានមករស់នៅក្នុងទឹកដីសហរដ្ឋអាមេរិកអស់រយៈពេលជាច្រើនឆ្នាំយ៉ាងណាក្តី។ ពួកគេភាគច្រើនមករស់នៅសហរដ្ឋអាមេរិកតាំងពីវ័យកុមារ មកជាមួយឪពុកម្តាយក្នុងឋានៈជាជនភៀសខ្លួនក្រោយរបបខ្មែរក្រហមបានដួលរលំ។ ក្នុងករណីពលរដ្ឋខ្មែរដែលមានសញ្ជាតិអាមេរិកហើយ ក្រោយពេលជាប់ទោស ពួកគេនឹងមិនអាចត្រូវបានបញ្ជូនចេញពីប្រទេសអាមេរិកឡើយ នេះបើផ្អែកតាមច្បាប់អាមេរិក៕

## អគ្គីភ័យឆេះអគារស្នាក់នៅពលករខ្មែរនៅថៃតែគ្មានអ្នករងរបួស

https://wmc.org.kh/ ថ្ងៃព្រហស្បតិ៍ ទី២៣ ខែសីហា ឆ្នាំ២០១៨ ធូ វីរៈ

ភ្នំពេញ៖ ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃបានប្រកាសថា អគ្គីភ័យបានឆេះអគារស្នាក់នៅរបស់ពលករខ្មែរបម្រើការងារផ្នែកសំណង់នៅប្រទេសថៃ កាលពីសប្តាហ៍មុន។ ប៉ុន្តែគ្មានពលករណាម្នាក់រងរបួសនោះទេ។ *ឧបទ្ទវហេតុអគ្គីភ័យឆេះអគារស្នាក់នៅពលករខ្មែរនៅថៃទី ១៨ សីហា សប្តាហ៍មុន នាំឱ្យបំផ្លាញទ្រព្យសម្បត្តិ និងឯកសារផ្ទាល់ខ្លួនដល់ពលករខ្មែរប្រមាណ២៥០នាក់។លោកថា ភ្លើងឆេះលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ សំបុត្រកំណើត និងឯកសារផ្សេងទៀត*។

លោក ឡុង វិសាលោ ឯកអគ្គរាជទូតកម្ពុជាប្រចាំនៅប្រទេសថៃ ឱ្យដឹងថា ឧបទ្ទវហេតុអគ្គីភ័យឆេះអគារស្នាក់នៅពលករខ្មែរនៅថៃទី ១៨ សីហា សប្តាហ៍មុន នាំឱ្យបំផ្លាញទ្រព្យសម្បត្តិ និងឯកសារផ្ទាល់ខ្លួនដល់ពលករ

ខ្មែរប្រមាណ២៥០នាក់។លោកថា ភ្លើងឆេះលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ សំបុត្រកំណើត និងឯកសារផ្សេងទៀត។ លោក ឡុង វិសាលោ បញ្ជាក់នៅក្នុងសេចក្តីប្រកាសព័ត៌មានថា ឧបទ្ទវហេតុភ្លើងឆេះអគារស្នាក់នៅពលករនេះគ្មានពលករណាម្នាក់រងរបួសដល់អាយុជីវិតនោះទេ។លោកថា ករណីនេះស្ថានទូតខ្មែរកំពុងរៀបចំពាក្យបណ្តឹងទៅអាជ្ញាធរថៃ ដើម្បីទាមទារសំណងខូចខាតទ្រព្យសម្បត្តិ និងទាមទារ ឱ្យអាជ្ញាធរថៃផ្តល់លិខិតទទួលស្គាល់ការបាត់បង់ឯកសារក្នុងឧបទ្ទវហេតុភ្លើងឆេះនេះ។ ជាមួយគ្នានេះ លោក វិសាលោ ឯកអគ្គរាជខ្មែរ អំពាវនាវឱ្យពលករខ្មែរដែលទទួលបានលិខិតបញ្ជាក់អំពីការបាត់បង់ឯកសារនានា ត្រូវប្រញាប់មកដាក់ពាក្យស្នើសុំនៅស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក៕

## ឧទ្ធរណ៍តម្កល់ទោសស្ត្រីនាំនារីទៅរៀបការប្តីចិន ៨ ឆ្នាំដដែល

https://www.postkhmer.com/ គីម សារុំ | Publication date 23 August 2018 | 10:41 ICT

**ភ្នំពេញៈ** សាលាឧទ្ធរណ៍កាលពីម្សិលមិញប្រកាសសាលដីកាសម្រេចឲ្យស្ត្រីជាប់ចោទម្នាក់ជាប់គុក ៨ ឆ្នាំដដែលពាក់ព័ន្ធករណីនាំនារីខ្មែរ ២ នាក់ទៅរៀបការប្តីនៅប្រទេសចិនប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីអំឡុងឆ្នាំ ២០១៦ បន្ទាប់ពីជំនុំជម្រះកាលពីថ្ងៃទី ៨ ខែសីហា។ នៅក្នុងបន្ទប់សវនាការពេលប្រកាសសាលដីកាចំពោះមុខស្ត្រីជាប់ចោទលោក ចៅក្រម ប្លង់ សំណាង បានឱ្យដឹងថាៈ «សំណុំរឿងនេះមានស្ត្រីជាប់ចោទឈ្មោះ អ៊ុច សេងហុង ហើយពេលនេះតុលាការប្រកាសតែសេចក្តីសម្រេចទេដោយតម្កល់សាលក្រមសាលាដំបូងរាជធានីភ្នំពេញទុកជាបានការ។ បានន័យថាទណ្ឌកម្មទោស ៨ ឆ្នាំគឺនៅតែ ៨ ឆ្នាំដដែល។ ប៉ុន្តែបើជនជាប់ចោទមិនសុខចិត្តអាចមានសិទ្ធិប្តឹងសារទុក្ខទៅតុលាការកំពូលគិតពីថ្ងៃប្រកាសសាលដីកានេះរយៈពេល ១ ខែ»។ តាមស្ត្រីជាប់ចោទឆ្លើយក្នុងសវនាការនៅថ្ងៃជំនុំជម្រះបានប្រាប់ចៅក្រមថា គាត់ជាអ្នកស៊ីឈ្នួលវត់តុឲ្យគេនៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ហើយកាលពីថ្ងៃទី ៦ ដល់ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០១៦ មានបុរសម្នាក់ចូលមកអង្គុយក្នុងហាងគាត់ ហើយសួរគាត់រកនារីក្មេងៗណាចង់បានប្តីចិនឲ្យទាក់ទងគាត់ដោយបុរសសន្យាផ្តល់សេវា ២ ពាន់ដុល្លារ។

ស្ត្រីជាប់ចោទបន្តថា ដោយសារជីវភាពក្រីក្រ ហើយណាមួយគាត់ក៏មានកូនស្រីម្នាក់កំពុងរស់ និងបានប្តីនៅប្រទេសចិនដែរនោះ គាត់ក៏បានទាក់ទងជាមួយនារី ២ នាក់នៅក្នុងភូមិជាមួយគ្នាដែលម្នាក់មានអាយុ ២១ ឆ្នាំ និងម្នាក់ទៀតអាយុ ២៦ ឆ្នាំ។ បន្ទាប់ពីណាត់ជួបគ្នានិយាយស្រុះស្រួលគ្នាហើយគាត់ក៏បបួលនារីទាំង ២ នាក់មករាជធានីភ្នំពេញដោយជួលផ្ទះសំណាក់ស្នាក់នៅ។ ស្ត្រីជាប់ចោទបន្តទៀតថាក្នុងការរត់ការបំពេញឯកសារគឺគាត់ជាអ្នកចាត់ចែងឲ្យនារីរងគ្រោះទាំងអស់ ព្រោះគាត់ក៏ធ្លាប់រត់ការឲ្យកូនស្រីខ្លួនឯងទៅរៀបការប្តីចិនដែរ។ ប៉ុន្តែក្រោយមកនារីរងគ្រោះទាំង ២ នាក់បានប្តឹង បន្ទាប់មកក៏ត្រូវបាននគរបាលប្រឆាំងការជួញដូរមនុស្សចាប់ខ្លួនតែម្តង។

សំណុំរឿងនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញសម្រេចផ្តន្ទាទោសដាក់គុក ៨ ឆ្នាំកាលពីថ្ងៃទី ៣ ខែមករាឆ្នាំ ២០១៧ ដោយចោទពីបទប៉ុនប៉ងនាំចេញដោយមិនស្របច្បាប់តាមបញ្ញត្តិមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបង្គាប់ឲ្យស្ត្រីជាប់ចោទសងសំណងទៅនារីរងគ្រោះម្នាក់ ២ លានរៀល។

ទោះយ៉ាងណាកាលពីជំនុំជម្រះនោះលោកព្រះរាជអាជ្ញា យុត សុភាង តំណាងមហាអយ្យការសន្និដ្ឋានថា សំណុំរឿងនេះជនជាប់ចោទបានសារភាពហើយសាលក្រមសាលាដំបូងរាជធានីភ្នំពេញធ្វើឡើងតាមច្បាប់ត្រឹមត្រូវ។ ដូច្នេះលោកសូមក្រុមប្រឹក្សាជំនុំជម្រះតម្កល់សាលក្រមទុកជាបានការដដែល។ រីឯកញ្ញាមេធាវី ជា បញ្ញា ដែលការពារសិទ្ធិឲ្យស្ត្រីជាប់ចោទសន្និដ្ឋានថា កូនក្តីលោកស្រីបានសារភាពកំហុសនៅគ្រប់ដំណាក់កាល និងបានស្នើឱ្យតុលាការបន្ថយទោស៕

# ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨

## កូនស្រីអាយុ១៥ឆ្នាំ និងម្តាយ ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួន ពីបទលួចលោមក្មេងស្រី អាយុ១៤ ទៅ១៥ឆ្នាំ ឲ្យទៅគេងជាមួយជនបរទេស ក្នុងមួយយប់តំលៃ២០០ដុល្លារ

https://www.khmernews.news/ ដោយ ស៊ីថា ២៣/០៨/២០១៨

ភ្នំពេញ ៖ កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨ ស្ត្រីវ័យចំណាស់ម្នាក់អាយុ៣១ឆ្នាំនិងកូនស្រីវ័យក្មេងអាយុ ១៥ឆ្នាំ ត្រូវសមត្ថកិច្ចកងរាជអាវុធហត្ថរាជធានីភ្នំពេញ ធ្វើការឃាត់ខ្លួន និង កសាងសំណុំរឿងបញ្ជូនទៅតុលាការ ដើម្បីធ្វើការផ្តន្ទាទោស តាមពាក្យបណ្តឹងរបស់ម្តាយក្មេងស្រីរងគ្រោះ ពីបទពាក់ព័ន្ធករណីលួងលោមក្មេងស្រីជា ច្រើននាក់ ឲ្យទៅរួមភេទជាមួយជនបរទេស ក្នុងតម្លៃ២០០ដុល្លារមួយយប់។ ក្មេងស្រីរងគ្រោះ ឈ្មោះ ស.ណ អាយុ ១៥ឆ្នាំ, ក្មេងស្រីឈ្មោះ ច.ណ អាយុ១៥ឆ្នាំ, ក្មេងស្រីឈ្មោះ ម.ត អាយុ១៤ឆ្នាំ, ក្មេងស្រីឈ្មោះ ល.ដ អាយុ១៤ឆ្នាំ សុទ្ធតែត្រូវបានជនសង្ស័យ០២នាក់ម្តាយកូនខាងលើធ្វើការលួងលោមឲ្យទៅរួមភេទ ជាមួយជនបរទេសដូចៗគ្នា ដោយជនសង្ស័យប្រាប់ថា នឹងទទួលបានប្រាក់ចំនួនពី ៥,០០០ ទៅ ១០,០០០ ដុល្លារព្រមទាំងទិញឡាននិងផ្ទះ ឲ្យថែមទៀត តែជាតុពិតគឺក្មេងស្រីឈ្មោះ ស.ណ និង ឈ្មោះ ច.ណ ធ្លាប់បានទៅរួមភេទជាមួយបរទេសរួចហើយ គឺ ទទួលបានប្រាក់ត្រឹមតែ២០០ដុល្លារក្នុងមួយយប់តែប៉ុណ្ណោះ ឯក្មេងស្រីពីរនាក់ទៀតឈ្មោះ ម.ត និងឈ្មោះ ល.ដ មិនទាន់បានទៅរួមភេទទេ ព្រោះត្រូវបានឪពុកម្តាយពួកនាងទាំងពីរ ប្តឹងមកសមត្ថកិច្ចអាវុធហត្ថរាជធានីភ្នំពេញ ជួយស្រាវជ្រាវទាន់ពេលវេលាបន្ទាប់ពីពួកនាងបានបាត់ចេញពីផ្ទះអស់មួយយប់ ។ បច្ចុប្បន្នជនសង្ស័យទាំងពីរនាក់ ត្រូវបានបញ្ជូនទៅកាន់តុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់៕

## គ្រាន់តែក្មេងខ្មែរអាយុក្រោម១៥ឆ្នាំ ទៅបាចត្រីក្នុងទឹកដីថៃ ត្រូវជនជាតិថៃដេញវាយនិង កាប់របួសធ្ងន់២នាក់

http://cambodiapolice.com/policekh/ 11:01 pm 23 សីហា 2018

**បន្ទាយមានជ័យ៖** កូនក្មេងជាជាតិខ្មែរ នៅជាប់ព្រំដែន កម្ពុជា-ថៃ ចំនួន៦នាក់ បាននាំគ្នាចូលទៅរកបាចត្រី នៅចំណុចភូមិខងផែង ឃុំតាបប្រាយ៉ា ស្រុកតាប់ប្រាយ៉ា ខេត្តស្រះកែវ ប្រទេសថៃ ត្រូវបានជនជាតិថៃ ដេញវាយ និង កាប់បណ្តាលឲ្យរងរបួសធ្ងន់ចំនួន២នាក់ ក្នុងចំណោម៦នាក់។ ហេតុការណ៍នេះបានកើតឡើងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨នៅម៉ោង៣រសៀល ។

លោកវរសេនីយ៍ទោ សៅ សារឿន អធិការនគរបាលស្រុកថ្មពួក បានឲ្យដឹងថា៖ក្មេងរងគ្រោះត្រូវជន ជាតិថៃ កាប់ត្រូវ ម្នាក់ឈ្មោះ គៀត លីហួ ភេទប្រុស អាយុ១៥ឆ្នាំ រស់នៅភូមិបន្ទាយមានរឹទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្ត បន្ទាយមានជ័យ របួសធ្ងន់បញ្ជូនទៅមន្ទីរពេទ្យថ្មពួកនិងបន្តទៅមន្ទីរពេទ្យបង្អែកមង្គលបូរីនិងម្នាក់ទៀត ឈ្មោះជឿង ដួង ភេទប្រុស អាយុ១២ឆ្នាំ រស់នៅភូមិបន្ទាយមានឫទ្ធិ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ រងរបួស ធ្ងន់បែកក្បាលត្រូវបានម្តាយដឹកយកទៅព្យាបាលនៅពេទ្យឯកជននៅបឹងត្រួន។ ចំណែក៤នាក់ទៀតអត់ទាន់ស្គាល់ ឈ្មោះហើយកំលាំងយើងបានចុះសហការជាមួយកម្លាំងទំនាក់ទំនងព្រំដែនកំពុងស្រាវជ្រាវ។

លោកវរសេនីយ៍ឯកឡុង សំណាង មេបញ្ជាការនគរបាលការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា៖ ក្មេងទាំង៦នាក់ បាននាំគ្នាដើរចូលទៅ ត្រង់ចំណុចដើមជើងគោឬដើមស្តៅ១០០ ដើម្បីបាចត្រីនៅក្នុងស្រែ ប៉ុន្តែ លោកនៅជាការបាននោះទេ តែបើទោះយ៉ាងណាក៏ជនជាតិថៃនោះមិនត្រូវដល់ថ្នាក់ដេញវាយនិងកាប់ឲ្យរងរបួស

ក្មេងនោះតែ ចំពោះករណីនេះ លោកនឹងសហការជាមួយកម្លាំងនគរបាលអធិការស្រុក និងកម្លាំងទំនាក់ទំនងព្រំដែន ធ្វើការសហការជាមួយសមត្ថកិច្ចថៃស្រាវជ្រាវនិង ស្វែងរកជនដៃដល់ មកសួរនាំពីរឿងពិតប្រាកដនោះ៕

## កិច្ចប្រជុំពិគ្រោះយោបល់រវាងភាគីថៃនិងភាគីកម្ពុជាលើបញ្ហាទប់ស្កាត់អំពើជួញដូរមនុស្សខុសច្បាប់នៅក្នុងប្រទេសថៃ

https://www.facebook.com/LPNCambodia/ 23-08-2018

កិច្ចប្រជុំនេះបានប្រព្រឹត្តទៅកាលពីវេលាម៉ោង08:30ព្រឹក ថ្ងៃពុធទី 22 ខែសីហា ឆ្នាំ 2018 នៅសណ្ឋាគារឥណ្ឌូចិន ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃ ដោយមានការអញ្ជើញចូលរួមពីសំណាក់មន្ត្រីអាជ្ញាធរប៉ូលិសជាន់ខ្ពស់ថៃនិងមន្ត្រីអាជ្ញាធរប៉ូលីសជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអង្គការសង្គមស៊ីវិលនានាជាច្រើនទៀតនៅក្នុងប្រទេសថៃ។ ក្នុងកិច្ចប្រជុំបានផ្តោតទៅលើបញ្ហាសំខាន់មួយចំនួន ដូចជាបញ្ហាពលករចំណាកស្រុកខុសច្បាប់ និងការរំលោភបំពានសិទ្ធិសេរីភាពពលករកម្ពុជាដែលកំពុងធ្វើការនៅក្នុងប្រទេសថៃផងដែរ។

## ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨

## នគរបាលខេត្តព្រះសីហនុ ឃាត់ខ្លួនជនជាតិចិន ៤នាក់ ពីបទផ្សព្វផ្សាយ ខិត្តបណ្ណ រូបភាពអាសអាភាស

https://www.dap-news.com/ Byprivate Posted on August 25, 2018

ភ្នំពេញ៖ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលសង្កាត់លេខ២ សហការជាមួយកម្លាំងអធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ឃាត់ខ្លួនជនជាតិចិនប្រុសស្រី៤នាក់ ពីបទផ្សព្វផ្សាយខិត្តបណ្ណរូបភាពអាសអាភាស នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង២៣និង៣០នាទី នៅចំណុចភ្នំខៀវ ក្នុងក្រុមទី១ ភូមិ១ សង្កាត់២ ក្រុង-ខេត្តព្រះសីហនុ ។ នគរបាលខេត្តព្រះសីហនុ បានឲ្យដឹងថា ជនជាតិចិន ដែលសមត្ថកិច្ចឃាត់ខ្លួនរួមមាន ទី១-ឈ្មោះ Xiang zi អាយុ ១៩ឆ្នាំ ភេទស្រី, ទី២-ឈ្មោះ Chao jian ring អាយុ ១៨ឆ្នាំ ភេទស្រី, ទី៣-ឈ្មោះ Liu xiong fei អាយុ ២៧ឆ្នាំ ភេទប្រុស និងទី៤-ឈ្មោះ Duan yu cheng អាយុ ៣៦ឆ្នាំ ភេទប្រុស ។ បានធ្វើសកម្មភាព ដោយចតរថយន្តនៅចំណុចខាងលើ ក្នុងគោលបំណង ចែកខិតបណ្ណផ្សព្វផ្សាយរូបអាសអាភាស ។

ពេលសមត្ថកិច្ចត្រួតពិនិត្យ ពួកគាត់បានកាន់ខិតបណ្ណ ផ្សព្វផ្សាយរូបភាពអាសអាភាស ក្នុងន័យបង្កប់សេវាផ្លូវភេទ ទម្លាក់ចុះពីតាបឡូរថយន្តមកក្រោម ឃើញសភាពបែបនេះកម្លាំងជំនាញ បាននាំពួកគាត់មក អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ ដើម្បីធ្វើការសាកសួរ តែពួកគាត់មិនព្រមសហការ ជាមួយសមត្ថកិច្ចឡើយ ។ សមត្ថកិច្ចបានដកហូតវត្ថុតាងៈ ទូរស័ព្ទចំនួន៤គ្រឿង, ខិត្តបណ្ណមានរូបអាសអាភាសចំនួន ៦៨៤សន្លឹក និងរថយន្តមួយគ្រឿងម៉ាកលុចស៊ីស ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 20-8959 ។ បច្ចុប្បន្នកម្លាំងជំនាញ កំពុងបន្តតាមនីតិវិធីបញ្ជូនទៅសាលាដំបូងខេត្តព្រះសីហនុ ៕

## ពលករខ្មែរ៣នាក់ បានរងរបួស ជួបហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍នៅថៃ

http://www.arey-news.com/archiv (ថ្ងៃទី 27 August 2018 ម៉ោង 8:02 am)

**ថៃ៖** កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨ ពលករខ្មែរ៣នាក់ បានរងរបួស ក្រោយពីជួបហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ ស្រុកបាងខ្លាវ ប្រទេសថៃ ត្រង់ចំណុចផ្លូវជាតិ៣០៤-មហាសាខាម ស្ថិតនៅក្នុងភូមិ៥ ឃុំថាថងឡាំងវ ស្រុកបាងខ្លាវ ខេត្តឆាក់ឈើងសៅ។ គ្រោះថ្នាក់ចរាចរណ៍នេះ បង្កឡើងដោយរថយន្ត Mazda bt-50 pro ពីរបាំងមួយគ្រឿង បើកបុកដើមឈើក្បែរចិញ្ចើមផ្លូវ បណ្តាលឲ្យពលករខ្មែរចំនួន០៣នាក់ រងរបួសធ្ងន់ និងតៃកុងជនជាតិ

ថៃម្នាក់ស្លាប់ នៅកន្លែងកើតហេតុ។ ពលករខ្មែររងគ្រោះទាំង៣នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនយកទៅសង្គ្រោះនៅមន្ទីរពេទ្យបាងខ្លាវខេត្តឆាក់ឈើងសៅ៕

---

## អាជ្ញាធរថៃប្រគល់ពលរដ្ឋកម្ពុជាចំនួន៥នាក់ឱ្យត្រឡប់មកស្រុកកំណើតវិញ

http://www.rasmeinews.com/ August 26, 2018, 4:06 PM

*ដោយៈបាយ័ន/ឧត្តរមានជ័យៈ* អាជ្ញាធរប្រទេសថៃបានបញ្ជូនប្រជាពលរដ្ឋខ្មែរចំនួន៥នាក់ ឱ្យវិលត្រឡប់មកស្រុកកំណើតវិញបន្ទាប់ពីពួកគេទាំង៥នាក់បានឆ្លងដែនដោយខុសច្បាប់ទៅកាប់ឈើក្រញូង ហើយត្រូវបានទាហានថៃចាប់ខ្លួនហើយបញ្ជូនទៅជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត។ ពិធីប្រគល់និងទទួលជនកម្ពុជាទាំង៥នាក់នេះ បានធ្វើឡើងកាលពីវេលាម៉ោង១៧និង៣០នាទី ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ តាមច្រកអន្តរជាតិជាំស្រងាំ ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំ បាននិយាយថា អ្នកទាំង៥នាក់ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនកាលពីថ្ងៃ២៥ ខែកុម្ភៈ ឆ្នាំ២០១៦កន្លងទៅនេះ ដោយចូលតាមច្រកប៉ោយប៉ែត ឆ្លងដែនកាប់ឈើក្រញូងខុសច្បាប់ហើយត្រូវបានអាជ្ញាធរថៃយកទៅដាក់ពន្ធនាគារនៅខេត្តនគរាជចំនួន៣នាក់ និង២នាក់ទៀតត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៦ ពីបទឆ្លងដែនកាប់ឈើក្រញូងហើយជាប់ពន្ធនាគារនៅខេត្តស៊ីសាកេត ដោយចូលតាមច្រកអូរស្មាច់។ សមត្ថកិច្ចបានបន្តថាក្រោយពីឃាត់ខ្លួនរួចមកជនកម្ពុជាទាំង៥នាក់ត្រូវបានយកទៅដាក់ពន្ធនាគារតាំងពីពេលនោះមករហូតដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨នេះទើបត្រូវបានអាជ្ញាធរថៃដោះលែងឱ្យត្រឡប់ទៅស្រុកកំណើតវិញ។

ជនទាំង៥នាក់ដែលត្រូវបានអាជ្ញាធរថៃដោះលែងគឺមានទី១ ឈ្មោះ ប្រាក់ កញ្ញា ភេទប្រុស អាយុ៣១ឆ្នាំ រស់នៅភូមិកសាង ឃុំចង្ក្រង់ ស្រុកចិត្របុរី ខេត្តក្រចេះ។ ទី២ ឈ្មោះ អ៊ុន ថន ភេទប្រុស អាយុ៣៧ឆ្នាំ រស់នៅភូមិទួល ឃុំលឿន ស្រុកឈូក ខេត្តកំពត ទី៣ ឈ្មោះ សុខ នី ភេទប្រុស អាយុ១៥ឆ្នាំ រស់នៅភូមិកសាង ឃុំចង្ក្រង់ ស្រុកចិត្របុរី ខេត្តក្រចេះ ទី៤ ឈ្មោះ សេង ធួត ភេទប្រុស អាយុ៥៩ឆ្នាំ រស់នៅភូមិអូរស្មាច់ ឃុំអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងទី៥ ឈ្មោះ ចិត្រ យ៉ាមយន ភេទប្រុស អាយុ១៤ឆ្នាំ រស់នៅភូមិអូរស្មាច់ ឃុំអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។ ក្រោយពីទទួលពីអាជ្ញាធរថៃរួចមកជនទាំង៥នាក់ត្រូវបានភាគីកម្ពុជាបានធ្វើការអប់រំនិងណែនាំមិនអោយធ្វើការឆ្លងដែនខុសច្បាប់ដូចលើកមុនៗឡើយ ៕S/

## អាមេរិក ស្នើកម្ពុជាចាប់ខ្លួនជនជាតិអាមេរិកម្នាក់ ដែលកំពុងរត់គេចខ្លួនកោននៅកម្ពុជា

http://kleykley.sabay.com.kh/article/ សុក្រ, ២៤ សីហា ២០១៨ ១៧:០៦

សហរដ្ឋអាមេរិកបានស្នើសម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ស្វែងរកចាប់ខ្លួនជនជាតិអាមេរិកាំងម្នាក់ ដែលបានរត់ពីសហរដ្ឋអាមេរិកមកជ្រកកោននៅប្រទេសកម្ពុជា ពាក់ព័ន្ធករណីរំលោភផ្លូវភេទលើកុមារជាបន្តបន្ទាប់។ ជនជាតិអាមេរិកកាំងដែលរកមកជ្រកកោននៅកម្ពុជានោះ មានឈ្មោះ William David BRENNER។

យោងតាមលិខិតរបស់ការិយាល័យសន្តិសុខភូមិភាគ (RSO) របស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ផ្ញើជូនសម្តេច ស ខេង កាលពីថ្ងៃទី២៣ ខែសីហា ដែល [ខ្លីៗ] ទើបតែទទួល បាន នៅ ថ្ងៃទី២៤ ខែសីហានេះ បានឲ្យដឹងថា ការិយាល័យសន្តិសុខភូមិភាគ បានទទួលព័ត៌មានថា ពលរដ្ឋអាមេរិកាំងឈ្មោះ William David BRENNER មានដីកាចាប់ខ្លួនដែលមានសុពលភាព ពាក់ព័ន្ធបទរំលោភបំពានផ្លូវភេទជាបន្តបន្ទាប់ទៅលើកុមារ។ ក្រសួងការបរទេសសហរដ្ឋអាមេរិក បានលុបចោលសុពលភាពលិខិតឆ្លងដែនរបស់ជនល្មើស។ ហើយជនល្មើសកំពុងតែរស់នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ដោយសារជនល្មើស គ្មានឯកសារធ្វើដំណើរដែលមានសុពល

ភាព វាស្តែងឲ្យឃើញថា ឈ្មោះ William David BRENNER កំពុងតែរំលោភទៅលើច្បាប់អន្តោប្រវេសន៍របស់ប្រទេសកម្ពុជា។

ការិយាល័យសន្តិសុខភូមិភាគស្នើសុំឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ជួយស្វែងរក និងឃាត់ខ្លួនជនល្មើស ដោយផ្អែកលើច្បាប់របស់ប្រទេសកម្ពុជា។ ប្រសិនបើជនល្មើសបង្ហាញមុខនៅស្ថានទូត ការិយាល័យសន្តិសុខភូមិភាគនឹងជូនដំណឹងទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍អំពីវត្តមានជនល្មើសឈ្មោះ William David BRENNER។ ការិយាល័យសន្តិសុខភូមិភាគ បាននឹងកំពុងធ្វើការជាមួយនឹងស្ថាប័នពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក ដើម្បីបញ្ជូនខ្លួនជនល្មើសត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ដើម្បីធ្វើការកាត់ទោស៕ អត្ថបទ៖ សោភា

## ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨

## ពលរដ្ឋខ្មែរចំនួន២៦នាក់ត្រូវបានជួយដោយស្ថានតំណាងកម្ពុជានៅក្រៅប្រទេស

http://www.rasmeinews.com/ August 28, 2018, 11:01 AM

ដោយៈមុនីរ័ត្នៈភ្នំពេញៈពលរដ្ឋខ្មែរចំនួន២៦នាក់នៅប្រទេសចំនួនបីត្រូវបានជួយដោយស្ថានតំណាងកម្ពុជានៅក្រៅប្រទេស។នេះបើយោងតាមលោកកេតសោផាន់អ្នកនាំពាក្យក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបញ្ជាក់នៅព្រឹកថ្ងៃទី២៨ខែសីហានេះតាមសារអេឡិចត្រូនិក។ អ្នកនាំពាក្យបានបញ្ជាក់ថា៖

ទី១. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសចិន បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ ចិន ធ្វើអន្តរាគមន៍ជួយសង្គ្រោះនិងរៀបចំមាតុភូមិនិវត្តន៍របស់ស្ត្រីខ្មែរចំនួន៧នាក់ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការដោយខុសច្បាប់ជាមួយបុរសជនជាតិចិននៅក្នុងប្រទេសចិន ហើយពួកគេបានមកដល់កម្ពុជាវិញ នៅថ្ងៃទី៩ និងទី២៣ ខែ សីហា ឆ្នាំ២០១៨ ។

២. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី បានសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ម៉ាឡេស៊ី រៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន៧នាក់ (ស្រី១នាក់) មកពីខេត្ត ក្រចេះ កណ្តាល កំពង់ចាម ត្បូងឃ្មុំ និងខេត្តបាត់ដំបង ដែលបានទៅធ្វើការដោយខុសច្បាប់នៅប្រទេសម៉ាឡេស៊ី ហើយមានបំណងត្រឡប់មកកម្ពុជាវិញ។ ពលករ-ពលការិនីទាំង៧នាក់ បានមកដល់កម្ពុជាវិញចន្លោះពីថ្ងៃទី៤ដល់ទី១៥ ខែសីហា ។

៣. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសឥណ្ឌូនេស៊ី បានជួយសម្របសម្រួលរៀបចំមាតុភូមិនិវត្តន៍របស់ពលករនេសាទខ្មែរចំនួន២នាក់ មានអាយុ២៨ឆ្នាំ និង៣៦ឆ្នាំ មកពីខេត្តកំពង់ធំ ដែលត្រូវបានអាជ្ញាធរឥណ្ឌូនេស៊ីឃាត់ខ្លួន ក្រោយពីទូកនេសាទដែលពួកគេធ្វើការ បានចូលក្នុងដែនទឹកឥណ្ឌូនេស៊ី។ ពលករទាំង២នាក់នោះ បានត្រឡប់មកដល់កម្ពុជាវិញ នៅល្ងាចថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ។

៤. ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងសៀងហៃ ប្រទេសចិន បានសហការជាមួយអាជ្ញាធរចិន ធ្វើអន្តរាគមន៍ជួយស្ត្រីខ្មែរចំនួន១០នាក់ មានអាយុចន្លោះពី១៩ឆ្នាំដល់៣៤ឆ្នាំ មកពីខេត្តកណ្តាល កំពត កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ តាកែវ រតនគិរី ស្វាយរៀង និងរាជធានីភ្នំពេញ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅរៀបការ និងស្នាក់នៅដោយខុសច្បាប់ជាមួយបុរសជនជាតិចិន នៅប្រទេសចិន។ ស្ត្រីរងគ្រោះទាំង១០នាក់ ត្រូវបានបញ្ជូនមកដល់កម្ពុជាវិញជាបន្តបន្ទាប់ នៅថ្ងៃទី១៣ ទី១៨ និងទី២៥ខែ សីហា៕ **សរន**

## ទប់ស្កាត់ការ លួចឆ្លងដែនខុសច្បាប់ ការនាំចូល ទំនិញខុសច្បាប់ សកម្មភាព ចរាចរគ្រឿងញៀន

http://www.cen.com.kh/archives/ August 28, 2018

ព្រៃវែង ៖ ឧត្តមសេនីយ៍ទោ ស្រេង ជា ស្នងការ បានដឹកនាំកិច្ចប្រជុំបូកសរុប សភាពការណ៍ ការថែរក្សាសន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋ ក្រោយរយៈពេលបោះឆ្នោត។ លោកស្នងការជំរុញឲ្យចុះល្បាតក្នុងភូមិសាស្ត្រ ដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ការនាំចូលទំនិញខុសច្បាប់ សកម្មភាពចរាចរគ្រឿងញៀន។

ព្រឹកថ្ងៃ ច័ន្ទ ទី ២៧ ខែ សីហា ឆ្នាំ ២០១៨ នៅសាលប្រជុំស្នងការដ្ឋាននគរបាលខេត្តព្រៃវែង បានបើក កិច្ចប្រជុំ បូកសរុប ស្តីពីការថែរក្សាសន្តិសុខសុវត្ថិភាព សណ្តាប់ ធ្នាប់ សាធារណៈ ជូនប្រជាពលរដ្ឋ ក្រោយរយៈពេលបោះឆ្នោត។ ពិធីនេះមានការអញ្ជើញចូលរួមពីសំណាក់ លោកឧត្តមសេនីយ៍ វរសេនីយ៍ ស្នងការរង លោក លោកស្រីប្រធានការិយល័យជំនាញ មេបញ្ជាការវរៈការពារព្រំដែន ៦០៧ លោកអធិការនគរបាលស្រុក ក្រុងទាំង១៣ ។ ឧត្តមសេនីយ៍ទោ ស្រេង ជា ស្នងការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះថ្នាក់ដឹកនាំនគរបាល គ្រប់ជាន់ថ្នាក់ទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញ ភារកិច្ចតាំងពីយុទ្ធនាការចុះឈ្មោះបោះឆ្នោត រហូលដល់បោះឆ្នោតត្រូវបានបញ្ចប់ ធ្វើឲ្យសន្តិសុខ សណ្តាប់ធ្នាប់ និងស្ថិរភាពទូទាំងខេត្ត ។ ឧត្តមសេនីយទោ ស្រេង ជា ស្នងការ បានបន្តទៀតថា កងកម្លាំងនគរបាលជាតិ នៅតែជាកម្លាំងស្នូលឈានមុខក្នុងការបំពេញតួនាទី ធានារ៉ាប់រងស្ថិរភាពសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងរក្សាបាននូវភាពសុខសាន្តជូនប្រជាពលរដ្ឋនិងសង្គមជាតិ។ បានមានមតិផ្តាំផ្ញើដល់កងកម្លាំងទាំងអស់ ត្រូវកែប្រែឥរិយាបទឲ្យសក្តិសមជាមន្ត្រីនគរបាលជាតិ ជាពិសេសត្រូវខិតខំអនុវត្តឲ្យបានខ្លាំងក្លានូវគោលការណ៍ យុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន បង្ក្រាបល្បែងស៊ីសង បទល្មើសនេសាទខុសច្បាប់ ការអនុវត្តន៍ច្បាប់ចរាចរណ៍ផ្លូវគោក និងអនុវត្តផែនការបង្ការទប់ស្កាត់បទល្មើសគ្រប់ប្រភេទផងដែរ។

ឧត្តមសេនីយ៍ ស្នងការបានបន្ថែមទៀតថា សម្រាប់កម្លាំងនគរបាលតាមបណ្តា វរសេនាតូចនគរបាលការពារព្រំដែននោះ ឧត្តមសេនីយ៍ស្នងការជំរុញឲ្យចុះល្បាតក្នុងភូមិសាស្ត្រ ដើម្បីទប់ស្កាត់ការលួចឆ្លងដែនខុសច្បាប់ ការនាំចូល ទំនិញខុសច្បាប់សកម្មភាព ចរាចរគ្រឿងញៀន និងសហការ ឲ្យបានល្អជាមួយ អាជ្ញាធរដែនដី នៅតាមតំបន់នីមួយៗ និងភាគីថៃផងដែរ។ ជាចុងក្រោយ លោកស្នងការ បានផ្តាំផ្ញើ ឲ្យកងកម្លាំងនគរបាល ទាំងអស់ ត្រូវរួមសាមគ្គីគ្នា នៅក្នុងអង្គភាពរបស់ខ្លួន ដើម្បីអនុវត្តការងារ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ៕ ដោយៈបញ្ញាស័ក្តិ

# ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨

## ពលករចំណាកស្រុកខ្មែរប្រាថ្នាចង់បានឱកាសការងារច្រើនក្នុងប្រទេសកម្ពុជា

https://khmer.voanews.com/a/ 28 សីហា 2018 កាន់ វិច្ឆិកា

ខណៈដែលកម្លាំងពលកម្ម និងទីផ្សារការងារនៅកម្ពុជាមានតម្លៃថោក ការធ្វើចំណាកស្រុកមានការទទួលស្គាល់ថា បានផ្តល់ប្រយោជន៍មួយចំនួនជាពិសេសចំណូលទៅដល់ប្រជាពលរដ្ឋ។ យ៉ាងណាក៏ដោយ ទាំងពលករ និងអ្នកជំនាញលើកឡើងថា កម្ពុជានឹងត្រូវប្រឈមវិបត្តិកង្វះទីផ្សារការងារធ្ងន់ធ្ងរ នាពេលអនាគត ប្រសិនបើពលកររាប់សែននាក់ដែលកំពុងធ្វើការនៅប្រទេសទាំងនោះ ត្រឡប់មកកម្ពុជាវិញ។

ភ្នំពេញៈ លោក ផន យ៉េនបានចាកចេញពីស្រុកកំណើតជាមួយភរិយាទៅធ្វើការងាររោងចក្រនៅប្រទេសថៃកាលពីដើមឆ្នាំ២០១៣។ គ្រួសាររបស់គាត់បានសម្រេចចិត្តត្រឡប់មកប្រទេសកំណើតវិញដើម្បីមើលថែទាំកូន បន្ទាប់ពីធ្វើការបានប្រមាណជា៥ឆ្នាំ សន្សំប្រាក់ធ្វើផ្ទះមានតម្លៃជាង១ម៉ឺនដុល្លារ។ ចាប់តាំងពីមកដល់ស្រុកកំណើតឯសង្កាត់និមិត្ត ក្រុងប៉ោយប៉ែតវិញ កាលពីដើមឆ្នាំ២០១៨មករហូតមកដល់ពេលនេះ ប្តីប្រពន្ធដែលមានវ័យជាង

៣០ឆ្នាំ និងមានកូនចំនួនពីរនាក់នៅក្នុងបន្ទុកគ្រួសារ មិនទាន់រកបានការងារធ្វើនៅឡើយ ក្រៅតែពីសល់ផ្ទះឈើមួយខ្នងនេះ។ ដោយសារបញ្ហាជីវភាព លោក យ៉េន មានវ័យជិត៤០ឆ្នាំ ជាពលករដែលប្រើកម្លាំងសុទ្ធសាធ បានសម្រេចចិត្តចាកចេញពីស្រុកកំណើត ជាមួយនិងភរិយាវ័យ៣៧ឆ្នាំទៅធ្វើជាពលករធ្វើការក្នុងរោងចក្រផលិតថ្នាំងបាយអគ្គិសនីមួយនៅប្រទេសថៃ ដោយទុកកូនស្រីប្រុសទាំងពីរឲ្យឪពុកម្ដាយជាអ្នកមើលថៃ។ ទៅដល់ប្រទេសថៃ លោកយ៉េន និងភរិយាធ្វើការបានប្រាក់ជាង៣០០បាត ឬស្មើនឹង៤ម៉ឺនរៀល ក្នុងមួយថ្ងៃ។ ក្រោយសន្សំពីការចំណាយប្រចាំថ្ងៃ និងផ្ញើទៅអ្នកផ្ទះ ប្ដីប្រពន្ធទាំងពីរនាក់សល់លុយប្រមាណជា២ម៉ឺនបាត ឬស្មើនឹង៦០០ដុល្លារក្នុងមួយខែដើម្បីសង់ផ្ទះមួយនៅស្រុកកំណើត។ លោកយ៉េនបានរៀបរាប់ថា ការចេញទៅធ្វើជាពលករចំណាកស្រុកមិនមែនងាយស្រួលដូចការធ្វើការងារក្នុងប្រទេសទេ។ លោកចង់ឲ្យកម្ពុជាមានទីផ្សារកសិកម្មគ្រប់គ្រាន់ និងអាចរកចំណូលបានប្រហាក់ប្រហែលនឹងនៅប្រទេសថៃ ដើម្បីកុំឲ្យប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស។ ដូច្នេះលោកនឹងមិនចាកចោលស្រុកកំណើត បែកពីកូនតូចៗ រហូតត្រូវប្រឈមនឹងការអត់ការងារធ្វើក្រោយត្រឡប់មកពីចំណាកស្រុកវិញនោះទេ។ លោក យ៉េន និងភរិយាបានសម្រេចត្រឡប់មកស្រុកកំណើតវិញ ទាំងមិនមានការងារធ្វើ និងមិនមានសល់ប្រាក់ដើម្បីអាចប្រកបរបរនៅស្រុកកំណើតបាន ដោយសារតែមិនមានអ្នកមើលថៃកូនទាំងពីរនាក់របស់លោក ដែលទើបមានអាយុ១០ឆ្នាំ និង៨ឆ្នាំ។

លោកបញ្ជាក់ថា៖ «អត់ដឹងធ្វើអីទេឥឡូវនេះ! វាអស់លុយហើយ ដឹងធ្វើអីកើត? ហើយបើយើងប្រកបមុខរបរធ្វើស្រែ សព្វថ្ងៃក៏មេឃរាំង មិនដឹងថា ធ្វើអីកើត! ការងារក៏វាគ្មានធ្វើសូម្បីតែចិញ្ចឹមត្រីហ្នឹង ក៏គ្មានទីផ្សារដែរ។ បើមាន់ ទាគ្រាន់»។ លោកយ៉េនថ្លែងរៀបរាប់ពីផលលំបាកដោយសារគ្មានទីផ្សារកសិកម្មថា៖ «ម្ដាយក្មេកខ្ញុំអ្នកចិញ្ចឹមត្រីនៅពេញស្រះ។ វាមិនមែនថា អត់ទេ តែវាថោក មួយគីឡូ៤-៥ពាន់រៀល ម៉េចនឹងរួចខ្លួនទៅ? វាមានតែត្រីពីបរទេសមកវិញ។ អាត្រីក្នុងស្រុក គេមិនសូវត្រូវការ»។

ចលនាចំណាកស្រុកចេញពីកម្ពុជាចាប់ផ្ដើមកើតមានច្រើនតាំងពីឆ្នាំ២០០៥មក ដោយសារប្រជាពលរដ្ឋត្រូវប្រឈមនឹងភាពក្រីក្រ។ ភាពក្រីក្រដែលពួកគេបាននឹងកំពុងប្រឈមក្នុងប្រទេស ដែលទើបបញ្ចប់សង្គ្រាមជាង២០ឆ្នាំនេះ គឺបណ្ដាលមកពីកង្វះខាតដីធ្វើស្រែចម្ការ គ្មានទីផ្សារការងារ គ្មានទីផ្សារកសិកម្ម សមាជិកគ្រួសារមានជំងឺ ជំពាក់បំណុលស្ថាប័នហិរញ្ញវត្ថុជាដើម។ មូលហេតុមួយទៀតដែលកំពុងត្រូវបានលើកយកមកជជែកដែរនោះ គឺកូនៗដែលពេញវ័យធ្វើការ តែងទទូចសុំឪពុកម្ដាយដើម្បីចេញទៅធ្វើការនៅឆ្ងាយ ដោយសារពួកគេចង់មានសេរីភាពដើរហើរផ្សេងៗ។ អ្នកធ្វើចំណាកស្រុកទៅក្រៅប្រទេសតែងសង្ឃឹមថា នឹងទទួលបានប្រាក់ចំណូលច្រើនជាងការធ្វើចំណាកស្រុកនៅក្នុងប្រទេស។ ចំណែកប្រទេសដែលទទួលយកកម្លាំងពលកម្មចំណាកស្រុកខ្មែរមានដូចជាប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសកូរ៉េ និងប្រទេសដទៃៗទៀត។ ការធ្វើចំណាកស្រុករបស់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេសធ្វើឡើងទាំងស្របច្បាប់ និងខុសច្បាប់។ ការធ្វើដោយស្របច្បាប់គឺធ្វើឡើងតាមរយៈការបញ្ជូនចេញរបស់ក្រសួងការងារកម្ពុជា តាមរយៈក្រុមហ៊ុនដែលមានច្បាប់ត្រឹមត្រូវ ហើយការចេញទៀតសោត គឺមានឯកសារនៃការធ្វើលិខិតឆ្លងដែន កិច្ចសន្យាការងារជាដើម។

របាយការណ៍របស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈចេញកាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ បង្ហាញថា រដ្ឋាភិបាលកម្ពុជាបានផ្ដល់សេវាស្វែងរកការងារធ្វើនៅក្រៅប្រទេសសម្រាប់ពលរដ្ឋចំនួនជាង១,២លាននាក់។ រដ្ឋាភិបាលកម្ពុជាបានដំឡើងប្រាក់ឈ្នួលអប្បបរមាជូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ និងផលិតស្បែកជើងពី១៥៣ដុល្លារកាលពីឆ្នាំ២០១៧ដល់ចំនួន១៧០ដុល្លារ នៅឆ្នាំ២០១៨។ បើទោះជារដ្ឋាភិបាលបានសម្រេចដំឡើងប្រាក់ឈ្នួលគោលជារៀងរាល់ឆ្នាំក្ដី ប៉ុន្តែគេឃើញថា ថ្លៃឈ្នួលផ្ទះក៏ដូចជាតម្លៃទំនិញផ្សេងៗលើទីផ្សារ ក៏តែងកើនឡើងរាល់ពេលទៅតាមនោះដែរ។

ពលករម្នាក់ទៀតដែលចាកចេញពីស្រុកកំណើតឯងខេត្តកំពង់ចាម កាលពីដើមឆ្នាំ២០១៤ និងកំពុងធ្វើការនៅរោងចក្រនៅឯខេត្តសាមុតប្រាកាន ប្រទេសថៃ កញ្ញាសុខ ហេងរៀបរាប់ថា បន្ទាប់ពីធ្វើការរោងចក្រនៅកម្ពុជាទទួលបានប្រាក់ឈ្នួលទាប កញ្ញាបានសម្រេចចិត្តចាកចេញពីកម្ពុជាដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ ទទួលបានចំណូលមួយទ្វេជាពីរ បើធៀបនឹងចំណូលនៅកម្ពុជា។ ហើយលក្ខខណ្ឌការងារនៅប្រទេសថៃក៏មានភាពប្រសើរជាងលក្ខខណ្ឌការងារនៅតាមរោងចក្រដែលកញ្ញាធ្លាប់បានធ្វើនៅកម្ពុជាផងដែរ។ អង្គុយក្នុងបន្ទប់ជួលទំហំ៣ម៉ែត្រគុណនឹង៤ម៉ែត្រ នាងសុខ ហេងបានប្រាប់ VOA តាមរយៈ Video Call ថា៖ «វាមិនសូវបានកម្រៃច្រើន ហើយណាមួយផ្គត់ផ្គង់គ្រួសារយើងវាមិនសូវគ្រប់គ្រាន់ទេ។ ណាមួយយើងស៊ីចាយស៊ីអី បើសិនជាយើងធ្វើការនៅភ្នំពេញ បើសិនជាប្រាក់ខែដំឡើងថ្លៃបន្តិច ផ្ទះជួលក៏ឡើងថ្លៃដែរ»។ កញ្ញារៀបរាប់ពីភាពខុសគ្នារវាងការធ្វើការនៅកម្ពុជា និងនៅប្រទេសថៃយ៉ាងដូច្នេះ៖ «បើនៅស្រុកថៃគ្មានទេ។ គេគ្មានឡើងថ្លៃអីតាមប្រាក់ខែយើងទេ។ និយាយរួមនៅទីនេះ (ប្រទេសថៃ) មួយឆ្នាំគេឡើងឲ្យយើងប៉ុន្មានៗអីចឹង ផ្ទះជួលផ្ទះអីធម្មតា មិនមែនដូចស្រុកខ្មែរយើង គ្រាន់តែឮប្រាក់ខែឡើង ថ្លៃផ្ទះឡើងមុនបាត់ទៅហើយ»។ ពលការិនីរោងចក្រវ័យ៣២ឆ្នាំរូបនេះបន្ថែមថា បើទោះបីជាប្រាក់ឈ្នួលនិងលក្ខខណ្ឌការងារនៅប្រទេសថៃមានភាពប្រសើរជាងនៅកម្ពុជាក្តី ប៉ុន្តែកញ្ញាថា កញ្ញាមិនដែលចង់ចាកចេញពីស្រុកកំណើតមកធ្វើការងារដាច់សង្វែងឯប្រទេសក្រៅនោះទេ។ កញ្ញានឹងត្រឡប់មកធ្វើការនៅកម្ពុជាវិញ ប្រសិនបើប្រាក់ឈ្នួល និងលក្ខខណ្ឌការងារប្រហាក់ប្រហែលនឹងនៅប្រទេសថៃ។ ទាំងមិនទាន់ដឹងពីការងារដែលកញ្ញាត្រូវធ្វើពេលត្រឡប់មកកម្ពុជាវិញនោះ កញ្ញាបន្ថែមយ៉ាងដូច្នេះ៖ «ហត់នឿយ នឹកផ្ទះ នឹកម៉ែនឹកឪ។ ធម្មតាទេ យើងនៅស្រុកគេ វាមិនដូចនៅស្រុកយើងទេ យើងនៅឆ្ងាយពីគ្រួសារអីចឹង។ យើងនៅជាមួយម៉ែឪយើងវាមានភាពកក់ក្តៅ បើទោះអត់ឃ្លានមានស៊ី ក៏យើងមានក្តីសុខដែរ។ តែធ្វើម៉េច បើត្រូវអីចឹងហើយ។ បើយើងនៅផ្ទះក៏វាពិបាក វារកអីមិនបានអីចឹង»។

ខណៈដែលកម្លាំងពលកម្ម និងទីផ្សារការងារនៅកម្ពុជាមានតម្លៃថោក ការធ្វើចំណាកស្រុកមានការទទួលស្គាល់ថា បានផ្តល់ប្រយោជន៍មួយចំនួន ជាពិសេសចំណូលទៅដល់ប្រជាពលរដ្ឋ បើទោះបីជាភាគច្រើនបំផុតនៃពលករធ្វើចំណាកស្រុកទៅក្រៅប្រទេសគឺត្រូវធ្វើការជាកម្មករតូចតាចដែលគ្មានជំនាញក្តី។ បើទោះជាពលករកម្ពុជាមួយចំនួនដែលត្រឡប់មកពីធ្វើការនៅក្រៅប្រទេសវិញ មិនអាចរកការងារធ្វើដូចនៅប្រទេសក្រៅទាំងនោះក្តី ប៉ុន្តែមួយចំនួននៅសល់ប្រាក់ដើម្បីអាចប្រកបរបរចិញ្ចឹមជីវិត ដោយខ្លួនឯងបាន។

លោក យន ចំណាប់ អតីតពលករធ្វើការនៅប្រទេសកូរ៉េ ដែលកំពុងប្រកបរបរបើករថយន្តតាក់ស៊ី លើកឡើងថា កង្វះទីផ្សារការងារជាមូលហេតុដែលនាំឲ្យលោកសម្រេចចិត្តចាកចេញពីកម្ពុជាទៅធ្វើជាពលករនៅប្រទេសកូរ៉េ។ លោកបន្ថែមថា មុនពេលដែលលោកសម្រេចចិត្តចាកចេញពីកម្ពុជាទៅធ្វើជាពលករនៅក្រៅប្រទេស កាលពីឆ្នាំ២០១៣ លោកបានរៀបចំផែនការទុកជាមុន និងបានស្វែងរកព័ត៌មានលម្អិតពាក់ព័ន្ធនឹងការធ្វើការ និងការរស់នៅទីនោះ។ បុរសវ័យ៣០ឆ្នាំប្លាយរូបនេះបន្ថែមថា ការកំណត់គោលដៅទុកជាមុន បានធ្វើឲ្យលោកត្រឡប់មកវិញនូវប្រាក់មួយចំនួន ដែលអាចឲ្យលោកប្រកបរបរខ្លួនឯងបាន បើទោះជាកម្ពុជាមិនមានទីផ្សារការងារដូចការងារដែលលោកធ្លាប់ធ្វើនៅប្រទេសកូរ៉េក៏ដោយ។ បុរសដែលមានរថយន្ត Highlander សម្រាប់បើកតាក់ស៊ីរូបនេះបញ្ជាក់ថា៖ «សម្រាប់ពេលយើងចប់អាណត្តិមកខ្មែរ យើងត្រូវធ្វើអី? យើងសល់លុយប៉ុន្មាន? យើងបែកចែកគ្រប់គ្រងលុយឲ្យបានច្បាស់លាស់។ បើមិនអីចឹងទេ យើងទៅដល់កូរ៉េ យើងភ្លេចខ្លួនថា យើងជាពលករ។ យើងបែរជាច្រឡំខ្លួនយើងជាជនជាតិកូរ៉េ។ អីចឹងទៅយើងចាយលុយខ្ជះខ្ជាយ ព្រោះគិតថា ប្រាក់ខែពាន់ៗ។ អីចឹងវាអាចមានហានិភ័យខ្លាំង នៅពេលគាត់ចប់អាណត្តិមកខ្មែរវិញ កង្វះការងារ លុយកាក់មិនគ្រប់គ្រាន់ ជីវភាពគាត់មកដល់ណេះធ្លាក់ចុះ ហើយមកដល់ណេះគាត់តាមគ្នីគ្នា ហើយសង្គមចាយលុយច្រើន។ វាមានហានិភ័យសម្រាប់គាត់»។

បើតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ (ILO) ស្តីពីហានិភ័យ និងការលើកទឹកចិត្តៈលទ្ធផលនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅតំបន់អាស៊ីអាគ្នេយ៍ ចេញនៅឆ្នាំ២០១៧នេះបង្ហាញថា ពលករកម្ពុជាដែលធ្វើការក្រៅប្រទេសស្ទើរតែទាំងអស់បានផ្ញើរប្រាក់ត្រឡប់មកផ្ទះវិញជាមធ្យមចំនួន១៦៣ដុល្លារពីប្រទេសថៃ និង១៣៧ដុល្លារពីប្រទេសម៉ាឡេស៊ី។ ការចំណាកស្រុកទៅធ្វើជាពលករនៅបរទេសត្រូវបានអ្នកជំនាញលើកឡើងថា ពួកគេអាចទទួលបានប្រយោជន៍រយៈពេលខ្លី និងត្រូវប្រឈមច្រើន ជាពិសេសការធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយមិនបានទទួលព័ត៌មានគ្រប់គ្រាន់។ ពលករដែលធ្វើចំណាកស្រុកភាគច្រើននឹងត្រូវប្រឈមនឹងការគ្មានការងារធ្វើនៅពេលដែលពួកគេត្រឡប់មកប្រទេសកំណើតវិញ ដោយសារនៅប្រទេសកំណើតមិនមានការងារល្អដូចការងារដែលពលករធ្វើនៅប្រទេសដែលពួកគេចំណាកស្រុកទាំងនោះ និងមិនមានទីផ្សារការងារគ្រប់គ្រាន់សម្រាប់ពួកគេ។ កត្តានេះបានធ្វើឲ្យមានការបារម្ភថា ក្នុងពេលអនាគត កំណើននៃអត្រាគ្មានការងារធ្វើនៅកម្ពុជានឹងកើនឡើងខ្លាំងពិសេសនៅពេលដែលពលកររាប់សែននាក់អាចនឹងត្រូវបញ្ជូនមកប្រទេសកំណើតវិញយ៉ាងគំហុក។

លោកមឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) ដែលជាអង្គការធ្វើការពាក់ព័ន្ធនឹងការការពារពលករចំណាកស្រុក បានលើកឡើងថា ពលករកម្ពុជាប្រមាណជាជាង២លាននាក់ កំពុងធ្វើការនៅក្រៅប្រទេស ដែលភាគច្រើនគឺជាកម្មករប្រើកម្លាំង និងទទួលបានកម្រៃទាប មានន័យថា មិនមែនជាកម្មករជំនាញ។ លោកបន្ថែមថា ពលករដែលធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស ដាច់ខាតត្រូវត្រឡប់មកកម្ពុជាវិញ ក្នុងពេលកំណត់ណាមួយ ដែលមិនអាចធ្វើការនៅប្រទេសក្រៅរហូតបាននោះទេ ដូច្នេះលោកថា នៅពេលដែលបរទេសឈប់ត្រូវការកម្លាំងពលកម្មពីកម្ពុជា នោះការបញ្ជូនពលករយ៉ាងគំហុកមកវិញនឹងធ្វើឲ្យកម្ពុជាប្រឈមនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរ។ លោកមានប្រសាសន៍ថា៖ «យើងត្រូវទទួលរងនូវផលប៉ះពាល់ធំ ដោយសារទី១គឺថាមកអាចហ្នឹងអត់មានថវិកាក្នុងការសងបំណុលគេ ដោះបំណុលគេ។ ទី២អត់មានការងារធ្វើ។ បើកាលណាមនុស្សអត់ការងារធ្វើកាន់តែច្រើន តាមពិតអាហ្នឹងជាបន្ទុករបស់រដ្ឋ។ រដ្ឋដែលទទួលខុសត្រូវហ្នឹងគឺដោយសារពលរដ្ឋជាអ្នកបង់ពន្ធ។ អ៊ីចឹងរដ្ឋត្រូវតែគិតគូរពីប្រព័ន្ធគាំពារសង្គម គេធ្វើយ៉ាងម៉េចកុំឲ្យមនុស្សហ្នឹង កាលណាអត់មានចំណូលសោះទៅបែកគំនិតលួច ទៅជាបែកគំនិតប្រព្រឹត្តបទល្មើសណាមួយដែលធ្វើឲ្យប៉ះពាល់ទៅដល់សណ្តាប់ធ្នាប់ ឬក៏សន្តិសុខសង្គម»។

អង្គការពលកម្មអន្តរជាតិ (ILO) និងអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានចេញរបាយការណ៍មួយកាលពីពាក់កណ្តាលខែធ្នូ ឆ្នាំ២០១៧ បង្ហាញថា មានពលករចំណាកស្រុកកម្ពុជា៨នាក់ ក្នុងចំណោមពលករចំណាកស្រុក ១០នាក់ បានជួបការរំលោភបំពានសិទ្ធិការងារ ខណៈធ្វើការនៅបរទេស ហើយ ៧នាក់ក្នុងចំណោម១០នាក់បានទទួលរងបញ្ហាសុខភាពផ្លូវកាយ និងផ្លូវចិត្តនៅពេលត្រឡប់មកវិញ។ ការសិក្សាដែលមានទ្រង់ទ្រាយធំនោះក៏បានបង្ហាញថា ពលករចំណាកស្រុកកម្ពុជាបានរាយការណ៍អំពីបទពិសោធន៍អាក្រក់បំផុត ក្នុងចំណោមប្រទេសនៅអាស៊ីអាគ្នេយ៍ រួមមាន វៀតណាម ឡាវ និងមីយ៉ាន់ម៉ា។ ក្នុងនោះ ពលករពីកម្ពុជាគឺទំនងជាទទួលរងគ្រោះច្រើនជាងចំពោះការរំលោភបំពានសិទ្ធិការងារ និងមានបញ្ហាផ្លូវកាយ និងផ្លូវចិត្តខ្លាំងជាងប្រទេសដទៃៗ នៅពេលត្រឡប់មកវិញ។

លោក ង៉ែត ជូ អ្នកជំនាញផ្នែកសេដ្ឋកិច្ចលើកឡើងថា ភាគច្រើននៃពលករកម្ពុជាដែលធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស មិនមែនទៅធ្វើការដើម្បីបង្កើនសមត្ថភាព ឬជំនាញនោះទេ ប៉ុន្តែលោកថា ពួកគេធ្វើចំណាកស្រុកដើម្បីរកប្រាក់មកសង់ផ្ទះ និងដោះបំណុល។ លោកបន្ថែមថា ការធ្វើចំណាកស្រុករបស់ពលករពេញកម្លាំងបាននិងកំពុងធ្វើឲ្យមនុស្សចាស់ក្លាយជាអ្នកមើលថែក្មេងតូចៗ ខណៈក្មេងៗត្រូវបោះបង់ការសិក្សា ស្របពេលដែលទីផ្សារការងារ និងទីផ្សារកសិកម្មមិនមានការយកចិត្តទុកដាក់។ លោក ង៉ែត ជូ បន្ថែមថា ប្រសិនបើរដ្ឋាភិបាលមិនយកចិត្តទុកដាក់កាត់បន្ថយការធ្វើចំណាកស្រុក ហើយបង្កើនទីផ្សារការងារក្នុងស្រុកទេនោះ នោះបន្ទុករបស់រដ្ឋាភិបាលនឹង

កើតមានយ៉ាងធ្ងន់ធ្ងរនាពេលអនាគត។ លោកបញ្ជាក់ថា៖ «ការធ្វើចំណាកស្រុក វាមានពីរប្រភេទ បើយើងចំណាកស្រុកជាកម្មករជំនាញ អាហ្នឹងជួយសេដ្ឋកិច្ចជាតិបានច្រើនណាស់។ ទី១គាត់ទៅបានកម្រៃខ្ពស់ទី២ត្រឡប់មកវិញគាត់នាំជំនាញមកជួយកសាងប្រទេស។ ប៉ុន្តែកាលណាយើងធ្វើចំណាកស្រុកជាកម្លាំងពលកម្មសុទ្ធសាធ គាត់ត្រឡប់មកវិញជាបន្ទុករបស់ជាតិ ជាបន្ទុករបស់សង្គមទាំងមូល។ អីចឹងខ្ញុំមើលឃើញមិនថា វាជាផលចំណេញរយៈពេលវែងទេ។ ដូចខ្ញុំជម្រាបអីចឹង គឺជាការដោះទាល់រយៈពេលខ្លី»។ លោក ង៉ែត ជួបន្ថែមថា លោកមានការបារម្ភថាការធ្វើចំណាកស្រុកទៅក្រៅប្រទេសកាន់តែច្រើននឹងធ្វើឲ្យកម្ពុជាកាន់តែឃ្លាតឆ្ងាយពីការប្រកួតប្រជែងសេដ្ឋកិច្ចក្នុងតំបន់។ លោកមានប្រសាសន៍ថា៖ «ខ្ញុំមានការព្រួយបារម្ភណាស់កន្លែងហ្នឹង ពីព្រោះយើងនៅក្នុងបរិបទមួយ យើងកំពុងប្រកួតប្រជែងសេដ្ឋកិច្ចជាមួយគេ យើងផលិតអីក៏មិនសូវពូកែដូចគេ ហើយធនធានមនុស្សយើង យើងទៅជួយបំពេញសេចក្តីត្រូវការសេដ្ឋកិច្ចរបស់គេទៀត។ អីចឹងសួរថា ចំណុចណាទៅដែលយើងអាចទាញបានផលប្រយោជន៍ពីការប្រកួតប្រជែងហ្នឹង គឺដូចជាមានឱកាសតិចតួចបំផុតសម្រាប់យើង»។

បើតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ ពលករចំណាកស្រុកពីប្រទេសកម្ពុជាមានចំនួនត្រឹម៥ភាគរយប៉ុណ្ណោះ ដែលត្រូវបានគេផ្តល់ការងារធ្វើស្របនឹងជំនាញដែលពួកគេមាន។ ពលករចំណាកស្រុកក្រៅប្រទេស ជាទូទៅត្រូវបានគេជ្រើសរើសដើម្បីបំពេញតម្រូវការសម្រាប់តែប្រភេទការងារដែលមានប្រាក់កម្រៃទាបនៅក្នុងឧស្សាហកម្មដែលប្រើកម្លាំងកាយច្រើនជាងជំនាញ ពីព្រោះពលករទាំងនោះត្រូវបានគេវាយតម្លៃថា មិនមានបទពិសោធន៍ ឬមិនមានការបណ្តុះបណ្តាលផ្លូវការ ដែលឆ្លើយតបទៅនឹងតម្រូវការជំនាញរបស់ពួកគេ។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារកម្ពុជា បានអះអាងថា ការលើកឡើងដែលថា ការធ្វើចំណាកស្រុកមានគុណវិបត្តិច្រើនជាងគុណសម្បត្តិជាការលើកឡើងដែលមិនបានប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយ។ លោកបន្ថែមថា ការធ្វើចំណាកស្រុកទៅធ្វើការនៅបរទេស ធ្វើឲ្យពលករទទួលបានប្រាក់ចំណូលខ្ពស់ និងទទួលបានបទពិសោធន៍ការងារថ្មីៗ ស្របពេលដែលរដ្ឋាភិបាលកំពុងអនុវត្តគោលនយោបាយក្នុងការការពារពលករដែលកំពុងតែធ្វើការនៅក្រៅប្រទេស និងក្រោយពេលពួកគេត្រឡប់មកកម្ពុជាវិញ។ លោកមានប្រសាសន៍ថា៖ «ទី១ យើងត្រូវមានប្រព័ន្ធគាំពារបងប្អូនពលករដែលកំពុងតែធ្វើការងារនៅក្រៅប្រទេសឲ្យបានល្អ នៅពេលដែលគាត់កំពុងធ្វើការងារនៅទីនោះដោយស្របច្បាប់។ ហើយទី២ ប្រសិនជាបងប្អូនវិលត្រឡប់មកប្រទេសកំណើតវិញ ទី១យើងត្រូវមានសេវាផ្តល់ព័ត៌មានដើម្បីឲ្យបងប្អូនពិចារណាថា តើមានការងារនៅក្នុងស្រុកណាខ្លះដែលបងប្អូនអាចធ្វើបាន ហើយទី២ នឹងរៀបចំឲ្យមានការទទួលស្គាល់ជំនាញដែលបងប្អូនបានធ្វើការនៅទីនោះ»។

តាមរបាយការណ៍របស់ក្រសួងការងារកម្ពុជា ពលករខ្មែរប្រមាណ១លាន ៧ម៉ឺននាក់ បានស្នាក់នៅ និងបំពេញការងារនៅក្នុងប្រទេសថៃ ហើយបានទទួលឯកសារស្របច្បាប់នៅតាមបណ្តារោងចក្រ សហគ្រាស លើវិស័យសំណង់ នេសាទ និងកសិកម្ម និងត្រូវបានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ចុះបំពេញបេសកកម្មការងារផ្តល់ភាពស្របច្បាប់ជូនពួកគេដល់ប្រទេសថៃ។ ទន្ទឹមនឹងនេះ មានពលករខ្មែរចំណាកស្រុកមួយចំនួនទៀតនៅតែបន្តចូលទៅធ្វើការងារក្នុងប្រទេសថៃដោយខុសច្បាប់តាមរយៈមេខ្យល់ ដែលបង្កឲ្យមានការព្រមានចាត់វិធានការតឹងរ៉ឹងតាមផ្លូវច្បាប់ពីភាគីថៃ។

កន្លងទៅ អាជ្ញាធរបានជួយសង្គ្រោះពលរដ្ឋខ្មែរនៅក្រៅប្រទេសជិត១ពាន់នាក់ មកពីបណ្តាប្រទេសចំនួន៩ឲ្យវិលត្រឡប់មកកម្ពុជាវិញ បន្ទាប់ពីពួកគេជួបការរំលោភសិទ្ធិ និងការលំបាកនៅកន្លែងធ្វើការ។ ភាគច្រើននៃពលរដ្ឋរងគ្រោះទាំងនោះត្រូវបានជួយសង្គ្រោះពីប្រទេសម៉ាឡេស៊ីមានចំនួនដល់ទៅ៣៨២នាក់ និងថៃ១៧១នាក់ ព្រមទាំងបណ្តាប្រទេសនានានៅក្នុងតំបន់។

កាលពីខែមិថុនា ឆ្នាំ២០១៤ អាជ្ញាធរថៃបានបញ្ជូនពលករកម្ពុជាមកវិញចំនួនជាង៤ម៉ឺននាក់។ នៅដើមខែកក្កដាឆ្នាំ២០១៨នេះ ពលករកម្ពុជាប្រមាណជា១ពាន់នាក់ ដែលបានចូលស្នាក់នៅ និងបម្រើការងារដោយខុស

ច្បាប់នៅប្រទេសថៃក៏ត្រូវបានចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញតាមច្រកប៉ោយប៉ែតនៃខេត្តបន្ទាយមានជ័យ បន្ទាប់ពីរដ្ឋាភិបាលនៃប្រទេសថៃបានប្រកាសបិទការផ្តល់សុពលភាពឯកសារការងារ និងធ្វើដំណើរស្របច្បាប់សម្រាប់ពលករបរទេសទាំងអស់កាលពីចុងខែមិថុនា។

លោក មឿន តុលា នាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) ដែលតែងចុះជួបពលករនៅក្រៅប្រទេសដោយផ្ទាល់បានបន្ថែមថា រដ្ឋាភិបាលគួរមានវិធានការទប់ស្កាត់ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋចេញទៅធ្វើការនៅក្រៅប្រទេស។ លោកបន្ថែមថា ការបង្កើនទីផ្សារការងារក្នុងស្រុកប្រកបដោយគុណភាពគឺអាចធ្វើតាមរយៈការកំណត់ប្រាក់ឈ្នួល និងលក្ខខណ្ឌការងារសមរម្យ ការបង្វែរពីការផ្តល់សម្បទានដីទៅក្រុមហ៊ុនជាការផ្តល់ដីសម្បទានទៅឲ្យពលរដ្ឋដើម្បីជំរុញវិស័យកសិកម្ម ជាដើម។ លោកបញ្ជាក់ថា៖ «បើកាលណាយើងធ្វើបែបហ្នឹងគឺថា យើងអាចជួយទប់ពលរដ្ឋយើងហ្នឹងឲ្យគាត់នៅមានមុខរបរ ហើយនិងការងារក្នុងស្រុកបាន ជួញជិតគឺវាល្អជាងជួញឆ្ងាយហើយតែបើសិនជាជួញជិតមិនអាចឲ្យគាត់រស់បានទេ អាហ្នឹងជាហេតុផលមួយដែលឲ្យគាត់សម្រេចចិត្តប្រថុយប្រថានជួញឆ្ងាយវិញ»។

របាយការណ៍លទ្ធផលនៃសន្និបាតបូកសរុបការងាររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចេញកាលពីថ្ងៃទី១៣ ខែមីនាឆ្នាំ២០១៨ បង្ហាញថា រដ្ឋាភិបាលកម្ពុជាបានផ្តល់សេវាស្វែងរកការងារធ្វើនៅក្រៅប្រទេសដល់ពលរដ្ឋចំនួនជាង១,២លាននាក់។ ក្នុងចំណោមពលករទាំង១,២លាននាក់នោះ កម្ពុជាបានបញ្ជូនពលករទៅប្រទេសថៃចំនួនជាង១លាននាក់ កូរ៉េខាងត្បូងចំនួន៤ម៉ឺននាក់ ប្រទេសជប៉ុនចំនួន៦ពាន់នាក់ ម៉ាឡេស៊ីចំនួន៣ម៉ឺននាក់ ប្រទេសសិង្ហបុរីចំនួនជិត៥០០នាក់ និងតំបន់រដ្ឋបាលពិសេសហុងកុងបានចាប់ផ្តើមទទួលពលការិនីចំនួន១៥នាក់។ របាយការណ៍ដដែលនោះក៏បានអះអាងថា ប្រជាពលរដ្ឋកម្ពុជាមានការងារធ្វើសរុបចំនួន៩៩,៣%។

ចំណែកលោក យ៉េន ដែលកំពុងរស់នៅស្រុកកំណើតដោយមិនទាន់មានការងារធ្វើនិយាយថា៖ «ខ្ញុំចង់ឲ្យស្ថាប័នរដ្ឋយើងមានការងារធ្វើដូចស្រុកគេ ស្រុកគេមិនខ្វះការងារធ្វើ មិនបាច់ចាំទៅណាទេ ធ្វើតែក្នុងស្រុកហ្នឹង។ វ៉ៃយចំណាស់ណាក៏មានការងារធ្វើរហូតដល់រ៉ឺត្រែត (ចូលនិវត្តន៍) ស្រុកគេ។ ស្រុកយើងវាមិនមាន តែខ្ញុំចង់បានអីចឹងមិនបាច់ឲ្យប្រជាពលរដ្ឋយើងចំណាកស្រុកគ្រប់ប្រទេសអីចឹង»៕

## អាជ្ញាធរថៃចុះត្រួតចាប់បានពលករខុសច្បាប់ចំនួន172នាក់

https://www.facebook.com/ ទឹកចិត្តពលករឆ្លងដែន 29-08-2018

នៅថ្ងៃអង្គារ៍ ទី28 ខែសីហា ឆ្នាំ2018 អាជ្ញាធរថៃចុះត្រួតចាប់បានពលករខុសច្បាប់ចំនួន172នាក់ ក្នុងនោះមានពលករវៀតណាមខុសច្បាប់ចំនួន129នាក់ និងពលករកម្ពុជាខុសច្បាប់ចំនួន43នាក់ ។ ពលករទាំងអស់នេះធ្វើការនៅក្នុងប្រទេសថៃដោយខុសច្បាប់ អត់មានឯកសារអ្វីទាំងអស់មកបង្ហាញអាជ្ញាថៃ។ ចំពោះពលករកម្ពុជាខុសច្បាប់ចំនួន43នាក់ ត្រូវបានអាជ្ញាធរថៃនិងចាប់បញ្ជូនយកមកប្រទេសកម្ពុជាវិញ ចំពោះពលករវៀតណាម ខុសច្បាប់ចំនួន129នាក់ ត្រូវបានអាជ្ញាធរថៃនិងចាប់បញ្ជូនយកទៅដំណើរការតាមផ្លូវច្បាប់ ហេតុការណ៍នេះអាជ្ញាធរថៃចុះចាប់នៅច្រកផ្លូវចូលវត្ត សៅថងហិន ក្រុមទី3 ស្រុកហាត់យ៉ៃ ខេត្តនុនថះបុរី នៅប្រទេសថៃ ។

## ទីភ្នាក់ងារអន្តោប្រវេសន៍របស់ UN ថា ក្រុមជនចំណាកស្រុកអាហ្វ្រិកបាននិយាយថា ពួកគេត្រូវក្រុមអ្នករត់ពន្ធមនុស្ស ឃុំឃាំងរហូតដល់ ២ឆ្នាំក្នុងប្រទេសលីប៊ី

https://www.facebook.com/BTVCambodia/ 29-08-2018

ទីភ្នាក់ងារអន្តោប្រវេសន៍របស់ UN បានឲ្យដឹងកាលពីថ្ងៃអង្គារ ថា ក្រុមជនចំណាកស្រុកអាហ្វ្រិក ដែលត្រូវបានប្រទេសអ៊ីតាលីបដិសេធមិនទទួលយក កាលពីសប្តាហ៍មុនបាននិយាយថា ពួកគេត្រូវក្រុមអ្នករត់ពន្ធមនុស្ស ឃុំឃាំងរហូតដល់២ឆ្នាំក្នុងប្រទេសលីប៊ី ដែលមនុស្សជាច្រើនត្រូវបានគេធ្វើទារុណកម្ម និងរំលោភផ្លូវភេទ។ ជនអន្តោប្រវេសន៍ ១៩០នាក់ភាគច្រើនជាជនជាតិអេរីត្រេ និងជនជាតិសូម៉ាលី ត្រូវបានសង្គ្រោះនៅសមុទ្រមេឌីទែរ៉ាណេ

កាលពីថ្ងៃទី១៥ ខែសីហា នេះបើយោងតាមការឲ្យដឹងរបស់អ្នកនាំពាក្យ អង្គការទេសន្តរប្រវេសន៍អន្តរជាតិហៅកាត់ IOM លោក ចូអែល មីលម៉ាន បានប្រាប់ដល់សន្និសីទ អង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ។

## ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨

### ប៉ូលិសចាប់ខ្លួនជនជាតិអាមេរិកកាំងរំលោភកុមារជាច្រើននាក់រត់មកលាក់ខ្លួននៅកម្ពុជា

http://www.rasmeinews.com/ August 29, 2018, 10:19 PM

ដោយៈ មុនីរ័ត្ន/ភ្នំពេញៈ ប៉ូលិសអន្តោប្រវេសន៍បានចាប់ខ្លួនជនជាតិអាម៉េរិកកាំង ដែលបានរំលោភផ្លូវលើកុមារជាច្រើននៅសហរដ្ឋអាមេរិករួចរត់មកពួនសម្ងំលាក់ខ្លួននៅខេត្តព្រះសីហនុ។ ការចាប់ខ្លួននេះ បានធ្វើឡើងនៅយប់ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨នេះ នៅខេត្តព្រះសីហនុ។

នាយឧត្តមសេនីយ៍ សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍បានប្រាប់រស្មីកម្ពុជាថា ជនជាតិអាមេរិកដែលចាប់ខ្លួនឈ្មោះ William David BRENNER។ ការចាប់ខ្លួននេះ គឺបន្ទាប់ពីមានការស្នើរបស់ការិយាល័យសន្តិសុខភូមិភាគ (RSO) របស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា។ ហើយកម្លាំងរបស់លោកកំពុងតែបញ្ជូនមកភ្នំពេញ។

ចំណែកការិយាល័យសន្តិសុខភូមិភាគ បាននឹងកំពុងធ្វើការជាមួយនឹងស្ថាប័នពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក ដើម្បីបញ្ជូនខ្លួនជនល្មើសត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ដើម្បីធ្វើការកាត់ទោស។ យោងតាមលិខិតរបស់ការិយាល័យសន្តិសុខភូមិភាគ (RSO) របស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ផ្ញើជូនសម្តេច ស ខេង កាលពីថ្ងៃទី២៣ ខែសីហា បានឲ្យដឹងថា ការិយាល័យសន្តិសុខភូមិភាគ បានទទួលព័ត៌មានថា ពលរដ្ឋអាមេរិកាំងឈ្មោះ William David BRENNER មានដីកាចាប់ខ្លួនដែលមានសុពលភាព ពាក់ព័ន្ធបទរំលោភបំពានផ្លូវភេទជាបន្តបន្ទាប់ទៅលើកុមារ។

ក្រសួងការបរទេសសហរដ្ឋអាមេរិក បានលុបចោលសុពលភាពលិខិតឆ្លងដែនរបស់ជនល្មើស។ ហើយជនល្មើសកំពុងតែរស់នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ ដោយសារជនល្មើស គ្មានឯកសារធ្វើដំណើរដែលមានសុពលភាព វាស្តែងឲ្យឃើញថា ឈ្មោះ William David BRENNER កំពុងតែរំលោភទៅលើច្បាប់អន្តោប្រវេសន៍របស់ប្រទេសកម្ពុជា។

ការិយាល័យសន្តិសុខភូមិភាគស្នើសុំឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ជួយស្វែងរក និងឃាត់ខ្លួនជនល្មើសដោយផ្អែកលើច្បាប់របស់ប្រទេសកម្ពុជា។ ប្រសិនបើជនល្មើសបង្ហាញមុខនៅស្ថានទូត ការិយាល័យសន្តិសុខភូមិភាគនឹងជូនដំណឹងទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍អំពីវត្តមានជនល្មើសឈ្មោះ William David BRENNER។ ការិយាល័យសន្តិសុខភូមិភាគ បាននឹងកំពុងធ្វើការជាមួយនឹងស្ថាប័នពាក់ព័ន្ធរបស់សហរដ្ឋអាមេរិក ដើម្បីបញ្ជូនខ្លួនជនល្មើសត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ដើម្បីធ្វើការកាត់ទោស៕SRN

### ថៃ មានវត្តបណ្តុះបណ្តាលអាពាហ៍ពិពាហ៍ សម្រាប់ស្ត្រីប្រាថ្នារៀបការបុរសបរទេស

https://www.postkhmer.com/ Publication date 29 August 2018 | 16:09 ICT

**ក្រុងបាងកក** : ស្ថិតក្រោមគម្រោងរបស់ក្រសួងអភិវឌ្ឍសង្គម និងសន្តិសុខមនុស្សជាតិថៃ ក្លឹនិកមួយឈ្មោះ «កូនប្រសារស្រីថៃ កូនប្រសារប្រុសបារាំង» បើកសម្ពោធកាលពីថ្ងៃរសៀលពុធ នៅមណ្ឌលថៃទាំសុខភាពស្ត្រីក្នុងស្រុកមួយ។ តើនៅទីណា? ខុន ខែន ជាទីក្រុងធំមួយនៅភាគឦសាន្ត។ តំបន់នេះជាប់កំណត់ត្រាខ្ពស់បំផុតចំពោះអាពាហ៍ពិពាហ៍ថៃ-បារាំង ក្នុងប្រទេសថៃ ដោយស្ត្រីប្រមាណ ៨ ពាន់នាក់ក្នុងភាគឦសាន្តបានរៀបការជាមួយ

បរទេស។ ពេលនេះ និយាយពីគ្លីនិកឈ្មោះចម្លែកនេះ ខណៈវាស្តាប់ទៅទំនងជា «សាលាភរិយាថៃ» តាមពិតមិនមែនទេ។ គ្លីនិកនេះនឹងជួយអប់រំដល់ស្ត្រីថៃអំពីសិទ្ធិស្របច្បាប់ ពេលពួកគេផ្លាស់ទៅរស់នៅជាមួយប្តីបរទេស ព្រមទាំងវិធីចុះសម្រុងនឹងវប្បធម៌ថ្មី។ នេះបើយោងតាម Matichon។

រដ្ឋមន្ត្រីអភិវឌ្ឍសង្គម លោកអគ្គស្នងការ អាណាន់តាផន កាន់ចាណារ៉ាត់ បាននិយាយថា គ្លីនីកនេះក៏បនាក្លាយជាមជ្ឈមណ្ឌលជួយដល់ស្ត្រីថៃរស់នៅបរទេស ដែលព្យាយាមស្វែងរកសេវាកម្មសង្គ្រោះអំពីការរំលោភបំពាន ខណៈវាក៏សហការជាមួយស្ថានទូតថៃនៅជុំវិញពិភពលោកផងដែរ។

ស្របពេលនេះ នាយកដ្ឋានកិច្ចការនារី និងអភិរក្សគ្រួសារ អគ្គនាយក ឡែតផានយ៉ា ប៊ូរ៉ាណាបានឌិត បាននិយាយថា ពួកគេជ្រើសភាគឦសាន្តជាគោលដៅទីតាំងគ្លីនិកមិនមែនដោយសារតែវាមានចំនួនអាពាហ៍ពិពាហ៍ ថៃ-បារាំង ច្រើននោះទេ តែក៏ជួយដល់គ្រួសារក្រីក្រនៅទីនោះ ដែលតែងតែជំរុញកូនស្រីឲ្យរៀបការជាមួយជនបរទេសឲ្យចេះស្វែងរកពន្លឺជីវិតថ្មី។ ឡែតផានយ៉ា បានបន្តថា ប៉ុន្តែ ស្ត្រីថៃភាគច្រើនរមែងដើរដល់ផ្លូវអស់សង្ឃឹម ដោយខ្លះថែមទាំងរងនូវការបំពានផ្លូវកាយ ឬជួញដូរថែមទៀត។ ការផ្តល់ព័ត៌មានអំពីស្ត្រីថៃទទួលរងនូវវិបត្តិរស់នៅជាមួយជនបរទេស អាចចូលទៅកាន់គេហទំព័រ www.yingthai.net៕ HR *ប្រភព Coconuts Bangkok*

## ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨

## រឿងត្រាក្លែងក្លាយលើលិខិតឆ្លងដែនសមត្ថកិច្ចថៃចាប់បានជាបន្តបន្ទាប់ខាងកម្ពុជាគ្មានអ្នកទទួលខុសត្រូវ

https://www.facebook.com/Matemohachun1/ mmc-news ចុះថ្ងៃទី ៣១ សីហា ឆ្នាំ២០១៨

បន្ទាយមានជ័យ៖ ប៉ុន្មានថ្ងៃចុងក្រោយក្នុងខែសីហា 2018នេះ ករណីត្រាក្លែងក្លាយលើលិខិតឆ្លងដែនត្រូវបាននគរបាលអន្តោប្រវេសន៍ថៃប្រចាំច្រកទ្វារអន្តរជាតិខ្លងលឹក ស្រុកអារញ្ញ ខេត្តស្រះកែវឈមទឹកដីកម្ពុជាច្រកទ្វារអន្តរជាតិប៉ោយប៉ែតចាប់បានជាបន្តបន្ទាប់ ប៉ុន្តែខាងកម្ពុជាហាក់ស្ងាត់ស្ងៀមដូចគ្មានអ្វីកើតឡើងអ្នករងគ្រោះគឺជាពលករខ្មែរពិតជាមហាសែនធ្ងល់។

យោងព័ត៌មានថៃមួយបានផ្សាយកាលពីពេលថ្មីៗថា បុរសម្នាក់ឈ្មោះ ហ៊ា សេងអាយុ41ឆ្នាំ ត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួនដោយចោទកាន់លិខិតឆ្លងដែនប្រើប្រាស់ត្រាក្លែងក្លាយចំនួន12ក្បាល ក្នុងចំណោមលិខិតឆ្លងដែន 32ក្បាល កាលពីថ្ងៃទី26 សីហា 2018 នៅច្រកទ្វារអន្តរជាតិខ្លងលឹកក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ។

ដោយឡែកស្ត្រីម្នាក់ឈ្មោះ អុន ស្រីនាង អាយុ22ឆ្នាំ ជាពលការនីធ្វើការសំណង់នៅខេត្តនគររាជសីមា ប្រទេសថៃ និងមានទីលំនៅភូមិ(ក)ឃុំ និងស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ត្រូវបានសមត្ថកិច្ចថៃឃាត់ខ្លួនដូចគ្នាកាលពីវេលាម៉ោង12 ថ្ងៃត្រង់ ទី27 សីហា2018 ដោយចោទថា នាងប្រើប្រាស់ត្រាក្លែងក្លាយលើលិខិតឆ្លងដែន។

ឈ្មោះ ឡុង សំឡូ អាយុ27ឆ្នាំ ប្តីស្ត្រីរងគ្រោះប្រាប់តាមទូរស័ព្ទថា ប្រពន្ធគាត់ត្រូវសមត្ថកិច្ចថៃនៅច្រកទ្វារអន្តរជាតិខ្លងលឹកឃាត់ខ្លួនដោយចោទថា កាន់លិខិតឆ្លងដែនប្រើប្រាស់ត្រាក្លែងក្លាយ។ បុរសខាងលើបន្តថា ការពិតគាត់និងប្រពន្ធមិនដឹងរឿងអ្វីឡើយកន្លងមកមានលិខិតឆ្លងដែនវីសារ2ឆ្នាំ ទាំងប្តីទាំងប្រពន្ធធ្វើការជាកម្មករសំណង់នៅខេត្តនគររាជសីមា លុះប្តូរការងារថ្មីថៅកែ(ថ្មី)ឲ្យយកលិខិតឆ្លងដែនឲ្យគេនិងដើររឿងវាយបិទវីសាចាស់ហើយតវីសាថ្មីឲ្យ។ បុរសរូបនេះបន្តទៀតថា ក្រោយថៅកែថ្មីយកលិខិតឆ្លងដែនគេឲ្យគាត់ និងប្រពន្ធត្រឡប់មកកម្ពុជាវិញដើម្បីទទួលលិខិតឆ្លងដែនតវីសាថ្មីដែលគេទាក់ទងឲ្យក្រុមហ៊ុនមួយរត់ការឲ្យ។ គាត់ថាកាលពីថ្ងៃទី27 សីហា 2018 អ្នករត់ការគេទូរស័ព្ទឲ្យឡើងទៅថៃវិញ ហើយប្រាប់ថាលិខិតឆ្លងដែនតវីសារួចហើយ លុះប្រពន្ធគាត់ដើរចូលដល់ទីតាំងត្រួតពិនិត្យឯកសារឆ្លងដែននៅច្រកទ្វារអន្តរជាតិខ្លងលឹក ស្រាប់តែត្រូវសមត្ថកិច្ចថៃឃាត់ខ្លួនតែម្តង។ សូម្បីតែ

លិខិតឆ្លងដែនរបស់គាត់ក៏ត្រូវប្រពន្ធទូរស័ព្ទប្រាប់ថា ជាលិខិតឆ្លងដែនមានត្រាក្លែងក្លាយដូចគ្នាទើបគាត់មិនហ៊ានចូលទៅប្រទេសថៃដើម្បីបន្តការងារបាន។ បុរសខាងលើអះអាងថា ពួកគាត់ជាគ្រួសារក្រីក្រហើយមិនបានដឹងរឿងអ្វីទាំងអស់ហេតុអីមានអ្នកវាយឯកសារក្លែងក្លាយឲ្យពួកគាត់គ្មានអ្នកទទួលខុសត្រូវបែបនេះ។

ករណីខាងលើបានកើតមាននៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត-ខ្លងលឹកជាញឹកញាប់ចុះហេតុអ្វីសមត្ថកិច្ចកម្ពុជាទប់ស្កាត់មិនបាន ហើយមិនដឹងបែជាសមត្ថកិច្ចថៃចាប់បានរហូត។ ករណីទី1ខាងលើលោកសេមមករាប្រធានសេនាធិការនគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតប្រាប់ព័ត៌មានក្នុងស្រុកមួយថា មិនបានដឹងរឿងរ៉ាវខាងលើទេ។ គេឆ្ងល់ថាពលរដ្ឋមុនឆ្លងដែនចូលទៅដីថៃត្រូវបំពេញបែបបទ និងប្រថាប់ត្រាចេញ( Departure Pass )នៅខាងកម្ពុជាជាមុនហេតុអីសមត្ថកិច្ចកម្ពុជាបែជានាំគ្នាធ្វើមិនដឹងបែបនេះ ឬមួយនៅក្រុងប៉ោយប៉ែតមានទីតាំងប្រថាប់ត្រាក្លែងក្លាយសមត្ថកិច្ចមិនដឹង?។ បញ្ហានេះបើក្រសួងពាក់ព័ន្ធមិនស្រាវជ្រាវរកការពិតនិងបកស្បែកមុខជនខិលខូចទេនិងមានពលកររងគ្រោះជាបន្តបន្ទាប់ទៀតជាក់ជាមិនខានឡើយ៕ ដោយធីតា

## ពលការិនីខ្មែរអ៊ិស្លាមម្នាក់ទៀតដែលចាញ់បោកមេខ្យល់ត្រូវបានជួយសង្គ្រោះពីប្រទេសអារ៉ាប់

http://nokorwatnews.com/ ៣១/០៨/២០១៨

ភ្នំពេញ ៖ លោកឧកញ៉ា អូស្មាន ហាស្សាន់ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះ បណ្តាលវិជ្ជាជីវៈបានផ្តល់កិច្ចអន្តរាគមន៍ ដល់ពលការិនីខ្មែរម្នាក់ទៀតដែលចាញ់បោកមេខ្យល់ម្នាក់មិនមានក្រុមហ៊ុនច្បាស់លាស់ឈ្មោះ ធីប ណូស្នី នៅភូមិថ្មី ឃុំ ពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំទៅធ្វើការខុសច្បាប់នៅប្រទេសអារ៉ាប៊ីសា អ៊ូឌីតរយៈពេលជាង២ឆ្នាំ ។

ពលការិនីជនរងគ្រោះឈ្មោះ លី សំរ៉ោះ អាយុ២២ឆ្នាំ ជនជាតិខ្មែរអ៊ិស្លាម មកពីភូមិត្រពាំងថ្ម ឃុំពពេល ស្រុកពញា ក្រែក ខេត្តត្បូងឃ្មុំ ជាកូនច្បង ក្នុងចំណោម បងប្អូន៧នាក់ ដែលជាគ្រួសារកសិករ មាន ជីវភាពក្រលំបាកបានសម្រេចចិត្តទៅធ្វើការជាស្ត្រីបម្រើការងារផ្ទះនៅអារ៉ាប៊ីសា អ៊ូឌីតតាមរយៈមេខ្យល់ខុសច្បាប់មិនមានក្រុមហ៊ុន និងអាជ្ញាបណ្ណបញ្ជូនពលករ បានបញ្ជូននាងទៅធ្វើការកាលពីខែមិថុនា ឆ្នាំ២០១៧។ តាមការបញ្ជាក់ដោយផ្ទាល់ពីស្ត្រីរងគ្រោះខាងលើបានឲ្យដឹងថា កំឡុងពេល ជាង១៤ខែដែលខ្លួនស្នាក់នៅបម្រើការងារនៅអារ៉ាប៊ីសាអ៊ូឌីតគឺភាគីមេខ្យល់ដែល បញ្ជូននាងទៅដោយខុសច្បាប់នោះបានទាក់ទងនិយាយគ្នាបានម្តងគត់។ តែក្រោយ មកក៏បាត់ឈ្មោះសូន្យឈឹងលែងទាក់ទងបាន ខណៈដែលខ្លួនជាស្ត្រីបម្រើការងារ បានបន្តធ្វើការងារទាំងវេទនាត្រូវបានម្ចាស់ផ្ទះប្រើឲ្យធ្វើការហួសកម្លាំង និងលើស ម៉ោងរហូត ។ ស្ត្រី លី សំរ៉ោះ បានបន្ថែមថា ទោះយ៉ាង ណាបញ្ហារំលោភលើកម្លាំងពលកម្មមិន សូវចោទជាបញ្ហាធំនោះទេ។ អ្វីដែលជា ឧបសគ្គធំធេងបំផុតធ្វើឲ្យនាងរកវិធីចាកចេញពីផ្ទះដែលធ្វើការក៏ដូចជារកអ្នកជួយធ្វើអន្តរាគមន៍ពីរាជរដ្ឋាភិបាល និងថ្នាក់ដឹក នាំក្រសួងពាក់ព័ន្ធគឺដោយសារតែថៅកែប្រុសជាភាគីម្ចាស់ផ្ទះដែលខ្លួននៅបម្រើ ការងារនោះក្រៅពីរំលោភលើកម្លាំងពល កម្មធ្វើការហួសកំណត់ ហើយតែងតែមកឆាឆៅក្នុងគោលបំណងប៉ុនប៉ងរំលោភលើខ្លួនប្រាណរបស់នាងថែមទៀតដែលតែងតែបង្ករឿងភិតភ័យដល់រូបនាងជារឿយៗ។

ភ្លាមៗឆ្លើយតបនឹងការប្រកាសស្វែង រកការជួយអន្តរាគមន៍ពីសំណាក់ស្ត្រីរងគ្រោះខាងលើលោក អូស្មាន ហាស្សាន់ បាន លើកឡើងថា ក្នុងនាមជារដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទទួលភារកិច្ចពីសម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផ្ទាល់ក្នុងការទទួលបន្ទុកដោះស្រាយរាល់បញ្ហានានាទាក់ទងនឹងវិស័យពលកម្មការងារ និងបញ្ហាផ្សេងៗនៅបណ្តាប្រទេសមជ្ឈិមបូព៌ាលោកក៏បានចាត់ចែងដោះស្រាយជាបន្ទាន់ ដោយទំនាក់ទំនងជាមួយស្ថានទូត កម្ពុជាប្រចាំប្រទេសអេហ្ស៊ីបដើម្បីផ្តល់បទអន្តរាគមន៍សម្រួលឲ្យនារីរងគ្រោះខាងលើនេះបានចាកចេញពីម្ចាស់ផ្ទះជនជាតិអារ៉ាប់ដែលខ្លួន

កំពុងបម្រើការងារទៅរកមណ្ឌលគាំពារស្ត្រីរងគ្រោះអារ៉ាប៊ីសាអ៊ូឌីតដោយ សុវត្ថិភាព និងបានត្រឡប់មកកាន់កម្ពុជាវិញដោយសុវត្ថិភាពនៅយប់ថ្ងៃទី២៩ ខែ សីហា ឆ្នាំ២០១៨ ។ លោក អូស្មាន ហាស្សាន់ បានបញ្ជាក់ ថា នេះជានារីរងគ្រោះទី៥ហើយ ដែលលោកបានដោះស្រាយឲ្យបានវិលត្រឡប់មកកម្ពុជាវិញដោយសុវត្ថិភាព ប៉ុន្តែដោយ សារនៅប្រទេសអារ៉ាប់នោះមិនទាន់មានស្ថានទូត ឬស្ថានកុងស៊ុលរាល់ការដោះ ស្រាយបញ្ហាម្តងៗមានការលំបាកយឺតយ៉ាវដែលលើកទី១ លោកបានសហការស្ថាន ទូតកម្ពុជាប្រចាំនៅរដ្ឋគុយវ៉ែតផង អេហ្ស៊ីប ផង។ រីឯលើកទី២, ៣, ៤ និងទី៥នេះយើង សហការជាមួយស្ថានទូតប្រចាំនៅអេហ្ស៊ីបតែម្តង ។

ពលការិនីរងគ្រោះ លី សំរ៉ោះ ក៏បាន ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងថ្លែងអំណរគុណដល់លោក អូស្មាន ហាស្សាន់ ជាថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសហការីព្រមទាំងស្ថានទូតកម្ពុជាប្រចាំនៅប្រទេសអេហ្ស៊ីបដែលបានជួយធ្វើអន្តរាគមន៍ដោះស្រាយទុក្ខលំបាករបស់នាងបានទាន់ ពេលវេលា ៕ ហេង សូរិយា

## ក្រសួងការបរទេស អាមេរិក ផ្តល់ចំណាត់ថ្នាក់លេខ២ ជូនកម្ពុជាខាងគ្មាន ការជួញដូរមនុស្ស

https://www.dap-news.com/ ByID:121 Posted on August 30, 2018

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានថ្លែងថា ក្រសួងការបរទេសរដ្ឋអាមេរិក បានផ្តល់ចំណាត់ថ្នាក់លេខ ២ ជូនកម្ពុជា ខាងផ្នែកគ្មានការជួញដូរមនុស្ស ខណៈរាជរដ្ឋាភិបាលកម្ពុជា មានឆន្ទៈពិតប្រាកដក្នុង ការទប់ស្កាត់បទល្មើសនេះ ។ ក្នុងវេទិកាអន្តរសាសនា ថ្នាក់ជាតិនៅកម្ពុជាលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្ស នៅថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៨ សម្តេច ស ខេង ថា នេះជាមុខមាត់របស់កម្ពុជាដូច្នេះ កាលណាដែលកម្ពុជាប្រឆាំងការជួញដូរ មនុស្សបានខ្លាំងក្លាដូច្នេះកម្ពុជាគឺជាប្រទេស ផ្តល់តម្លៃជីវិតមនុស្ស។ សម្តេច ស ខេង មានប្រសាសន៍ថា "តាមការវាយតម្លៃប្រចាំឆ្នាំ នៃក្រសួងការបរទេសសហរដ្ឋអាមេរិក កម្ពុជាយើងមិន ដែលធ្លាក់ដល់លេខ៣នោះទេ ឥឡូវនេះយើងបានឈរនៅលេខ២នេះ ប៉ុន្មានឆ្នាំមកនេះ ពីរឆ្នាំ បីឆ្នាំចុងក្រោយនេះ ដែលនេះជាមោទនភាពរបស់យើងដែរ ហើយប្រហែលជាយើងខិតខំ ប៉ុន្តែមិនទាន់ដឹងថាប៉ុន្មានឆ្នាំទៀតទើបបាន លេខ១នោះទេ"។

សម្តេចបន្តថាចំណាត់ថ្នាក់លេខ១ គឺជាប្រទេសដែលគ្មានអំពើជួញដូរមនុស្ស-ចំណាត់ថ្នាក់លេខ២ គឺជាប្រទេសដែលមានការជួញដូរ មនុស្សតិចតួច ខណៈរាជរដ្ឋាភិបាល មានឆន្ទៈក្នុងការ ទប់ស្កាត់-ចំណាត់ថ្នាក់លេខ៣ គឺជាប្រទេសដែលមានការជួញដូរមនុស្សដូច្នេះរដ្ឋាភិបាល គ្មានឆន្ទៈក្នុងការទប់ស្កាត់។ សម្តេចក្រឡាហោម ស ខេង ក៏បានអំពាវនាវ ដល់សមត្ថកិច្ច និងភាគីពាក់ព័ន្ធ ត្រូវពង្រឹងការផ្សព្វផ្សាយ បន្ថែមដល់ពលរដ្ឋ ឲ្យស្វែងយល់ កាន់តែច្បាស់ អំពីការជួញដូរមនុស្ស គ្រប់ទម្រង់ ដែលអាចនឹងកើតមានឡើងនៅកម្ពុជា។

យោងតាមរបាយការណ៍ របស់អង្គការសហប្រជាជាតិ បានឲ្យដឹងថា គ្រាន់តែក្នុងតំបន់ អាស៊ីប៉ាស៊ីហ្វិក មានជនរងគ្រោះ ដែលជាបុរស ស្ត្រី យុវវ័យ កុមារ ទារក ប្រមាណជិត១២លាន នាក់ កំពុងតែទទួលរងការរំលោភបំពាន បំបាត់សិទ្ធិជាមនុស្ស និងត្រូវបានកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ ក្នុងរូបភាពជាទាសភាពក្នុង សម័យទំនើប៕

## សម្តេច ស ខេង ៖ ការជួញដូរមនុស្ស រាប់លាននាក់ មានស្ទើរ តែគ្រប់ទីកន្លែង ក្នុងពិភពលោក

https://www.dap-news.com/ ByID:112 Posted on August 30, 2018

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានថ្លែងថា អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ច កម្លាំងពលកម្ម និងផ្លូវភេទ លើមនុស្ស រាប់លាននាក់ មានស្ទើរតែគ្រប់ទីកន្លែងក្នុងពិភពលោក ដែលរងទុក្ខវេទនា រហូតដល់បាត់បង់ អាយុជីវិត ជារៀងរាល់ថ្ងៃ ដូច្នេះសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ត្រូវរួមគ្នាទប់ស្កាត់ ។

យោងតាមរបាយការណ៍ របស់អង្គការសហប្រជាជាតិ បានឲ្យដឹងថា គ្រាន់តែក្នុងតំបន់ អាស៊ី ប៉ាស៊ីហ្វិក មានជនរងគ្រោះ ដែលជាបុរស ស្ត្រី យុវវ័យ កុមារ ទារក ប្រមាណជិត១២លាន នាក់ កំពុងតែទទួលរងការរំលោភបំពាន បំបាត់សិទ្ធិជាមនុស្ស និងត្រូវកេងប្រវ័ញ្ចយ៉ាងធ្ងន់ធ្ងរ ក្នុងរូបភាពជាទាសភាពក្នុងសម័យទំនើប។

ក្នុងវេទិកាអន្តរសាសនាថ្នាក់ជាតិ នៅកម្ពុជាលើកទី២ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ សម្តេច ស ខេង បានឲ្យដឹងថា អង្គការមិនមែន រដ្ឋាភិបាល ជាតិ-អន្តរជាតិ យុវជន-យុវនារី ត្រូវរួមគ្នាប្រយុទ្ធប្រឆាំង ការជួញដូរមនុស្ស ដែលកំពុងតែកើត មានជាបន្តបន្ទាប់ ចំពោះប្រជាជនកម្ពុជា និងមនុស្សជាតិគួរឲ្យបារម្ភ។ សម្តេចបន្តថា "អំពើជួញដូរមនុស្ស ដែលរួមទាំងការលក់ដូរមនុស្ស ការជួញដូរសេរីរាង្គមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងផ្លូវភេទលើមនុស្ស បានធ្វើឲ្យមនុស្សគ្រប់ប្រភេទ គ្រប់វ័យ តាំងពីទារក កុមារ យុវវ័យ និងមនុស្សចាស់រាប់លាននាក់ នៅស្ទើរតែគ្រប់ទីកន្លែងក្នុង ពិភពលោក រងទុក្ខវេទនា បាត់បង់កិត្តិយស សេចក្តីថ្លៃថ្នូរ បាត់បង់សិទ្ធិជាមនុស្ស និងសេចក្តីសុខក្នុងគ្រួសារ ខូចខាតសុខភាពផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ រហូតដល់បាត់បង់ អាយុជីវិតជារៀងរាល់ថ្ងៃ"។ សម្តេចបន្តថា នេះជាសោកនាដកម្មសម្រាប់មនុស្សជាតិ ដែលបង្កដោយជនអគតិ និងឧក្រិដ្ឋជន ទាំងឡាយដែលព្យាយាមរកគ្រប់វិធី ដើម្បីកេងចំណេញផលប្រយោជន៍ លើអ្នកដទៃ ទោះបីជាធ្វើឲ្យគេរងទុក្ខវេទនា ផ្លូវកាយ ផ្លូវចិត្ត និងអាយុជីវិតយ៉ាងណាក៏ដោយ ដែលនេះជាអំពើឃោរឃៅ អមនុស្សធម៌ គួរឲ្យស្អប់ខ្ពើម។

ឧបនាយករដ្ឋមន្ត្រីបន្ថែមថា គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់ ការគោរពសិទ្ធិមនុស្ស កិច្ចការពារប្រជាពលរដ្ឋ ពីការរំលោភបំពាន កេងប្រវ័ញ្ច និងអំពើ ជួញដូរមនុស្សគ្រប់រូបភាព និងប្តេជ្ញាចិត្តធ្វើសកម្មភាពបង្ការទប់ស្កាត់ តាមរយៈការបន្តផ្សព្វ ផ្សាយ អប់រំណែនាំតាមបែបសាសនា ដល់សាសនិកគ្រប់និកាយសាសនាទាំងអស់ ដែលមាន នៅកម្ពុជា ដើម្បីឲ្យយល់ដឹងអំពីប្រភេទ និងផលប៉ះពាល់នៃបទល្មើសជួញដូរមនុស្ស និងនាំគ្នា លុបបំបាត់ទាសភាពសម័យទំនើបនេះឲ្យអស់ពីទឹកដីនៃកម្ពុជា។ ឱកាសនោះ សម្តេច ស ខេង ក៏បានលើកឡើងទៀតថា ក្រសួងមិនអត់អោនចំពោះជនណា ដែលបង្កបញ្ហាសាងនូវបទឧក្រិដ្ឋបំផ្លាញមនុស្សជាតិ និងបំបែកបំបាក់សាមគ្គីភាព ភាព សុខដុមរមនាក្នុងសង្គម ព្រមទាំងបំផ្លាញវប្បធម៌ប្រពៃណី ដ៏ល្អផូរផង់របស់កម្ពុជា ដែលមាន តាំងពីយូរលង់មកហើយ ៕ ដោយ អេង ប៊ូឆេង

---